# វិសុទ្ធិកថា

## សំដែងអំពីវិសុទ្ធិ ៧ ប្រការ

## ដែលព្រះមុនីកោសល សូរ-ហាយ

អធិបតីរងនៃក្រុមជំនុំព្រះត្រៃបិដក ពុទ្ធសាសនបណ្ឌិត្យក្រុងភ្នំពេញ
ចៅអធិការវត្តនិរោធរង្សី ឃុំច្បារអំពៅ ស្រុកកៀនស្វាយ

## រៀបរៀបអធិប្បាយ

ព.ស ២៥០៨ គ.ស ១៩៦៥

ការផ្សាយរបស់ បណ្ណាគារ ជឹងបោ-ហួត លេខ ១៤០
វិថីព្រះបាទអង្គអេង ក្រុងភ្នំពេញ

សៀវភៅ **វិសុទ្ធិកថា** នេះ

អាត្មាបានជូនទៅលោកស្រី វេជ្ជបណ្ឌិត **គ្រួយ លាងស៊ីម** អោយយកទៅបោះពុម្ពចែកជា ធម្មទានតាមសទ្ធារបស់លោកស្រី ។ លោកស្រីបានដឹង ឃើញហើយក៏មានចិត្តជ្រះថ្លាដ៏ខ្លាំងក្លា ទទួលយកទៅបោះចែកជាធម្មទានផ្ទាល់លោកស្រី១ផ្នែក យកមកចែកជូនចំពោះពុទ្ធបរិស័ទជុំវិញវត្តព្រះពុទ្ធមានបុណ្យ ចំនួន៤០០ចប់១ផ្នែក ។ ការបោះពុម្ពនេះជាទ្រព្យផ្ទាល់របស់លោកស្រីពុំមាន ឃោសនាបបួលអ្នកដទៃទេ ។

សូមអស់លោកជា សីលវា សីលវតី ទទួលដោយសោមនស្ស ដើម្បីបានស្គាល់ ឃើញផ្លូវត្រង់ទៅកាន់ព្រះអមតមហានិព្វានគ្រប់ៗគ្នា ។

សូមជូនពរមហាប្រសើរ លោកស្រីជាធម្មទានមានប្រាថ្នា ផ្លូវលោក ផ្លូវធម៌ ភ្លឺថ្លាត្រចះត្រចង់គ្រប់ៗជាតិ និងសូមអោយបានសម្រេចនូវព្រះបរមសុខ គឺព្រះនិព្វានក្នុងជាតិណាមួយ កុំបីខកខានឡើយ ។

**សព្វទានំ ធម្មទានំ ជិនាតិ** ។

ធម្មទាន រមែងឈ្នះទាន ទាំងអស់ ។

**ព្រះពុទ្ធឃោសាចារ**

ចៅអធិការ វត្តព្រះពុទ្ធមានបុណ្យ

**ហេង លាងហោ**

# អារម្ភកថារបស់អ្នករៀបរៀង

សៀវភៅវិសុទ្ធិកថានេះ សំដែងអំពីវិសុទ្ធិ ៧ប្រការ មានសីលវិសុទ្ធិជាដើម ប៉ុន្តែវិសុទ្ធិទី ១ ទី ២ ពុំបានសំដែងពិស្តារទេ គ្រាន់តែអធិប្បាយសម្រួលតាមលំអាន ដោយសង្ខេប ព្រោះថា សៀវភៅសីលនិទ្ទេសនិងសមាធិនិទ្ទេសដែលពិស្តារមានសព្វគ្រប់ហើយ ។

វិសុទ្ធិ ៧ ប្រការ ដែលមានក្នុងគម្ពីរវិសុទ្ធិមគ្គនោះ មានសេចក្តីពិស្តារក្រៃពេកពេកណាស់ ក្នុងទីនេះមិនអាចនឹងរៀបរៀងឱ្យអស់បានឡើយ ។ ខ្ញុំជ្រើសរើសដកស្រង់ចំពោះតែអត្ថបទ ដែលត្រូវការមើល ទន្ទេញ ពិចារណាងាយយល់បានផង ងាយនឹងចាត់ការបោះពុម្ពផង ។ សៀវភៅនេះបានបោះពុម្ពចែកជាធម្មទានតាំងពី ព.ស ២៤៨៣ ម្តងហើយដោយកុដុម្ពិក អ៊ា.ស៊ាំងហោ នៅផ្សារព្រៃកសណ្តែក ស្រុកស៊ីធរកណ្តាល ចេញបច្ច័យបោះពុម្ព ក្នុងឱកាសឆ្លងសាលាបាលីរង និងធម្មមន្ទីរក្នុងវត្តព្រៃកចង្ក្រានលើ ។ សៀវភៅនេះជាផ្លូវធម៌សុទ្ធឥតលាយដោយផ្លូវលោកទេ រាប់ថាជាឧបករណ៍ នៃការសិក្សាធម្មវិន័យថ្នាក់ឯកបានដោយពិត ព្រោះជាគោលនៃសីល សមាធិ បញ្ញា ដើម្បីបំភ្លឺផ្លូវឱ្យត្រង់ទៅរកមគ្គផលនិព្វាន ។ ក្នុងឱកាសអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទី ១៥ ឈ្មោះបតីបេ-យាន បានសូមយកទៅបោះពុម្ព ដើម្បីប្រគេនជាធម្មទានចំពោះមន្ត្រីសង្ឃដោយគហបតីធ្លាប់ ជាអ្នកមានសទ្ធាជ្រះថ្លា ក្នុងការធ្វើធម្មទានតែរៀងរាល់ឆ្នាំទាំងស្រលាញ់ពេញចិត្តចំពោះធម៌ ក្នុងផ្ទៃសៀវភៅនេះ ក្រៃពេកណាស់ ។

ខ្ញុំអ្នករៀបរៀងសៀវភៅនេះ ក៏បានអនុញ្ញាតឱ្យគហបតីយកទៅបោះពុម្ព
ាយសេចក្ដីសោមនស្ស ចំពោះមហាកុសលដ៏ប្រសើរនេះ តាមបំណងនៃ
ហបតី ។ លុះមកដល់ ឆ្នាំម្សាញ់សប្ដស័ក ព.ស ២៥០៨ គ.ស ១៩៦៥
ណ្ណាគារ ជិង ប៉ោ-ហួត លេខ ១៤០ វិថីព្រះអង្គអេងក្រុងភ្នំពេញ ក៏សូមយក
ៅបោះពុម្ពផ្សាយទៀត ។

ព្រះមុនីកោសល សូរ-ហាយ

អធិបតីរងនៃក្រុមជំនុំព្រះត្រៃបិដក

ចៅអធិការវត្តនិរោធរង្សី

ឃុំច្បារអំពៅ

# សន្ទឹកចង្អុលប្រាប់មាតិកាធម៌


| ឈ្មោះមាតិកាធម៌ | ទំព័រ |
|---|---|
| បរិយាយខាងដើមនៃវិសុទ្ធិ ------------------- | ១ |
| វិសុទ្ធិ ៧ ប្រការ ---------------------------- | ៦ |
| **វិសុទ្ធិទី ១** | |
| អធិប្បាយអំពីសីល --------------------------- | ៧ |
| សីល ៤ ពួក ------------------------------- | ៩ |
| ការជម្រះសីល ដោយស្ថាន ៣ យ៉ាង ------------------- | ៩ |
| **វិសុទ្ធិទី ២** | |
| សំដែងអំពីចិត្តានុបរិវត្តិ -------------------------- | ១១ |
| ចិន្តា ៣ យ៉ាង ------------------------------ | ១២ |
| សេវនប្បច្ច័យរបស់ចិត្ត ---------------------------- | ១៣ |
| សេចក្តីប្រៀបធៀបអំពីរូបកាយនិងចិត្ត ----------------- | ១៥ |
| អាហាររបស់ចិត្ត ------------------------------ | ១៥ |
| អធិប្បាយនីវរណៈ ៥ យ៉ាង ------------------------- | ១៦ |
| កិលេសកាម ៦ យ៉ាង --------------------------- | ១៧ |
| សំដែងអំពីចិត្តបរិហារ -------------------------- | ១៩ |
| កម្មដ្ឋាន ២ យ៉ាង ------------ ------------- | ១៩ |
| កម្មដ្ឋានចែកជា ៧ ពួក ------------------------ | ២០ |
| ចេតោវិមុត្តិ ចាស់ក្លាដោយធម៌ គឺបុគ្គលិកលក្ខណៈ ៥ យ៉ាង ------ | ២១ |
| ត្រូវចំរើនធម៌ ៤ យ៉ាង ------------------------- | ២២ |

# សន្លឹកចង្អុលប្រាប់មាតិកាធម៌


| ឈ្មោះមាតិកាធម៌ | ទំព័រ |
|---|---|
| គួរប្រយ័ត្តចិត្តក្នុងស្ថាន ៤ យ៉ាង | ២២ |
| ការសង្រួមចិត្តមាន ៣ យ៉ាង | ២៣ |
| សមាធិចែកចេញជា ៣ យ៉ាង | ២៤ |
| **វិសុទ្ធិទី ៣** | |
| សង្ខារ ២ យ៉ាង | ២៦ |
| អធិប្បាយអំពីលក្ខណៈ ៣ យ៉ាង | ២៧ |
| អនិច្ចៈ ដោយហេតុ ៤ យ៉ាង | ២៨ |
| សត្វលោកជាប់ចំណោទនៃសេចក្ដីទុក្ខ | ២៨ |
| ទុក្ខៈដោយហេតុ ៤ យ៉ាង | ២៩ |
| អនត្តាដោយហេតុ ៤ យ៉ាង | ៣០ |
| **វិសុទ្ធិទី ៤** | |
| ពិចារណាស្វែងរកហេតុបច្ច័យនៃនាមរូប ៥ យ៉ាង | ៣២ |
| សេចក្ដីសង្ស័យ ១៦ យ៉ាង | ៣៤ |
| **វិសុទ្ធិទី ៥** | |
| ការកំណត់ទុកដោយបញ្ញានូវនាមរូប | ៣៦ |
| សញ្ញា ៣ ប្រការបិទបាំងត្រៃលក្ខណ៍ | ៣៦ |
| អនុបស្សនា ៣ អាចកំចាត់សញ្ញា ៣ ប្រការ | ៣៧ |

# សន្ទឹកចង្អុលប្រាប់មាតិកាធម៌

**ឈ្មោះមាតិកាធម៌** **ទំព័រ**

វ័យ ៣ ប្រការ ---------------------------------- ៣៧

រយៈកាលរបស់វ័យ ១០ប្រការ ---------------------- ៣៨

អន្តរកប្ប ៣ យ៉ាង ------------------------------- ៤០

វិបស្សនូបក្កិលេស ១០ ប្រការ ---------------------- ៤០

វិសុទ្ធិទី ៦

វិបស្សនាញាណ ៩ ប្រការ -------------------------- ៤៣

១- ឧទយព្វយានុបស្សនាញាណ ----------------- ៤៣

និព្វត្តិលក្ខណៈ វិបរិណាមលក្ខណៈ ៥ យ៉ាង -------- ៤៤

២- ភង្គានុបស្សនាញាណ --------------------- ៤៥

៣- ភយតុបដ្ឋានញ្ញាណ ---------------------- ៤៦

៤- អាទីនវានុបស្សនាញាណ ------------------ ៤៦

៥- និព្វិទានុបស្សនាញាណ ------------------ ៤៧

៦- មុញ្ចិតុកម្យតាញាណ --------------------- ៤៧

៧- បដិសង្ខានុបស្សនាញាណ ---------------- ៤៧

ឧបមាអំពីបុរសចាប់ពស់ស្មានថាជាត្រី ------------- ៤៨

៨- សង្ខារុបេក្ខាញាណ ------------------------ ៤៩

ឧបមា ១២ យ៉ាង មានសត្វប្រជៀវជាដើម ------------ ៥

៩- អនុលោមញ្ញាណ --------------------------

# សន្ទឹកចង្អុលប្រាប់មាតិកាធម៌

ឈ្មោះមាតិកាធម៌ ទំព័រ


ជវនចិត្ត ៣ យ៉ាង កើតឡើង ------------------ ៥៦

ពុទ្ធសាសនាមានធុរៈ ២ យ៉ាង ------------------ ៥៦

## វិសុទ្ធិទី ៧

អធិប្បាយអំពីគោត្រភូញាណ ---------------------- ៥៧

មគ្គបានឈ្មោះដោយហេតុ ៥ យ៉ាង ------------------- ៥៨

មគ្គញ្ញាណអាចលះសំយោជនៈ --------------------- ៦០

កិច្ចរបស់មគ្គញ្ញាណ ៤ យ៉ាង ---------------------- ៦១

កិច្ចមគ្គញាណ ១៦ ហៅថាសោឡសកិច្ច ---------------- ៦១

កិច្ចរបស់ប្រទីប ៤ យ៉ាង ------------------------- ៦១

កិច្ចរបស់ព្រះអាទិត្យ ៤ យ៉ាង --------------------- ៦២

កិច្ចរបស់នាវា ៤ យ៉ាង -------------------------- ៦២

ជវនចិត្តលឿនទៅបាន ៧ ខណៈ --------------------- ៦២

អានិសង្សនៃបញ្ញាភាវនា ៤ យ៉ាង ------------------ ៦៣

បុព្វកិច្ចនៃលោកអ្នកចូលនិរោធ ៤ យ៉ាង --------------- ៦៤

អ្នកស្លាប់ និងលោកចូលនិរោធ ប្លែកគ្នាដូចម្តេច ? ----------- ៦៦

សោតាបន្នបុគ្គល ៣ ពួក ------------------------- ៦៧

អនាគាមិបុគ្គល ៥ ពួក ------------------------- ៦៨

វិសុទ្ធិ ៧ សង្គ្រោះចូលក្នុងធម្មក្ខន្ធ ៣ ------------------ ៦៩

# វិសុទ្ធិកថា

## នមត្ថុ រតនត្តយស្ស

សូមនមស្ការ ចំពោះព្រះរត្នត្រ័យ ។

## បរិយាយខាងដើមនៃវិសុទ្ធិ

មនុស្សទាំងអស់ ក្នុងលោក សុទ្ធតែប្រាថ្នាឈមមុខទៅរកសេចក្ដីសុខគ្រប់ៗគ្នា ឥតមាននរណាមួយបដិសេធសេចក្ដីសុខចោលឡើយ ដូចយ៉ាងពួកមនុស្ស ដែលខំប្រឹងប្រកបការងារនីមួយៗ ក៏សុទ្ធតែត្រូវការចង់ឱ្យចួបប្រទះសេចក្ដីសុខទាំងអស់ ពីថាប្រឹងប្រកបលៃលក ដើម្បីស្ទាក់រកតែសេចក្ដីសុខប៉ុណ្ណោះ។ ឯការងារដែលគេត្រូវប្រកបនោះ ក៏មានច្រើនយ៉ាងគឺ កិច្ចការ ខ្លះក្រខ្លះងាយ ខ្លះធ្ងន់ ខ្លះស្រាល ខ្លះច្រើន ខ្លះតិច តាមធម្មតាការងាររបស់មនុស្សរាល់ស្រុក រាល់ប្រទេស ក្នុងផ្លូវ ជើងទឹក ឬ ជើងគោក ។

ការងារទាំងអស់ ទោះបីមានច្រើនយ៉ាងក៏ពិត ប៉ុន្តែបើបំព្រួញឱ្យតិចចុះមកមានត្រឹមតែ២យ៉ាងគឺ ការងារដែលលាយច្រឡំដោយទោស មានការសម្លាប់សត្វជាដើម ហៅថា សាវជ្ជកម្ម ១ ការងារដែលប្រាសចាកទោសមានវៀរចាកការសម្លាប់សត្វជាដើម ហៅថា **អនវជ្ជកម្ម** ១ ។ មនុស្សគ្រប់ពួករមែងប្រទះការងារ២យ៉ាងប៉ុណ្ណោះ ការងារណាមួយពុំខាន ។ ពួកអ្នកដែលចុះដៃចាប់ធ្វើការងារប្រកបដោយទោសនោះ អ្នកខ្លះដឹងថា អំពើនុ៎ះជាទោសដែរ ប៉ុន្តែព្រោះ មានៈសេចក្ដីប្រកាន់រឹងរូសក៏មាន ព្រោះទាល់ផ្លូវក៏មាន ហើយក៏ក្លែង

ចចេសធ្វើទាំងបំពាន , អ្នកខ្លះមិនដឹងថា អំពើនុ៎ះៗជាទោសទេ ព្រោះសេចក្ដីល្ងង់ខ្លៅសុទ្ធក៏មាន ព្រោះទំលាប់ធ្វើមកមិនដែលមានគេស្ដីប្រដៅក៏មាន ក៏ធ្វើដោយមោហៈតាមទំនើងចិត្តខ្លួនយ៉ាងស្និទ្ធឥតញញើត ។ អំពើដែលប្រកបដោយទោសតែងនាំមកនូវទុក្ខភ័យ ក្ដៅក្រហាយក្នុងកាលជាខាងក្រោយ ដល់បុគ្គលអ្នកដែលធ្វើ មិនមែនជាអំពើនាំមកនូវសេចក្ដីសុខក្សេមក្សាន្តឡើយ ។ ផលបាបអកុសលទុច្ចរិតមានសម្លាប់សត្វជាដើម ដែលបុគ្គលណាធ្វើហើយតែងវិលតាមបុគ្គលនោះវិញ ដូចជាស្រមោលជាប់តាមរូប ។ មួយទៀត បុគ្គលអ្នកប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេងៗ គង់នឹងបានទទួលទុក្ខភ័យក្ដៅក្រហាយស្ដាយក្រោយក្នុងពេលណាមួយមិនខាន ពុំនោះទោះជាចូលទៅកាន់ទីប្រជុំបរិស័ទណាតែងមានសេចក្ដីរង្កៀសរអើលខ្លួនឯង ដូចគោដំបៅខ្នង រអើលនឹងក្អែកដែលហើររំលងពីលើជាដរាប ។ អំពើអាក្រក់នោះសុទ្ធតែជាមូលហេតុនៃទុក្ខភ័យទាំងអស់ ។ ចំណែកខាងកុសលកម្មអំពើសុចរិតពិតទៀងត្រង់ ជាមូលហេតុនៃសេចក្ដីក្សេមក្សាន្ត ត្រជាក់ចិត្តគ្រប់កាលទាំងពួង ព្រោះហេតុនោះ សាធុជនទាំងឡាយ អ្នកប្រាថ្នាសេចក្ដីសុខដ៏ទូលាយ គួរប្រយ័ត្នរវាំងមើលកម្មគឺអំពើដែលខ្លួនត្រូវធ្វើនោះឱ្យរឿយៗកុំបីភ្លេចស្មារតីឡើយ ព្រោះថាកម្មនេះជាមេបណ្ដាលហេតុ ឬ ថាជាដើមផ្លូវនៃសេចក្ដីសុខទុក្ខគ្រប់យ៉ាង ។

សេចក្ដីសុខដែលយើងតែងប្រាថ្នាសោតក៏មានច្រើនស្ថាន ដូចសេចក្ដីសុខចំពោះរូបមួយៗ របស់មនុស្សដោយសារមិនមានជំងឺដំកាត់ក្ដី ដោយសារត្រកូលខ្ពង់ខ្ពស់ក្ដី ដោយសារសម្បូរភោគសម្បត្តិក្ដី ឬ ដោយសារប្រាជ្ញាស្មារតីការចេះដឹងក្ដី ទាំងនេះហៅថា សុខតាមចំនែករាល់ៗរូប ។ មួយទៀត សត្វដែលមក

ចាប់កំណើតជាមនុស្សនេះ រាប់ថាជាសុខវិសេស ព្រាន់បើជាងសត្វតិរច្ឆាន ប៉ុន្តែធម្មតា មនុស្សបុថុជ្ជន ដែលធ្លាប់តែរលើបរលាបដោយសេចក្តីសុខ លុះប្រទះបានសេចក្តីសុខប៉ុណ្ណោះហើយ ច្រើនតែត្រេកត្រអាលភ្លេចខ្លួន លង់គំនិតក្នុងអំពើអាក្រក់ផ្សេងៗក៏មាន លង់ទាល់តែប្រែក្លាយធ្លាក់ខ្លួនទៅប្រទះសេចក្តីទុក្ខភ្លាមក៏មាន ។ សេចក្តីសុខដែលប្រកបដោយ អាមិសៈ នៅប្រែប្រួលនេះ លោកពោលថាជា សាមិសសុខ គឺសុខនៅមានគូគ្នានឹងទុក្ខ តែងប្រែក្លាយទៅជាទុក្ខខ្លះសុខខ្លះម្តងៗ មិនទាន់រាប់ថាជាសុខសុទ្ធសួន្យមាំមួននៅឡើយ ។ សូម្បីសុខក្នុងសួគ៌ទេវលោក ដែលជាទិព្វសុខស្តុកស្តម្ភ ដោយអាយុ ពណ៌សម្បុរ ភោគសម្បត្តិ ក៏លោករាប់ថាជាសាមិសសុខដូចគ្នាដែរ ព្រោះនៅវិលត្រឡប់មកកាន់កំណើតរងទុក្ខផ្សេងៗទៀត ប៉ុន្តែសុខក្នុងសួគ៌ទេវលោកនោះ ឃើញថាវិសេសជាងសុខក្នុងមនុស្សលោកនេះ ។ សេចក្តីសុខបើពោលដោយរួបរួមមាន ៣យ៉ាងគឺ សុខក្នុងមនុស្ស១ សុខក្នុងសួគ៌ទេវលោក ១ សុខក្នុងព្រះនិព្វាន ១ សុខពីរយ៉ាងខាងដើមចាត់ចូលក្នុងសាមិសសុខឬកាមសុខ ជាសុខនៅក្នុងចំណោមនៃទុក្ខ គឺជាសុខដែលនៅល្បួងរររ ដោយបរអារម្មណ៍មានរូបារម្មណ៍ជាដើម ដែលជាទីត្រេកអរ ជាទីប្រាថ្នាពេញចិត្តរបស់បុថុជ្ជន តែជាទីខ្ពើមរអើមរបស់អរិយបុគ្គល ។

សុខក្នុងព្រះនិព្វានលោកចាត់ថាជា និរាមិសៈ គឺសុខប្រាសចាកអាមិសៈ មិនលាយច្រឡំដោយទុក្ខ មិនវិបរិតប្រែប្រួលទៀតឡើយ ។ ព្រះនិព្វានឈ្មោះថាឯកន្តសុខ ជាសុខដាច់ចំណោមអំពីទុក្ខ ឬ ហៅថា សន្តិសុខជាសុខស្ងប់ស្ងាត់ចាកអារម្មណ៍ ផុតស្រឡះចាកឧបធិអន្តរាយគ្រប់យ៉ាង ។

ព្រះសម្មាសម្ពុទ្ធកាលនៅជាពោធិសត្វនៅឡើយ ព្រះអង្គបានត្រាច់រង្គាត់

ចាប់កំនើតក្នុងភពតូចធំ បានភប់ប្រសព្វនឹងសេចក្តីសុខគ្រប់អន្លើ ។ បណ្តាសេចក្តីសុខទាំងអស់ ដែលជាប់ទាក់ទាមក្នុងភព សុទ្ធតែជាសុខមានវេនផ្លាស់ប្តូរនឹងទុក្ខទោសផ្សេងៗ សូម្បីសុខក្នុងភពទាំង ៣ គឺកាមភព, រូបភព, អរូបភព ក៏ព្រះអង្គបានចូបប្រទះ បានជ្រាបច្បាស់ទាំងអស់ឥតកំបាំងឡើយ ។ ព្រះអង្គបានពិចារណាលៃលក ស៊ើបដំណឹងចំណាំមើលក្នុងលោកទាំងមូល ដោយប្រាជ្ញដ៏ វិសេសគ្រប់ៗជាតិ នឹងឃើញមានសេចក្តីសុខណាមួយឱ្យប្រសើរវិសេសដល់នូវទីបំផុតទុក្ខ ដូចសុខក្នុងព្រះនិព្វាននោះពុំមានឡើយ ព្រោះហេតុនោះ បានជាព្រះពោធិសត្វខំកសាងបំពេញបារមីធម៌ អស់ច្រើនជាតិដើម្បីលះបង់ចៀសវាងគំនរទុក្ខទោសដែលបន្ទំនៅក្នុងសាមិសសុខ ព្រោះព្រះអង្គបានឃើញច្បាស់នូវសេចក្តីសុខទុក្ខក្នុងភពគ្រប់យ៉ាងហើយ ទ្រង់បែរព្រះហឫទ័យឆ្ពោះទៅរកសន្តិសុខតែម្យ៉ាង ។ ឯផ្លូវដែលធ្វើដំណើរសេចក្តីប្រតិបត្តិ ឱ្យត្រង់លឿនទៅរកសន្តិសុខគឺព្រះនិព្វាននោះ សម្រេចដោយការធ្វើកាយវាចាចិត្តឱ្យបរិសុទ្ធ សម្រេចដោយប្រាជ្ញាចាស់ក្លា។ ពួកសត្វដែលមិនទាន់បានលាងជម្រះមន្ទិលកាយវាចាចិត្តឱ្យស្អាតបរិសុទ្ធមិនបានដល់ទីបំផុតទុក្ខគឺព្រះនិព្វាននោះឡើយ ព្រោះហេតុដូច្នេះ យោគាវចរកុលបុត្រ អ្នកឃើញទោសរបស់កាមគុណ ឃើញអនិសង្សនៃការរលាស់ខ្លួនចេញចាកកាមគុណហើយប្រាថ្នានឹងរើខ្លួនចេញចាកភពប៉ុនប៉ងនឹងឆ្លងកាត់សង្សារវដ្ត ហែលតម្រង់ឆ្ពោះទៅកាន់កោះត្រើយខាងនាយគឺព្រះនិព្វាននោះ លុះតែបានអប់រំខ្លួនធ្វើបារមីធម៌ គឺកុសលឱ្យបានក្រាស់ក្រៃល ដើម្បីរៀបចំសម្រឹតសម្រាំងខ្លួនឱ្យបរិសុទ្ធផុតស្រឡះ ចាកមន្ទិលសៅហ្មងគ្រប់យ៉ាង ទាំងធ្វើបញ្ញាឱ្យបរិបូណ៌ផង ទើបធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានបាន ។ កុសលធម៌ជាគន្លងដ៏ល្អរបស់

លោកអ្នកប្រាជ្ញមានព្រះពុទ្ធជាដើម ដែលលោកតែងប្រព្រឹត្តធ្វើឱ្យល្អិតលាស់ចម្រើនឡើងនោះមានច្រើនប្រភេទនឹងពណ៌នាឱ្យសព្វគ្រប់ពុំបានឡើយ ។ ក្នុងទីនេះសូមសំដែងចំពោះតែវិសុទ្ធិ ដែលជាធម៌មានថ្នាក់តាំងអំពីធម៌ជាន់ទាបឡើងទៅដល់ជាន់ខ្ពស់ រហូតដល់ព្រះនិព្វាន ស្រង់យកតែគោលសេចក្ដីខ្លី១ល្មមជាផ្លូវសិក្សារបស់កុលបុត្រ ក្នុងព្រះពុទ្ធសាសនាតទៅ ។

ពាក្យថា វិសុទ្ធិ ប្រែថា សេចក្ដីបរិសុទ្ធិ ថា ស្អាតវិសេស ឬថាម៉ត់ចត់។ ពួកតាបសឥសីជាន់ពីដើម ខ្លះចូលចិត្តថា ការធ្វើខ្លួនឱ្យបរិសុទ្ធនោះត្រូវប្រព្រឹត្តតបវត្តឱ្យតឹងរ៉ឹងមានចុះត្រាំទឹកក្នុងរដូវដែលកំពុងត្រជាក់រងាជាដើម ក្នុងមួយថ្ងៃ ៣ ដងដើម្បីផ្ដន្ទា ផ្ដាលផ្ដាញ់កិលេសឱ្យ ឃ្លាតចេញចាកខន្ធសន្ដាន ឬ ឈរហាលថ្ងៃ ឬក៏អាំងភ្លើងទើបឈ្មោះថាបានធ្វើខ្លួនឱ្យបរិសុទ្ធ ។ ការចូលចិត្តប្រព្រឹត្តបែបតាបសឥសីដូច្នោះនឹងបានឈ្មោះថា វិសុទ្ធិ ជាឧបាយនាំខ្លួនឱ្យស្អាតម៉ត់ចត់នោះក៏ទេ គ្រាន់តែជាការធ្វើខ្លួនឱ្យហត់នឿយឥតអំពើ ។ ពាក្យថា វិសុទ្ធិ ក្នុងទីនេះសំដៅយកសេចក្ដីប្រតិបត្តិដោយប្រពៃ ជាឧបាយធ្វើកាយវាចាចិត្តឱ្យបរិសុទ្ធរហូតដល់ បានសម្រេច អរហត្តផល-និព្វានជាទីបំផុតទើប ហៅថា វិសុទ្ធិ ។

# វិសុទ្ធិមាន ៧ ប្រការគឺ

១. សីលវិសុទ្ធិ សេចក្តីបរិសុទ្ធ ព្រោះការរក្សាសីល ។

២. ចិត្តវិសុទ្ធិ បរិសុទ្ធព្រោះការទូន្មានចិត្ត ( វិសុទ្ធិ ២ ប្រការ ) នេះ ចាត់ជាមូល គឺជា ឫសគល់ជាទីតាំងនៃវិបស្សនា ។

៣. ទិដ្ឋិវិសុទ្ធិ បរិសុទ្ធព្រោះការឃើញ ( ដោយប្រពៃ )

៤. កង្ខាវិតរណវិសុទ្ធិ បរិសុទ្ធព្រោះការឆ្លងផុតចាកសេចក្តីសង្ស័យ ដែលនាំឱ្យចិត្តស្ទាក់ស្ទើរ ។

៥.មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ បរិសុទ្ធព្រោះការឃើញដែលប្រកប ដោយបញ្ញាជាគ្រឿងដឹងច្បាស់ថា មគ្គនិងមិនមែនមគ្គ ។

៦.បដិបទាញាណទស្សនវិសុទ្ធិ បរិសុទ្ធព្រោះការឃើញដែលប្រកប ដោយបញ្ញាជាគ្រឿងដឹងច្បាស់នូវសេចក្តីប្រតិបត្តិ ( ក្នុងវិបស្សនាញាណទាំង៩ )

៧.ញាណទស្សនវិសុទ្ធិ បរិសុទ្ធព្រោះការឃើញដោយបញ្ញាជាគ្រឿង ដឹងច្បាស់ ( នូវអរិយមគ្គ ) ។

( វិសុទ្ធិទាំង ៥ ប្រការនេះចាត់ជាសរីរៈ គឺជាគ្រោង ឬ ជាតួនៃវិបស្សនា ) ។

លំដាប់នេះសូមអធិប្បាយ ពង្រីកសេចក្តីចំពោះវិសុទ្ធិមួយៗតទៅ

# វិសុទ្ធិទី ១

ការបានដឹងប្រាកដថា ជាសីលមានប្រភេទដូច្នោះៗ គឺកើតឡើងដោយអំណាចនៃព្រះអគ្គមហាបុរសសម្មាសម្ពុទ្ធ ដែលបានត្រាស់ដឹងឡើងក្នុងលោក ព្រះអង្គជាបធានាធិបតីលើពុទ្ធបរិស័ទទាំងមនុស្សនឹងទេវតា ទ្រង់សំដែងសើរើបញ្ញត្តតែងតាំងបើកបង្ហើបធ្វើសីលធម៌ដែលកំបាំងមកយូរហើយ ឱ្យឃើញជាក់ច្បាស់ឱ្យរាក់ងាយយល់ ឱ្យមានបែបទំនងដល់ពួកមនុស្សក្នុងដែននោះៗ , ទ្រង់សំដែងធម៌បញ្ញត្តវិន័យសមតាមចរិតនៃបុគ្គលគ្រប់ពួកឱ្យត្រូវតាមវ័យ ល្មមដល់អធ្យាស្រ័យ សមគួរតាមឧបនិស្ស័យឥតមានទាស់ ។ ព្រះអង្គសំដែងអំពីសីលនិងវត្តចរិយាឯទៀតៗ ឱ្យសមតាមកិច្ចរបស់គ្រហស្ថនិងបព្វជិត ទុកសំរាប់ប្រតិបត្តិកំចាត់ទោសទុច្ចរិតផ្សេងៗ ដែលត្រូវខ្លួនឯង ឬអ្នកផង អាចតិះដៀលបាន ។ សីលនេះសម្រាប់ការពារទោសដែលកើតអំពីកាយវាចា ។ បុគ្គលអ្នកមានសេចក្តីប្រព្រឹត្ត ជឿកាន់ត្រឹមត្រូវតាមត្រណមនៃសិក្ខាបទទាំងនោះឯងហៅថាអ្នកមានសីល ព្រោះបុគ្គលបុរសស្ត្រី អាចមានកាយវាចារៀបរយល្អមិនឱ្យមានការបៀតបៀន មានតែចិត្តមេត្តាករុណា ដល់មនុស្សផងគ្នា និងសត្តនិករ ទូទៅទាំងអស់ក្នុងលោក ។

សីលរមែងកែសំរូលមនុស្ស ក្នុងត្រកូលដែលធ្លាប់មានគំនិតអធ្យាស្រ័យគ្រោតគ្រាត អាក្រក់ ផ្សេងៗគ្នា ឱ្យត្រឡប់ទៅជាត្រកូលមានកិរិយាមារយាទសណ្តាប់ធ្នាប់ល្អ តាមពួកក្រុម គួរជាទីជ្រះថ្លាយកជាតម្រាប់នៃកល្យាណជនទូទៅ ។ បុរសស្ត្រីអ្នកប្រាថ្នានឹងរក្សាសីល ឱ្យបរិសុទ្ធមាំមួននោះ ព្រូវអាស្រ័យ

ការតាំងចិត្តឱ្យធ្ងន់ក្នុងសីលនោះៗ ស្មើនឹងជីវិតរបស់ខ្លួន ដូចពុទ្ធភាសិតថា

បាតិមោក្ខំ វិសោធេន្តោ អប្បេវ ជីវិតំ ជហេ បញ្ញត្តំ

លោកនាថេន ន ភិន្ទេ សីលសំវរំ

សេចក្តីថា បុគ្គលនឹងធ្វើសីលជាប្រធានឱ្យបរិសុទ្ធបាន សូម្បីតែជីវិតក៏ហានលះបង់ មិនត្រូវទំលាយនូវសីលសំវរៈ គឺការសង្រួមក្នុងសីលដែលព្រះលោកនាថទ្រង់បញ្ញត្តទុកនោះឡើយ ។ អ្នកដែលត្រូវការនឹងប្រតិបត្តិធមិជាន់ខ្ពស់ៗឡើងទៅនោះ លុះតែរក្សាសីលតាមថ្នាក់របស់ខ្លួនឱ្យបរិសុទ្ធ បរិបូណ៌ជាមុនសិនទើបអាចចំរើនធមិជាន់ខ្ពស់ឡើងទៅបាន។

សីលនេះជាដើ្មមនៃព្រះពុទ្ធសាសនា ឬថាជាប្រធានរបស់អ្នកកាន់ព្រះពុទ្ធសាសនា ចាត់ជាភូមិភាគនៃកុសលធមិទាំងពួង ជាមេច្បាប់ខាងដើមសម្រាប់សំគាល់របស់មនុស្សឱ្យដឹងថាល្អឬអាក្រក់ ឬទុកដូចសញ្ញាប័ត្រជាគ្រឿងចំណាំឱ្យឃើញប្លែកជាងតិរច្ឆាន ។ មួយទៀត សីលនេះដូចអាវុធ សម្រាប់តទល់នឹងវិតិក្កមទោស គឺកិលេសយ៉ាងគ្រោតគ្រាត ដែលអាចពុះពារសិក្ខាបទធំតូចជាក់ស្តែងបាន ។ បុគ្គលកាលបើបានរក្សាសីលឱ្យបរិសុទ្ធផូរផង់ ហើយឈ្មោះថាមានដើ្មមស្រួលល្អ គឺថាមានមុខឱនឆ្ពោះឈមទៅរកធមិជាន់កណ្តាលជាន់ខ្ពស់ឡើងទៅ ដូចកាំជណ្តើរឡើងទៅកាន់គេហដ្ឋាន ។ មួយទៀត បុគ្គលអ្នកមានសីលអប់រំល្អនោះនឹងបានចៀសវាង ឬ ដកខ្លួនផុតចាកពៀរវេរា និងទោសភ័យគ្រប់យ៉ាង តាំងអំពីលោកនេះដរាបដល់បរលោក។ សីលជាទីប្រជុំចុះនៃកុសលធមិទាំងពួង ដូចផែនដីជាទីអាស្រ័យនៅនៃមនុស្សសត្វ ឈើព្រៃលតាវល្លិផ្សេងៗ ។ ៥០ គ្ន : មិ៥.៩

សីល បើពោលតាមវោហារទេសនា មានច្រើនពួក(១) តែបើទុកជាដូច្នោះ ក៏គង់សង្គ្រោះចូល ក្នុងសីល ៤ ពួកគឺ

១.និច្ចសីល បានដល់សីលប្រាំដែលគ្រហស្ថបុរសស្ត្រីចាស់ក្មេងគួររក្សាជានិច្ច មិនមានកំណត់កាល នឹងកុសលកម្មបថ ១០ ប្រការដែលជាវិន័យសម្រាប់គ្រហស្ថ ។

២.ឧបោសថសីល បានដល់សីលសម្រាប់ឧបាសកឧបាសិកាអ្នកដែលមានចិត្តប្រាថ្នាប៉ុនប៉ងប្រតិបត្តិយ៉ាងឧក្រិដ្ឋ ឆ្លៀតរក្សាតាមកាលដែលគួររក្សា ចំពោះថ្ងៃឧបោសថ ។

៣.អដ្ឋវេកសីល បានដល់សីលសម្រាប់សាមណេរសាមណេរី ឬសម្រាប់គ្រហស្ថជាអនាគាមិបុគ្គលឬក៏សម្រាប់គ្រហស្ថបុថុជ្ជនអ្នកមានសទ្ធាខ្លាំងក្លា ជាសីលខ្ពង់ខ្ពស់លើសជាងនិច្ចសីល-ឧបោសថសីល ជាសីលដ៏ឧក្រិដ្ឋខ្ពង់ខ្ពស់របស់គ្រហស្ថ ។

៤.ចតុប្បារិសុទ្ធិសីល បានដល់សីល៤ មានបាតិមោក្ខសំវរសីលជាដើមសម្រាប់ភិក្ខុ-ភិក្ខុនី ។ បណ្ដាសីលទាំងបួនពួកនេះ កាលបើបុគ្គលស្ម័គ្រចិត្តកាន់សីលជំពូកណា ត្រូវជម្រះសីលនោះ ឱ្យបរិសុទ្ធដោយស្ថាន៣យ៉ាងគឺ

ក- អនាបជ្ជនំ មិនហ៊ានប្រព្រឹត្តល្មើសលើសិក្ខាបទ ឬ ថាប្រយ័ត្នមិនឱ្យកន្លងសិក្ខាបទ .

ខ- អាបន្នវុដ្ឋានំ កាលបើជ្រុលប្រព្រឹត្តកន្លងហើយ ត្រូវសើរើ

(១) ចូរមើលសេចក្ដីពិស្ដារ ក្នុងសីលនិទ្ទេស ។

ទោសនោះចេញគឺថា កាលបើត្រូវអាបត្តិហើយត្រូវប្រញាប់សំដែងចេញចាកអាបត្តិនោះ

គ- កិលេសសេហិ អប្បដិបីឡនំ មិនបណ្ដោយឱ្យកិលេសបៀតបៀនញាំញី.

សីល ដែលបុគ្គលរក្សាឱ្យបរិសុទ្ធ ផុតចាកវីតិក្កមទោស មិនមានធ្លុះធ្លាយ មិនពព្រុះពពាល ល្មមជាបទដ្ឋាន ជាទីតាំងនៃសមថកម្មដ្ឋាននុ៎ះឯងលោកចាត់ថាជា សីលវិសុទ្ធិ ដោយសង្ខេបប៉ុណ្ណោះ ។

## វិសុទ្ធិទី ២

សីល ជាភ្នាក់ងារខាងការសង្កត់សង្កិន នូវវិតិក្កមទោស ដែលជាកិលេសគ្រោតគ្រាត ។ សមាធិ ជាភ្នាក់ងារខាងការសង្កត់សង្កិននូវបរិយុដ្ឋានក្កិលេស គឺជាកិលេស ចោមរោមរឹតរួតចិត្តឱ្យនៅទាក់ទាមក្នុងនីវរណធម៌ដែលជាកិលេសយ៉ាងកណ្ដាល ។ ព្រោះហេតុនោះយោគាវចរកុលបុត្រ កាលបើបានរក្សាសីលល្អហើយ គួរចំរើនសមាធិ អប់រំធ្វើចិត្ត ឱ្យបរិសុទ្ធផុតចាកកិលេសនោះតទៅទៀត ។

ក្នុងអធិការនៃចិត្តវិសុទ្ធិនេះមានន័យយ៉ាងល្អិតជ្រាលជ្រៅច្រើនស្ថាន(១) តែឥឡូវនេះ សូមលើកឡើងតាំងជាឧទ្ទេស សម្រាប់ជាគោលនៃពាក្យអធិប្បាយត្រឹមតែ២យ៉ាងគឺ **ចិត្តានុបរិវត្តិ** (ដំណើរប្រព្រឹត្តិទៅរឿយៗនៃចិត្ត)១ **ចិត្តបរិហារ** (ឧបាយសម្រាប់រក្សា ឬទូន្មានចិត្ត) ១ ។

(១) ចូរមើលក្នុងសមាធិនិទ្ទេសផងចុះ ។

# សំដែងអំពីចិត្តានុបរិវត្តិ

បណ្តាពួកសត្វលោកទាំងអស់ក្នុងភពនេះ មិនមានសត្វពួកណាប្រសើរជាងមនុស្ស បណ្តាគ្រោងកាយទាំងមូលរបស់មនុស្ស ក៏មិនមានធម្មជាតិអ្វីមួយប្រសើរជាងចិត្តឡើយ ឃើញតែចិត្តមួយជាប្រធានលើអវយវៈទាំងមូល អាចត្រួតត្រាគ្រប់ទ្វារទាំងអស់ ដូចអវយវៈដែលឈានលូកទៅចាប់ធ្វើការអ្វីៗក៏មកអំពីចិត្តជាអ្នកបង្គាប់ឱ្យធ្វើឱ្យនិយាយ កាលបើចិត្តអាក្រក់រមែងបង្គាប់កាយវាចាឱ្យធ្វើអាក្រក់ ឱ្យនិយាយអាក្រក់ កាលបើចិត្តល្អ ក៏បង្គាប់ឱ្យធ្វើល្អ ឱ្យនិយាយល្អ។ អំពើរបស់បុណ្យបាបគុណទោសសម្រេចមកអំពីចិត្តជាដើមហេតុ ។ ចិត្តនេះជានាមធម៌មួយឥតខ្លួនប្រាណពពិសពណ៌នយ៉ាងណាទេ ប៉ុន្តែអាចដឹងច្បាស់នូវអារម្មណ៍ផ្សេងៗបានយ៉ាងវិសេស ។ ចិត្តនេះលំបាករក្សាបំផុតជាងរបស់អ្វីៗទាំងអស់ ព្រោះថា ចិត្តនេះមានកលមាយាចេញតាមទ្វារទាំង៦ទៅជាអាការច្រើនយ៉ាង ។

ក្នុងទីនេះ សូមពោលដោយសរុបអាការរបស់ចិត្ត ៤ យ៉ាងគឺ ចិត្តនេះតែងត្រាច់រង្គាត់រវេរវាមរកអារម្មណ៍ដែលមិនធ្លាប់មាន ឬ អារម្មណ៍ដែលនៅក្នុងកាលខាងមុខៗនោះ១ ចិត្តនេះតែងអន្ទះសាអន្ទ្រាស្ទុះទៅមកជានិច្ចមិនចេះនៅស្ងៀម ទាំងដំណើរដែលស្ទុះទៅមកនោះ ក៏ទៅតែមួយដួងៗលឿនរហ័សក្រៃលែងគ្មានអ្វីប្រៀបបាន១ ចិត្តដែលរវេរវាមស្វែងរកអារម្មណ៍ក្នុងទិសផ្សេងៗនោះក៏មិនប្រាកដ ដល់មំសចក្ខុរបស់ខ្លួនឬអ្នកដទៃ១ ចិត្តតែងជ្រកកោនអាស្រ័យនៅក្នុងគុហា គឺមហាភូតរូប១ ។ ចិត្តជាធម្មជាតល្អិតក្រៃលែងហួស

វិស័យនឹងឃើញបាន ទាំងទូន្មានរក្សាឱ្យតាំងនៅជាប្រក្រតីក៏ក្រណាស់ លុះតែបុគ្គលអ្នកមានប្រាជ្ញា ទើបរក្សាចិត្តឱ្យឋិតនៅល្អបាន សមដូចពុទ្ធភាសិតក្នុងខុទ្ទកនិកាយធម្មបទថា

សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ

ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។

សេចក្ដីថា អ្នកប្រាជ្ញតែងរក្សាចិត្តដែលកម្រនឹងឃើញបានដោយងាយ ដែលជាធម្មជាតល្អិតក្រៃពេក តែងធ្លាក់ទៅក្នុងអារម្មណ៍ជាទីប្រាថ្នា (តែបើ)ចិត្តដែលគេគ្រប់គ្រងបានហើយ រមែងនាំសុខមកឱ្យ ។

ចិត្តកាលដែលកើតឡើង ក៏រហ័ស រលត់ស្ងប់ទៅវិញ ក៏រហ័ស នឹងស្ទុះទៅស្ទាបអង្អែលអារម្មណ៍ក៏ស្ទុះទៅមិនដឹងប្រមាណកាលវេលា ។ ចិត្តនេះជាធម្មជាតសម្រាប់គិត សម្រាប់សន្សំអារម្មណ៍ជាចម្បងលើរូបធម៌ នឹងអរូបធម៌ទាំងអស់ ។ បណ្ដាធម្មជាតដែលសម្រាប់ដឹងច្បាស់នូវអារម្មណ៍ មានតែចិត្តមួយនេះឯងជាធំជាងនាមឯទៀត១ គឺថាចិត្តនេះ ជាមេនាំមុខបើកឱកាសដល់នាមធម៌ដទៃ ។ ចិត្តនេះជាមូលហេតុនៃសេចក្ដីត្រិះរិះគ្រប់យ៉ាង ចួនកាលលោកប្រើជាអាការន្តឥត្ថីលិង្គ ហៅថា **ចិន្តា** ប្រែថាធម្មជាតិសម្រាប់សន្សំអារម្មណ៍ដូចគ្នានឹងចិត្តដែរ ។

## ចិន្តា នេះចែកចេញជា ៣ យ៉ាងគឺ

**១ ឧហានចិន្តា** គំនិតដែលអណ្ដែតចេញ ឬហើបឡើងអំពីហទយវត្ថុក្នុងខណៈជាដំបូងបង្អស់លោកសំដៅយកវិតក្កៈគឺសេចក្ដីត្រិះរិះផ្ដងឡើង

**២ វិជាននចិន្តា** លុះនឹកថ្កងមុនស៊ប់ស្រេចហើយ ខណៈអំពីនោះក៏មានគំនិតមួយបន្ទាប់មក នាំឱ្យដឹងវិសេសជាងនោះតមក មួយខណៈឡើងទៀត លោកសំដៅយកវិញ្ញាណ សេចក្តីដឹងប្លែកបន្តិចតមក

**៣ បជាននចិន្តា** បន្ទាប់មកទៀត ក៏មានគំនិតខ្ពស់លេចឡើងភ្លឺច្បាស់ជាបច្ច័យនាំឱ្យដឹងជាក់ប្រាកដជាងចិន្តាខាងដើម លោកសំដៅយកបញ្ញា សេចក្តីដឹងច្បាស់ ។ ចិន្តានេះតែងមានធុរៈត្រិះរិះ ស្រាវជ្រាវ វិលវល់មិនដាច់ គឺថាចេះមានគំណនៃសេចក្តីគិតជាប់ត១គ្នាដូចកង់រទេះ ។

ក្នុងគ្រោងកាយរបស់មនុស្ស សុទ្ធតែមានចិន្តា៣យ៉ាងនេះជាធម្មតា ប៉ុន្តែពួកមនុស្សសាមញ្ញ ដែលមិនធ្លាប់បានសិក្សារៀនសូត្រ មិនធ្លាប់បានចំរើនអប់រំសន្តានក្នុងអរិយធម៌ មានប្រាកដតែត្រឹមចិន្តា២យ៉ាង ខាងដើមប៉ុណ្ណោះ មិនអាចជាប់តមក ក្នុងបជាននចិន្តាឡើយ លុះតែបុគ្គលអ្នកធ្លាប់គប់រកការសិក្សាល្អទើបមានចិន្តាគ្រប់ទាំង៣យ៉ាងដូចពោលមកនេះ ។

## សេវនប្បច្ច័យ របស់ចិត្ត

ធម្មតាចិត្តដែលរយាលអំពីការសេពគប់បណ្ឌិត , រយាលអំពីការសិក្សា តែងឃ្លេងឃ្លោង ញាប់ញ័រ ត្រឡប់ទៅជាខូចខុសគន្លងធម៌ក៏មាន , រវើរវាយបម្រាសនទៀលទៅរកអារម្មណ៍ផ្សេង១ ខុសទំនងក៏មាន ។ ចិត្តដែលមិនមានធម៌ជាទីពំនាក់ទេ តែងអន្ទះសាជានិច្ច ឥតស្រាកស្រាន្ត ។ ចិត្តនេះលោកប្រៀបថាមានអាការដូចផ្លែត្រឡាចដែលគេដាក់លើខ្នងសេះ ឬដូចបង្គោលដែលគេបោះក្នុងគំនរអង្កាម ឬក៏ដូចផ្កាក្ដម្ព ដែលដាក់លើក្បាលថ្ពែក ពុំនោះដូចអាការ របស់សត្វស្វា ឬកូនក្មេងតូចកំពុងរពឹស ។

ចិត្តដែលនៅទំនេរ មិនមានសេវនប្បច្ច័យ គឺការសេពគប់ល្អចំពោះបុគ្គល ឬការសិក្សាជាទីពឹងទេ តែងអន្ទះអន្ទែងទៅផ្សេងៗ ចូនកាលប្រែក្លាយទៅជាមិច្ឆាទិដ្ឋិក៏មាន ទៅជាចិត្តប្រាសចាកសទ្ធាបញ្ញាក៏មាន ។ ការប្រព្រឹត្តិទៅនៃចិត្តនេះ តែងប្រែប្រួលទៅជាច្រើនយ៉ាង

មួយទៀត នីវរណៈ ៥ យ៉ាង ជាកិលេសខាងក្នុងដូចជាសត្រូវក្នុងផ្ទះទៅដឹកនាំ ទៅប្រមូលយកសឹកសត្រូវ ឬមន្ទិលសៅហ្មងផ្សេងៗពីខាងក្រៅមកញុះញង់ ធ្វើឱ្យចិត្តរាយមាយខូចខុសប្រក្រតី ។ ចិត្តនេះកាលដំបូងដែលមិនទាន់មានឧបក្កិលេសបាបធម៌ចូលមកលុកលុយទេ ជាចិត្តថ្លាស្អាតផូរផង់ ដូចមានព្រះពុទ្ធដីកាថា បភស្សរមិទំ ភិក្ខវេ ចិត្តំ ចិត្តសង្កិលេសា ភិក្ខវេ សត្តា សង្កិលិស្សន្តិ ចិត្តវោទានា ភិក្ខវេ សត្តា វិសុជ្ឈន្តិ សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ចិត្តនេះ មានរស្មីផ្សាយចេញល្អណាស់ ( ប៉ុន្តែដែលទៅជាសៅហ្មងនោះ ព្រោះឧបក្កិលេសចូលមកថ្មី ) ម្នាលភិក្ខុទាំងឡាយ ព្រោះចិត្តសៅហ្មង សត្វទាំងឡាយក៏រមែងសៅហ្មង ព្រោះចិត្តផូរផង់បរិសុទ្ធ សត្វទាំងឡាយក៏រមែងបរិសុទ្ធទៅតាម ។ ព្រះពុទ្ធដីកានេះ បំភ្លឺសេចក្តីឱ្យឃើញថា ពួកសត្វទាំងអស់រមែងសៅហ្មងឬបរិសុទ្ធ ព្រោះចិត្ត ដែលបានទទួលទុក្ខទោសផ្សេងៗ ឬសុខសប្បាយដោយសម្បត្តិ យសបរិវារ ក៏បណ្តាលមកអំពីចិត្តតែម្យ៉ាង បើចិត្តធ្លាប់សន្សំ ឬប្រព្រឹត្តទៅយ៉ាងណា ក៏ប្រដៅកាយវាចាឱ្យចេញមកយ៉ាងនោះដោយពិត ។ ចិត្តនេះឯងតែងជ្រកនៅក្នុងមហាភូតរូប ឬថាមានមហាភូតរូប ជាទីនៅអាស្រ័យ ដូចផ្ទះជាទីលំនៅនៃមនុស្ស . ផ្ទះដែលល្អអាក្រក់ដាច់ធ្លុះធ្លាយ ក៏សម្រេចមកអំពីមនុស្ស ដូចរូបកាយដែលបានទទួល ទុក្ខ សុខ

ក៏សម្រេចមកអំពីចិត្តដូច្នោះដែរ ។

មួយទៀត រូបកាយនេះប្រៀបដូចទូក ចិត្តដូចម្ចាស់ទូក . បើម្ចាស់ទូកចេះច្បាប់ដើរទូកស្ទាត់ ក៏នាំទូកចេញចូលបានដោយស្រួល ឥតមានប្រទះគ្រោះថ្នាក់. បើម្ចាស់ទូកមិនចេះច្បាប់ទូកដើរស្ទាត់ ឬជាបនុស្សអ្នកធ្វេសប្រហែសច្រើន ក៏មុខជានឹងនាំទូកចេញទៅប្រទះគ្រោះថ្នាក់លិចលង់ខ្លួនឯងទៅក្នុងទឹក ឬបុកទង្គិចទូកគេ នាំបណ្ដាលឱ្យខាតប្រយោជន៍ទៅមិនខាន ។ ចិត្តនេះជាប្រធានលើកាយ កាលបើបុគ្គលបានបង្ហាត់ស្ទាត់ល្អហើយ ក៏នាំកាយឱ្យបានសុខស្រួលល្អឱ្យចម្រើនប្រយោជន៍ តាំងអំពីលោកនេះ ដរាបដល់បរលោក. បើមិនបានបង្ហាត់ចិត្តឱ្យថ្នឹកល្អទេ នឹងនាំកាយឱ្យលិចលង់ទៅក្នុងទន្លេឬសមុទ្រ គឺសេចក្ដីទុក្ខភ័យលំបាកក្រៃលែងពុំខាន ។

## អាហាររបស់ចិត្ត

ចិត្តរបស់បុថុជ្ជន តែងស្រេកឃ្លានអាហារ គឺអកុសលធម៌ទាំងពួងជាធម្មតា . បណ្ដាពួកបាបអកុសលធម៌ទាំងអស់មាននីវរណៈជាដើម ជាអាហាររបស់ចិត្តខាងអាក្រក់ ចំណែកខាងកុសលធម៌ មានបុញ្ញកិរិយាវត្ថុ៣យ៉ាង និងសតិប្បដ្ឋាន ៤ ជាដើម ជាអាហាររបស់ចិត្តខាងល្អ ដូចគ្នានិងភោជនាហារសម្រាប់រូបកាយ ។ មនុស្សដែលមានចរិតអធ្យាស្រ័យខ្ជីខ្ជា ឬជាមនុស្សក្រីក្រ តាក់តែងអាហារសម្រាប់បរិភោគ មិនសូវស្អាតល្អទេ ច្រើនតែប្រើអាហារថោកទាបតាមតែប្រទះ ។ ចំណែកខាងមនុស្សដែលសំបូណ៌ទ្រព្យសម្បត្តិ ឬមានចរិតអធ្យាស្រ័យខ្ពង់ខ្ពស់ផង តាក់តែងអាហារក៏ស្អាតល្អថ្លៃថ្លា ។ អាហារសម្រាប់

រូបកាយយ៉ាងណា អាហារសម្រាប់ចិត្ត ក៏ប្រហែលគ្នាយ៉ាងនោះដែរ គឺថាបើអាហារអាក្រក់មានបាយឆៅជាដើម តែងឱ្យទុក្ខដល់រាងកាយ ធ្វើឱ្យហើមពោះចុះរាគថយកម្លាំងទៅវិញ ។ អាហារល្អថ្លៃថ្លា តែងជួយបំប៉នកាយ ឱ្យសុខស្រួលឱ្យមានកម្លាំងឡើង ចំណែកចិត្តរបស់អន្ធបុថុជ្ជន ច្រើនតែស្រេកឃ្លានញ៉ាំមក្នុងអាហារដ៏គ្រោតគ្រាត គឺនីវរណៈ៥ជាដើម មិនសូវជ្រើសរើស ។ ចិត្តរបស់កល្យាណបុថុជ្ជន តែងជ្រើសរើសរកអាហារល្អដ៏ថ្លៃថ្លាគឺសមថកម្មដ្ឋាន។ ចិត្តកាលបើត្រូវការក្រេបផឹក ចំពោះតែអាហារដ៏លាមកគឺ នីវរណៈ ក៏រមែងឱ្យទុក្ខទោស ជាយូរអង្វែងជាតិ គ្មានទីបំផុតឡើយ . បើចិត្តត្រូវការទទួលបរិភោគអាហារដ៏ថ្លៃថ្លា គឺកុសលធម៌ផ្សេងៗ គង់នឹងមានទីបំផុតទុក្ខ ដល់នូវសេចក្ដីសុខក្សេមក្សាន្ត គឺព្រះនិព្វានពុំខាន ។

សត្វទាំងឡាយដែលជាប់ចំពាក់ វិលវល់នៅក្នុងលោក ទទួលរងទុក្ខភ័យសង្រេងសង្រៃ ព្រោះការកើតចាស់ឈឺចាប់ស្លាប់ បាត់ព្រាត់ប្រាស់និរាស ទាំងនេះមិនមែនមកអំពីហេតុខាងក្រៅណាមួយឡើយ គឺមកតែអំពីបច្ចនីកធម៌ គឺធម៌ជាសឹកសត្រូវខាងក្នុងសន្ដាន បានដល់ នីវរណូបក្កិលេស នោះឯង ។ កិលេសដែលរារាំងបិទបាំងបញ្ញារបស់សត្វ ធ្វើបញ្ញាឱ្យខ្សោយកម្លាំង ឬធ្វើចិត្តឱ្យងងឹតជ្រប់វង្វេងនៅក្នុងសង្សារវដ្ដ ឱ្យអាល័យជាប់ចំពាក់នៅក្នុងភព មិនឱ្យនឿយណាយធុញទ្រាន់នឹងការកើតចាស់ឈឺស្លាប់ មិនឱ្យឃើញច្បាស់នូវ អរិយសច្ច មគ្គ ផលនិព្វាន ហៅថា នីវរណៈ ។

នីវរណៈមាន ៥យ៉ាង ដូចសេចក្ដីវែកញែកតទៅ

ទី១. កាមច្ឆន្ទៈ សេចក្ដី ត្រេកត្រអាល ដោយអំណាច

កិលេសកាម ៦ យ៉ាង គឺ

១/ រាគៈ សេចក្តីត្រេកអរក្នុងអារម្មណ៍

២/ លោភៈ សេចក្តីជាប់ចំពាក់ក្នុងអារម្មណ៍

៣/ ឥច្ឆា សេចក្តីប្រាថ្នាមិនចេះឆ្អែត

៤/ ឥស្សា សេចក្តីច្រណែនឈ្នានិះនឹងគេ

៥/ អរតិ សេចក្តីមិនត្រេកអរក្នុងកុសល

៦/ អសន្តុដ្ឋិ សេចក្តីមិនសន្តោសតាមមាន តាមបាន ។

កិលេសកាមដែលក្សៀវក្លាឡើង ព្រោះអាស្រ័យវត្ថុកាមខាងក្រៅមានរូបជាដើម ។ កិលេសទាំងនេះ កាលបើពុះពារខ្លាំងក្នុងសន្តានចិត្តនៃបុគ្គលណា រមែងធ្វើដួងចិត្តនៃបុគ្គលនោះ ឱ្យងងឹតសូន្យសុង មិនឱ្យយល់ឃើញគុណទោសខុសត្រូវដោយច្បាស់លាស់ ដូចទឹកដែលលាយច្រឡំដោយពណ៌ផ្សេងៗ មិនអាចឆ្លុះមើលស្រមោលបាន ។ កាមច្ឆន្ទៈនេះកើតមកអំពីសុភនិមិត្ត គឺកំណត់សំគាល់ថាល្អ ។

ទី២. ព្យាបាទៈ សេចក្តីខឹងគ្នាន់គ្នាញ់ប្រទូស្តតបតចំពោះអារម្មណ៍ដែលមិនជាទីប្រាថ្នា មិនជាទីពេញចិត្តជាធម្មតា ។ កិលេសនេះកាលបើកើតឡើងក្នុងសន្តានចិត្តនៃបុគ្គលណា រមែងធ្វើដួងចិត្តនៃបុគ្គលនោះ ឱ្យក្តៅអន្ទះអន្ទែង សំដែងអាការញាប់ញ័រច្រឡោតលោតឡើងខុសប្រក្រតីជាហេតុឱ្យចងគំនុំនឹងសត្វសង្ខារនោះៗ បំបាំងបញ្ញាមិនឱ្យយល់ឃើញគុណទោស ដូចទឹកកំពុងពុះមិនអាចមើលស្រមោលបាន ។ ព្យាបាទៈនេះកើតមកអំពីបដិឃៈ គឺសេចក្តីថ្នាំងថ្នាក់ចិត្តប្ទាស់ទែងចំពោះសត្វសង្ខារនោះៗ ។

ទី៣. ថីនមិទ្ធៈ សេចក្ដីរួញរាធុញថប់ ឬច្រអូសកាយច្រអូសចិត្ត ។ កិលេសនេះ កាលបើកើតឡើងក្នុងសន្ដានចិត្តនៃបុគ្គលណា រមែងធ្វើដួងចិត្តបុគ្គលនោះឱ្យងេងងោងសុបសៅ ធ្វើអាការដូចជាធុញទ្រាន់ស្រពោនពណ៌សម្បុរសំដែងចេញអវយវៈគឺ ដៃ ជើង ដែលលូតចេញទៅ ឬបត់ចូលមកយឺត១ ភ្លឺះ១ ធ្វើបញ្ញាមិនឱ្យភ្លឺស្វាង ឆាប់យល់កិច្ចការអ្វី១បានឡើយ ដូចទឹកដែលមានសារាយ ឬចកបិទបាំង មិនអាចឆ្លុះមើលស្រមោលបាន ។ ថីនមិទ្ធៈ នេះកើតមកអំពីអរតិ គឺសេចក្ដីមិនត្រេកអរ មិនចូលចិត្តចំពោះកិច្ចការនោះ១ ។

ទី៤. ឧទ្ធច្ចកុក្កុច្ចៈ សេចក្ដីរាយមាយអណ្ដែតអណ្ដូងក្ដៅក្រហាយទៅក្នុងអំពើរអាក្រក់ដែលធ្លាប់ធ្វើមក ឬក៏រាយមាយចិត្តទៅក្នុងអារម្មណ៍ផ្សេង១ ដែលមិនជាប្រយោជន៍ ។ កិលេស កាលបើកើតឡើងក្នុងសន្ដានចិត្តនៃបុគ្គលណា រមែងធ្វើចិត្តបុគ្គលនោះឱ្យរវើរវាយអណ្ដែតឡើងចុះជានិច្ច ដូចទឹកដែលខ្យល់បក់រលកអង្កាញ់១ មិនអាចឆ្លុះមើលស្រមោលបាន ។ ឱទ្ធច្ចកុក្កុច្ចៈ នេះកើតមកអំពីចេតសោអវូបសមៈ គឺសេចក្ដីមិនស្ងប់រម្ងាប់ចិត្ត ។

ទី៥. វិចិកិច្ឆា សេចក្ដីសង្ស័យ ស្ទាក់ស្ទើរ ងឿងឆ្ងល់ អល់អែកអង្អឹអង្អៃ ។ កិលេសសនេះ កាលបើកើតឡើងក្នុងសន្ដានចិត្តនៃបុគ្គលណា រមែងធ្វើដួងចិត្តបុគ្គលនោះឱ្យរារែក ឱ្យសន្ទិះ មិនឱ្យដាច់ស្រេច មិនឱ្យចុះសម្រុងមូលទៅខាងណា១បានឡើយ ប្រៀបដូចទឹកដែលមានកករល្អក់ខាប់មិនអាចឆ្លុះមើលស្រមោលបាន ។ វិចិកិច្ឆា នេះកើតមកអំពីអយោនិសោមនសិការៈ គឺសេចក្ដីមិនបានកំណត់ទុកក្នុងចិត្តដោយឧបាយ ។

នីវរណៈទាំង ៥ យ៉ាងដូចពោលមកនេះ ជាមនោគោចរ ឬជាចិត្តាមិសៈ គឺជាអារម្មណ៍របស់ចិត្ត ឬជាអាហារចំណើរបស់ចិត្តនៃបុថុជ្ជន ។

មួយទៀត ចិត្តរបស់សត្វតែងព្រាច់រង្គាត់ប្រព្រឹត្តទៅរឿយៗ មិនដាច់ចាកភពទាំង៣ តែងអន្ទោលយកកំណើត មិនមានទីបំផុត ក៏ព្រោះមានផ្លូវគឺនីវរណៈទាំង ៥យ៉ាងនេះ ឯង ។

ចប់ ចិត្តានុបរិវត្តិប៉ុណ្ណោះ ។

## សំដែងអំពីចិត្តបរិហារ

ច្បាប់ផ្ទាក់កណ្តាលនៃពុទ្ធសាសនា សម្រាប់បង្ខាត់ទូន្មានចិត្ត តម្រង់ចិត្តឱ្យត្រង់មិនឱ្យចិត្តវង្វេង ភ័ន្តភាំង ទៅតាមតន្លង នីវរណៈ ឬធ្វើចិត្តឱ្យស្អាតបរិសុទ្ធផុតចាកនីវរណៈនោះឯង ហៅថា សមាធិ ប្រែថា ការតំកល់ចិត្តទុកដោយល្អ ឬថា ធម៌សម្រាប់ប្រមូលដួងចិត្តទុកឱ្យស្មើល្អ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ប្រមានព្រះធម្មទេសនា ដើម្បីជាឧបាយជម្រះចិត្តឱ្យស្អាតចាកនីវរណៈ មានប្រភេទផ្សេងៗ ។ ព្រះសង្គីតិកាចារ្យ បានចាត់រូបរួមធម៌ទុកជាពួកៗ ហៅថា កម្មដ្ឋាន មានពួកផ្សេងៗគ្នា សម្រាប់តម្រូវដល់ចរិតរបស់សត្វ សំរាប់ប្រឆាំងតទល់នូវសឹកសត្រូវគឺនីវរណៈទាំងនោះ ។ កម្មដ្ឋាននោះដោយសង្ខេបមានពីរយ៉ាងគឺ សមថកម្មដ្ឋាន ១ វិបស្សនាកម្មដ្ឋាន ១ ។

វិធីដែលជាប់ដោយបរិកម្ម គឺប្រើខាងផ្លូវចិត្ត ធ្វើឱ្យចិត្ត កួចកាន់យក

កសិណ ឬអសុភជាដើម ដែលជាចំណាងរបស់ចិត្ត សម្រាប់ឱ្យសំឡឹងឱ្យនឹករឿយៗ ដើម្បីឱ្យចិត្តស្ងប់រម្ងាប់ ឱ្យតាំងនៅនឹងធឹង មានគោលអារម្មណ៍តែមួយៗ មិនឱ្យចិត្តគេចបែរវៀចវេរទៅរកអារម្មណ៍ឯទៀតៗ ហៅថា សមថកម្មដ្ឋាន ។ កម្មដ្ឋាននេះចែកជា៧ពួកគឺ កសិណ១០ ជាពួក១ អសុភ១០ ជាពួក១ អនុស្សតិ១០ ជាពួក១ ព្រហ្មវិហារ៤ ជាពួក១ អរូបជ្ឈាន៤ ជាពួក១ អាហារេបដិកូលសញ្ញា ជាពួក១ ចតុធាតុវវដ្ឋាន ជាពួក១ គ្រប់ជា៧ពួក ។ បើចែកដោយពិស្តារមាន៤០ប្រភេទ(១) ។ កម្មដ្ឋានទាំងនេះ សុទ្ធតែជាឧបាយសម្រាប់ជម្រះចិត្តឱ្យបរិសុទ្ធ ដូចភេសជ្ជៈសម្រាប់កែរោគ ជាប្រយោជន៍ដល់រោគដែលកើតអំពីសមុដ្ឋានផ្សេងៗ ។ រោគដែលកើតអំពីរូបកាយមានច្រើនបែប ភេសជ្ជៈក៏ត្រូវមានច្រើនបែបសម្រាប់តម្រូវដល់រោគនោះៗ ។ សេចក្ដីនេះឧបមាយ៉ាងណាមិញ , កម្មដ្ឋានដែលមានប្រភេទច្រើនយ៉ាងនោះ សំដៅចំពោះតែការជម្រះចិត្ត ឱ្យជាសះស្បើយចាករោគ គឺ នីវរណូបក្កិលេស ផ្សេងៗក៏មានឧបមេយ្យដូច្នោះដែរ ។

វិធីដែលជាប់ដោយ ញាណទស្សនៈ គឺការដឹងច្បាស់ ឃើញច្បាស់ថា "សង្ខារទាំងពួង តែងធ្លាក់ទៅក្នុងសាមញ្ញលក្ខណៈជាដើម" ហៅថា វិបស្សនាកម្មដ្ឋាន ។ ឥឡូវនេះ សូមសំដែងចំពោះសមថកម្មដ្ឋាន ជាវិធីសំរាប់ធ្វើចិត្តឱ្យស្ងប់រម្ងាប់ដោយសង្ខេបជាមុន ដូចតទៅ :

បុគ្គលដែលមានចិត្តក្រាស់ដោយ កាមច្ឆន្ទៈ គប្បីចំរើន អសុភ ឬ កាយ

*(១) ចូរមើលសេចក្ដីពិស្តារក្នុងសមាធិនិទ្ទេសផងចុះ ។*

តគាសតិ ។ ចិត្តដែលក្រាស់ដោយព្យាបាទ គប្បីចំរើនព្រហ្មវិហារ ។ ចិត្តដែលក្រាស់ដោយថីនមិទ្ធៈ គប្បីចំរើនអនុស្សតិ ។ ចិត្តដែលក្រាស់ដោយឧទ្ធច្ចកុក្កុច្ចៈ គប្បីចំរើនមរណានុស្សតិ ឬ កសិណ ។ ចិត្តដែលក្រាស់ដោយវិចិកិច្ឆា គប្បីចំរើនចតុធាតុវវដ្ឋាន ។ ការចំរើនកម្មដ្ឋាន ត្រូវចំរើនឱ្យសមគួរដល់ចរិតរបស់ខ្លួនឯង ។ ក្នុងមេឃិយវគ្គបឋមសូត្រ គម្ពីរខុទ្ទកនិកាយ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា ចេតោវិមុត្តិ(១) ចាស់ក្លាផូរផង់ឡើងបាននោះ ត្រូវអាស្រ័យការឋិតនៅក្នុងបុគ្គលិកលក្ខណៈ ៥ យ៉ាងគឺ

១. កល្យាណមិត្តោ ជាអ្នកមានកល្យាណមិត្ត គ្មានបាបមិត្ត

២. សីលវា មានសីលបរិសុទ្ធតាមលក្ខណៈរបស់សីល ដែលខ្លួនរក្សាទោះបីសីលប្រភេទណាមួយ

៣. អភិសល្លេខិកា កថា មានវាចាដ៏ផូរផង់ប្រកបដោយកថាវត្ថុ១០ យ៉ាង មានអប្បិច្ឆកថា ជាដើម

៤. អារទ្ធវិរិយោ មានព្យាយាមផ្គងឡើងជានិច្ច ក្នុងការលះបង់បាបអកុសល និងការចំរើនកុសល

៥. បញ្ញវា មានប្រាជ្ញាឈ្លាសវៃក្នុងការពិចារណាខន្ធទាំង៥ តាមសភាវៈដែល កើតនិងរលត់ ។

បុគ្គលកាលបើបានឋិតនៅស៊ប់ ក្នុងលក្ខណៈ ៥ យ៉ាងនេះហើយត្រូវចំរើនធម៌ ៤ យ៉ាង ជាគោលគំនិតតទៅទៀត ។

*(១)ការផុតស្រឡះចាកនីវរណធម៌កិលេស ដោយអំណាចសមថកម្មដ្ឋាន ។*

ធម៌ ៤ យ៉ាងដែលត្រូវចំរើននោះគឺ

១.អសុភា ភាវេតព្វា រាគស្ស បហានាយ បុគ្គលគប្បីចំរើន អសុភ ដើម្បីលះរាគៈ ។

២.មេត្តា ភាវេតព្វា ព្យាបាទស្ស បហានាយ គប្បីចំរើនមេត្តា ដើម្បីលះ ព្យាបាទ ។

៣. អានាបានស្សតិ ភាវេតព្វា វិតក្កុបច្ឆេទាយ គប្បីចំរើន អានាបានស្សតិ ដើម្បីផ្តាច់បង់ នូវវិតក្កៈ ៣យ៉ាងមានកាមវិតក្កៈជាដើម

៤. អនិច្ចសញ្ញា ភាវេតព្វា អស្មិមានសមុគ្ឃាតាយ ចំរើនអនិច្ចសញ្ញា ដើម្បីដកនូវ អស្មិមានៈ(សេចក្តីប្រកាន់មាំ) ចេញ ។

មួយទៀត បុគ្គលគួរប្រយ័ត្នចិត្តក្នុងស្ថាន ៤ យ៉ាងគឺ

១/ ប្រយ័ត្នចិត្ត មិនឱ្យត្រេកអរ ក្នុងអារម្មណ៍ជាទីតាំងនៃសេចក្តីត្រេកអរ

២/ ប្រយ័ត្នចិត្ត មិនឱ្យក្រេវក្រោធ ក្នុងអារម្មណ៍ជាទីតាំងនៃសេចក្តីក្រេវក្រោធ

៣/ ប្រយ័ត្នចិត្ត មិនឱ្យវង្វេងភ្លេចខ្លួន ក្នុងអារម្មណ៍ជាទីតាំងនៃសេចក្តីវង្វេង

៤/ ប្រយ័ត្នចិត្ត មិនឱ្យស្រវឹងជ្រុលជ្រប់ទៅក្នុងអារម្មណ៍ជាទីតាំងនៃសេចក្តីស្រវឹង ជ្រុលជ្រប់ ។

បុគ្គលអ្នកមានបំណង នឹងរក្សាចិត្តឱ្យឋិតនៅល្អ គួររវាំងចិត្តក្នុងទី៤ យ៉ាង ដូចបានពោលមកនោះចុះ ។

ន័យមួយទៀតថា អាការសង្រួម ចិត្តនេះមាន៣យ៉ាង គឺ

១. ឥន្ទ្រិយសំវរោ សង្រួមឥន្ទ្រិយទាំង ៦ គឺចក្ខុ , សោត , ឃាន,ជិវ្ហា, កាយ , មនៈ ។ កាលបើចក្ខុជួបប្រទះនឹងរូប រមែងកើតសេចក្តីដឹងឡើង ហៅថា ចក្ខុវិញ្ញាណ បើរូបនោះជាទីប្រាថ្នាជាទីត្រេកអរ ក៏កើតសោមនស្ស , បើរូបមិនជាទីប្រាថ្នា មិនជាទីត្រេកអរ ក៏កើតទោមនស្សជាធម្មតា ។ ដែលហៅថាសង្រួមនោះគឺរាំងចិត្តមិនឱ្យកើត សោមនស្ស ទោមនស្សក្នុងកាលដែលភ្នែកឃើញរូប , ត្រចៀកឮសំលេង , ច្រមុះធុំក្លិន , អណ្តាតដឹងរស , កាយប៉ះពាល់ត្រូវ , ចិត្តទទួលដឹងធម្មារម្មណ៍ ។ ត្រូវតាំងសតិសម្បជញ្ញៈ ឱ្យឋិតនៅក្នុងអាយតនៈមានចក្ខាយតន ជាដើមនោះ ជានិច្ច ឱ្យដូចជានាយឆ្មាំទ្វារ ។

២. កម្មដ្ឋានបរិហារោ ធ្វើទុកក្នុងចិត្តដោយឧបាយចំពោះកម្មដ្ឋានឱ្យត្រូវតាមចរិតដំណើរចិត្តរបស់ខ្លួន ។ បើបុគ្គលមានលំនាំជា រាគចរិត គួរចំរើនកម្មដ្ឋាន១១ គឺ អសុភ១០ កាយគតាសតិ១ ។ ទោសចរិត គួរចំរើនកម្មដ្ឋាន៨ គឺព្រហ្មវិហារ៤ វណ្ណកសិណ៤ គឺនីលកសិណ១ បីតកសិណ១ លោហិតកសិណ១ ឱទាតកសិណ១ ។ មោហចរិតនឹងវិតក្កចរិត គួរចំរើនចំពោះកម្មដ្ឋាន១ គឺអានាបានស្សតិ ។ សទ្ធាចរិតគួរចំរើនកម្មដ្ឋាន៦គឺ ពុទ្ធានុស្សតិ១ ធម្មានុស្សតិ១ សង្ឃានុស្សតិ១ សីលានុស្សតិ១ចាគានុស្សតិ១ ទេវតានុស្សតិ១ ។ ពុទ្ធិចរិត គួរចំរើនកម្មដ្ឋាន៤ គឺមរណានុស្សតិ១ ឧបសមានុស្សតិ១ ចតុធាតុវវដ្ឋាន១ អាហារប្បដិកូលសញ្ញា១ ។ កម្មដ្ឋានសល់អំពីនេះ១០ទៀតគឺ បឋវីកសិណ១ អាបោកសិណ១ តេជោកសិណ១ វាយោកសិណ១ អាកាសកសិណ១ អាលោកកសិណ១ អរូបជ្ឈាន៤ ទាំងនេះគួរគ្រប់ចរិតទាំងអស់ដោយពិត តែ

បុគ្គលជាវិតក្កចរិត ត្រូវធ្វើវង់កសិណឱ្យតូច . បុគ្គលជាមោហចរិត ត្រូវធ្វើវង់កសិណឱ្យធំ ។

៣. វិបស្សនាភាវនានុយោគោ ប្រកបរឿយៗ ក្នុងវិបស្សនាភាវនា គឺលែលកពេលនឹងចំរើនវិបស្សនាតទៅទៀត ។ កាលបើបានចំរើនសមថកម្មដ្ឋានធ្វើចិត្តឱ្យស្ងប់ឱ្យសាបរលាបស្រោលស្តើង ចាកនីវរណូបក្កិលេស ល្មមសមគួរជាបទដ្ឋាននៃវិបស្សនាហើយ គួរលើកសង្ខារឡើងកាន់ត្រៃលក្ខណៈ មានអនិច្ចលក្ខណៈជាដើម មករំពឹងពិចារណា បន្ទាប់អំពីសមថកម្មដ្ឋាននោះមក ។ ធម៌ដែលត្រូវចំរើន ៤ យ៉ាង . ស្ថានដែលគួរប្រយ័ត្ន ៤ យ៉ាង នឹងអាការសង្រួមចិត្ត៣យ៉ាង ដូចសេចក្តីអធិប្បាយមកនេះ ជាឧបាយដ៏វិសេសក្នុងការរក្សាទូន្មានចិត្តឱ្យទន់ទោរ ឱ្យឈម ឱនទៅរកសមាធិដោយពិត ។

## សមាធិនោះចែកចេញជា៣យ៉ាងគឺ

១.សមាធិ ដែលកើតអំពីការធ្វើសមណធម៌ ឬស្តាប់ធម៌ ចិត្តក៏សង្ងៀតស្ងួតស្ងប់ចុះស៊ប់ក្នុងក្រសែធម៌ មានអារម្មណ៍មូលតែមួយហើយរលត់ទៅវិញមួយរំពេចក៏មាន ចួនកាលបុគ្គលអ្នកមានកុសលវាសនាចាស់ក្លាបរិបូណ៌ ធ្វើសមណធម៌ ឬអង្គុយគោរពស្តាប់ធម៌ ចិត្តរបស់បុគ្គលនោះអាចឈោងចាប់មគ្គផលបាន ក្នុងខណៈនោះក៏មាន ។ សមាធិកើតឡើងមួយខណៈប៉ុណ្ណោះ ហៅថា ខណិកសមាធិ ។

២. សមាធិ ដែលកើតអំពីសមណធម៌ ក្នុងទីសេនាសនៈស្ងប់ស្ងាត់ ចាកអារម្មណ៍ផ្សេងៗ ជវនចិត្តដែលលឿនស្ទុងទៅកាន់ឈានជិតៗ នឹងបានសម្រេច

ឈានក្នុងខណៈនោះ ហៅថា ឧបចារសមាធិ ។

៣. សមាធិ ដែលកើតអំពីសមណធម៌ ជវនចិត្តជ្រះថ្លាផ្លូវផង់ក្នុងសន្តាន បានអែរបញ្ញ៉ិទ្ធក្នុងឈានទាំង៤ មានបឋមជ្ឈានជាដើម អាចគ្របសង្កត់ញាំញី នូវនីវរណៈ ឱ្យទ្រុឌទ្រោម ឱ្យខ្សោយកំឡាំងទៅបាន ដូចថ្មសង្កត់ស្មៅ ហៅថា អប្បនាសមាធិ ។ បណ្តាសមាធិ៣យ៉ាងនេះ សមាធិណាមួយដែលយោគីបានចំរើនបានធ្វើរឿយ ៗ ល្មមជាទីតាំងនៃវិបស្សនា ចាត់ជា ចិត្តវិសុទ្ធិ (ចប់ដោយសង្ខេបប៉ុណ្ណោះ)។

វិសុទ្ធិទាំង ២ ប្រការដូចបានពណ៌នាមកនេះ ចាត់ជាមូលដ្ឋាន គឺថាជាឫសគល់ ជាទីតាំងនៃវិបស្សនា ។

ចប់ចិត្តបរិហារ ។

## វិសុទ្ធិទី ៣

កុលបុត្រអ្នកមានព្យាយាមបំពេញ សីល សមាធិ ឱ្យបរិសុទ្ធបរិបូណ៌ ហើយមានប្រាថ្នា នឹងធ្វើគុណសម្បត្តិ ឱ្យម៉ត់ចត់វិសេសឡើងទៅទៀត គួរចំរើនវិបស្សនា ដើម្បីបណ្តុះបញ្ញាឱ្យកើតឡើង សម្រាប់ពិចារណាក្នុងកងសង្ខារនិងអាយតនៈធាតុឥន្ទ្រិយជាដើម ដែលមានលក្ខណៈគួរពិចារណា គួរចំណាំមើលឱ្យឃើញថាជារបស់ មិនទៀង ជាទុក្ខ ជាអនត្តា ព្រោះថាធម៌ទាំងឡាយមានសង្ខារអាយតនៈធាតុឥន្ទ្រិយជាដើមនេះ លោកចាត់ថា ជាភូមិ ជាអារម្មណ៍នៃវិបស្សនាទាំងមូល ។

ពាក្យថា "សង្ខារ" នេះប្រែថា សភាវៈ ឬអ្វីៗដែលបច្ច័យទាំងឡាយប្រជុំតាក់តែង ឬថាធម្មតា ដែលផ្សំផ្គុំមកអំពីធាតុ ដូចយ៉ាងគ្រោងកាយរបស់មនុស្សសត្វ តែងតែប្រាកដឡើងព្រោះអាស្រ័យធាតុទាំង ៤ ដែលចេញចំហាយធាតុមកអំពីកុសលាកុសលកម្មជាបច្ច័យ ស្អូម្បីផ្ទះនិងរថដែលកើតឡើងដោយទព្វសម្ភារៈមានគ្រឿងឈើ គ្រឿងដែក ជាដើមព្រោះជាងអ្នកធ្វើ ជាបច្ច័យ ទាំងនេះក៏ឈ្មោះថា សង្ខារ ។ ព្រោះហេតុនោះទើបលោក វែកញែកសង្ខារនេះចេញជា២យ៉ាងគឺ ឧបាទិន្នកសង្ខារ សង្ខារដែលមាននាមធមិ គឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាម្ចាស់ចូលគ្រប់គ្រង ប្រកាន់ទុក១ អនុបាទិន្នកសង្ខារ សង្ខារដែលគ្មាននាមធមិជាម្ចាស់ចូលគ្រប់គ្រង សំដៅយកផ្ទៃដី ទឹក ឈើព្រៃ លតាវល្លិគ្រួសថ្ម សំណ ដែក ជាដើម១ ។ សង្ខារទាំង ២ យ៉ាងនេះ ទោះបីមានទំហំធំតូចខុចជា វិសេសប្លែកគ្នាយ៉ាងណា ក៏តែងមានលក្ខណៈ៣យ៉ាង មានអនិច្ចលក្ខណៈជាដើម ដូចៗគ្នាទាំងអស់ មិនគន្លងរំលងលក្ខណៈនេះបានឡើយ ។ មួយទៀតការប្រជុំខន្ធទាំង ៥ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ នេះក៏ឈ្មោះថាសង្ខារ ។ ចុះសង្ខារដែលប្រជុំខន្ធទាំង ៥ និងសង្ខារដែលនៅក្នុងផ្ទៃរបស់ខន្ធ ៥ តើមានសេចក្តីប្លែកគ្នាដូចម្តេច ? ប្រស្នានេះ លោកអ្នកចេះដឹងដែលធ្លាប់ត្រិះរិះពិចារណាដោយម៉ត់ចត់ទើបអាចឆ្លើយបានមួយរំពេច វេលានេះយើងសូមដោះស្រាយឱ្យស្រេចតែម្តង ដោយសេចក្តីយ៉ាងខ្លីថា សង្ខារដែលរួបរួមខន្ធទាំង ៥ សំដៅយកសង្ខារ ជាអតីតផល គឺកំរៃផល ជាអំណោយរបស់បច្ច័យដែលហុចជូនមកអំពីអតីតកាល ។ សង្ខារដែលកប់នៅក្នុងផ្ទៃខន្ធ៥នោះ សំដៅយកបច្ចុប្បន្នហេតុ និង អនាគតហេតុ គឺជាស្នាមតំនូសរបស់ចិត្ត និងចេតសិក

ដែលកំពុងរោករេ ត្រិះរិះរាវរកអារម្មណ៍ក្នុងបច្ចុប្បន្នកាល ស្រាវជ្រាវប្រមូលយកអារម្មណ៍ សន្សំទុកទៅក្នុងអនាគតកាល . នេះជាចំលើយដោយសង្ខេប ។

សង្ខារទាំងអស់ ទោះបី ឧបាទិន្នកសង្ខារក្តី អនុបាទិន្នកសង្ខារក្តី សង្ខារដែលប្រជុំបញ្ចក្ខន្ធក្តី សង្ខារទី ៤ ដែលជាប់នៅក្នុងផ្ទៃបញ្ចក្ខន្ធក្តី ទាំងអស់នេះមិនកន្លងផុតលក្ខណៈ៣យ៉ាងបានឡើយ ។ លក្ខណៈ៣យ៉ាងនោះគឺ **អនិច្ចលក្ខណៈ** មានគ្រឿងចំណាំឃើញថា មិនទៀង១ **ទុក្ខលក្ខណៈ** មានគ្រឿងចំណាំឃើញថា ជាទុក្ខ១ **អនត្តលក្ខណៈ** មានគ្រឿងចំណាំឃើញថា មិនមែនជារបស់ខ្លួនប្រាណ១ ។

ពាក្យថា "សង្ខារមិនទៀង" នោះគឺថា មិនគង់ចំណាំនៅដូចប្រក្រតី តែងមានអាការវិបរិត ប្រែប្រួលទៅផ្សេងៗ គឺមានការកើតឡើងជាខាងដើម មានសេចក្តីប្រែប្រួល ក្នុងទីពាក់កណ្តាល មានសេចក្តីសាបសូន្យទៅ ក្នុងទីបំផុត ដូចយ៉ាងមុនដំបូងតូច តំណពីតូចទៅធំ , ដំបូងក្មេង តំណពីក្មេងទៅចាស់ តំណពីចាស់ស្លាប់ តំណពីស្លាប់កើតវិលសាមកចូបនឹងតំណដើមវិញ មិនចេះដាច់។ ក្នុងចន្លោះរយៈកាលអាយុនៃសង្ខារនោះសោត ក៏មានជម្ងឺដំកាត់ដោយសមុដ្ឋានរោគ តាមកាលរដូវខ្លះ ដោយកម្មវិបាកជាធម្មតារបស់សត្វខ្លះ ។

មួយទៀត ក្នុងគម្ពីរអដ្ឋកថា អលគទ្ទូបមសូត្រ នៃមជ្ឈិមនិកាយ មូលបណ្ណាសកៈ មានសេចក្តីថា ដែលហៅថា អនិច្ចៈ មិនទៀង , ទុក្ខៈ ជាទុក្ខ , អនត្តា មិនមែនខ្លួនប្រាណនេះ ដោយហេតុ ៤ ៗ យ៉ាង ។

## អនិច្ចៈដោយហេតុ ៤ យ៉ាង

ពាក្យថា អនិច្ចៈ ដោយហេតុ៤យ៉ាងគឺ ឧប្បាទវយវត្តិតោ កើតឡើង និងសូន្យទៅប្រព្រឹត្តទៅផ្សេង១ វិបរិណាមតោ ប្រែប្រួលត្រឡប់ក្លាយទៅតាមធម្មតា១ តាវកាលិកតោ ប្រព្រឹត្តទៅបានចំពោះកាលវេលា ដូចជារបស់ខ្ចីគេនោះ១ និច្ចប្បដិក្ខេបតោ ជាបដិប័ក្ខ (ទំនាស់) ធ្លាំនឹងសភាវៈដែលទៀងទាត់១ ។ សេចក្តីប្រែប្រួលផ្លាស់រូបខុសចំណាំប្រក្រតីរបស់សង្ខារយ៉ាងនេះ ជាគ្រឿងសំគាល់ថា មិនទៀង ។

## សត្វលោក ជាប់ចំណោទនៃសេចក្តីទុក្ខ

ពាក្យថា សង្ខារជាទុក្ខ នោះសំគាល់ថា សេចក្តីក្តៅក្តៅ ថាអត់ធ្មត់ទ្រាំនៅបានដោយលំបាក ឬថា គាស់រំលើងបំបាត់ចោលចេញបានដោយក្រ ដែលជាអំណោយផលរបស់ ជាតិ១ ជរា១ ព្យាធិ១ មរណៈ១ ទាំង៤យ៉ាងនេះជាទុក្ខធំ គឺជាដើមពូជបែកសាខានៃសេចក្តីទុក្ខតូចតាច រំកាច់រំកោចគ្រប់យ៉ាងរបស់សត្វលោក ដូចសេចក្តីទុក្ខតានតឹងដែលកើតឡើងព្រោះ ស្រេកឃ្លាន ក្តៅត្រជាក់ ស្អុះស្អាប់ បន្ទោបង់ ឧច្ចារបស្សាវៈ ការស្វែងរកអាហារចំណី ឬកើតឡើងព្រោះការព្រាត់ព្រាស់ខុសសេចក្តីប៉ុនប៉ង ទាំងអស់នេះសុទ្ធតែជាទុក្ខរប៉ិចរប៉ុដែលជាកូនរម ជាផ្លែផ្កា ឬជាសេនា របស់សេចក្តីទុក្ខធំៗ ។ សេចក្តីទុក្ខធំតូច ដែលតែងគ្របសង្កត់សត្វលោកទាំងនេះ រាប់ថាជាចំណោទប្រចាំលោក ឬជាប្រស្នាមួយដែលហេតុបច្ច័យចោទទុកមកជាយូរមកហើយ ជាប្រស្នាយ៉ាងជ្រៅតឹងបំផុត មិនងាយសត្វលោកបុថុជ្ជន ឆ្លើយរួចបានឡើយ ។ បុរសស្ត្រីអន្ធពាលបុថុជ្ជន

ដែលរយាលអំពីការសិក្សារៀនសូត្រស្តាប់ផ្ទាល់ខ្លួន ឬមិនដែលបានចុះស្នាមក្នុង អរិយធម៌សោះ កាលបើត្រូវសេចក្តីទុក្ខគ្របសង្កត់ញាំញីម្តងៗ ឥតមានប្រាជ្ញាស្មារតីពិចារណាស្រាវជ្រាវរក ឆ្លើយឱ្យរួច ដោះស្រាយចំណោទ ឱ្យច្បាស់ ឱ្យឃើញដើមពូជ សេនានៃសេចក្តីទុក្ខនោះបានឡើយ ច្រើនតែទ្រាំនៅទាំងទាល់ប្រស្នារបស់សេចក្តីទុក្ខនោះជាដរាប មានត្រឹមតែ ក្រៀមក្រំ សម្រក់ទឹកភ្នែក ស្រែកយំថ្ងូរ ត្អូញត្អែរប៉ុណ្ណោះ នេះឯងឈ្មោះថា ជាការដោះស្រាយចំណោទ ដោយទាល់ផ្លូវ ដូចសុនខដេញខាំត្រឹមតែដុំដី ឬកំណាត់ឈើ ដែលគេបោះចោល ទៅត្រូវប៉ះខ្លួនប៉ុណ្ណោះ មិនអាចដឹងហេតុរបស់ដុំដីឬកំណាត់ឈើនោះបានឡើយ ។

ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ជាបុគ្គលមានប្រាជ្ញាជ្រាលជ្រៅ មោះមុត បានត្រិះរិះ ឈ្វេចឈ្វី ស្ទង់មើល ជាអនុលោម បដិលោមតាមបដិច្ចសមុប្បាទធម៌ ស្រាវរកឃើញនូវដើមកំណើតភូមិលំនៅនៃសេចក្តីទុក្ខ ដោយជាក់ច្បាស់ហើយ បានគាស់រំលើង ដុតបំផ្លាញទីកន្លែងដែលជាដែនកើត មិនឱ្យមានពូជត្រកូលលំនៅនៃសេចក្តីទុក្ខជ្រកកោនកើតឡើងតទៅទៀតបាន ។ ការដែល ព្រះសម្ពុទ្ធទ្រង់ ពិចារណា ស្រាវរក ឃើញដើមចមនៃទុក្ខ ក្នុងបដិច្ចសមុប្បាទធម៌ ដោយជាក់ច្បាស់នោះ ឈ្មោះថា ព្រះអង្គបានឆ្លើយប្រស្នាដោះស្រាយ ចំណោទនៃសេចក្តីទុក្ខ រួចស្រឡះឥតទើសទាល់ឡើយ ។

## ទុក្ខៈដោយហេតុ ៤ យ៉ាង

ពាក្យថា "ទុក្ខៈ" រមែងប្រាកដដោយហេតុ៤យ៉ាងគឺ សន្តាបតោ នាំឱ្យក្តៅរោលរាលសព្វសពាង្គកាយ១ ទុក្ខតោ នាំឱ្យកើតទុក្ខច្រើនប្រការ១

ទុក្ខវត្ថុកតោ ជាកន្លែងជាទីតាំងនៃទុក្ខ១ សុខប្បដិក្ខេបតោ ជាបដិប័ក្ខ (ទំនាស់)គ្នានឹងសេចក្តីសុខ១ ។ បញ្ចក្ខន្ធមានការៈដ៏ធ្ងន់នាំឱ្យបានពីងក្តៅក្រហាយ អផ្សុកអផ្សាន្តនេះ ជាគ្រឿងសំគាល់ថាជាទុក្ខ ដែលជាផលនៃនាមរូប ។

ពាក្យថា សង្ខារជាអនត្តា នោះសំគាល់សេចក្តីថាមិនមែនខ្លួនប្រាណ គឺថា កាលបើសង្ខារមានប្រាកដឡើងហើយ ឥតមានធម្មជាតិអ្វី ជាឥស្សរៈលើសង្ខារនោះទេ ទោះបីមានវិញ្ញាណជ្រកអាស្រ័យ ក្នុងផ្ទៃសង្ខារនោះក៏ដោយ មិនមានអំណាចនឹងរាំងរាថែរក្សាបានឡើយ ។ អនត្តា ប្រែថាមិនមែនខ្លួន ឬថាមិនតាំងនៅក្នុងការបង្គាប់បញ្ជារបស់ខ្លួន ដូចយ៉ាងសង្ខារដែលប្រទះនឹងអន្តរាយ ក្នុងកាលម្តង១ មានរោគន្តរាយជាដើម ហើយយើងបង្គាប់ ឬសូមអង្វរថា "សូមសង្ខាររបស់អញ ជាសះស្បើយឡើង ? សូមកុំឱ្យមានគ្រោះថ្នាក់ដូច្នោះឡើយ ?" ការសូមអង្វរដូច្នេះក៏ទុកដូចជាមិនអង្វរ ព្រោះមិនដែលបានដូចបំណងនោះឡើយ ដូចក្នុងអនត្តលក្ខណសូត្រ ដែលព្រះសព្វញ្ញាពុទ្ធទ្រង់សំដែងប្រោសបញ្ចវគ្គិយភិក្ខុថា " ម្នាលភិក្ខុទាំងឡាយ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែនជាតួខ្លួនទេ បើជាខ្លួនប្រាណរបស់យើងប្រាកដមែននោះគួរណាស់តែនឹងមិនមានជម្ងឺ ដំកាត់បានឡើយ " ។

## អនត្តាដោយហេតុ ៤ យ៉ាង

ពាក្យថា អនត្តា នេះរមែងប្រាកដដោយហេតុ ៤ យ៉ាងគឺ សុញ្ញតោ សូន្យឈឹងចាកខឹមសារ១ អស្សាមិកតោ ឥតមានបុគ្គលគ្រប់គ្រងបាន១ អនិស្សរតោ ឥតមានបុគ្គល ឬវត្ថុអ្វីជាធំត្រួតត្រាបាន១ អត្តប្បដិក្ខេបតោ

ជាបដិប័ក្ខ (ទំនាស់) គ្នានឹងការ ប្រកាន់របស់ខ្លួនថា ខ្លួនប្រាណ១ ។

យោគាវចរកុលបុត្រអ្នកចំរើនវិបស្សនា កាលបើលើកយកសង្ខារគឺ ខន្ធ៥ មកពិចារណា តាមលក្ខណៈទាំង៣ប្រការ ដូចសំដែងមកនេះ ហើយគប្បីញែក ខន្ធទាំង៥នោះចេញជា២គឺ រូប១ នាម១ ឱ្យឃើញទីទៃពីគ្នា ដូចស្គរនឹងសំឡេង ស្គរ លុះអាស្រ័យគ្នាទៅវិញទៅមក ទើបអាចប្រព្រឹត្តទៅបាន គឺនាមអាស្រ័យរូប ជាទីជ្រកកោន រូបក៏អាស្រ័យនាមជាកំឡាំង , ដូចនាវាអាស្រ័យមនុស្សជាកំឡាំង មនុស្សក៏អាស្រ័យនាវាជាគ្រឿងប្រកបការ ទើបអាចលឿនទៅមុខបាន ឬដូច បុរសពីរនាក់ គឺម្នាក់ខ្វាក់ ម្នាក់ខ្វិន អាស្រ័យគ្នានឹងគ្នា លុះរូបនិងនាមនេះ អាស្រ័យគ្នាហើយ ក៏បានឈ្មោះថា ជាសត្វ ជាបុគ្គល ជាទេវតា ជាព្រហ្ម ដោយសេចក្ដីសន្មតិប៉ុណ្ណោះ មិនមែនបានឈ្មោះដោយបរមត្ថទេ ។ ប្រាជ្ញរបស់ យោគីដែលឃើញច្បាស់ចាំជាក់ថា សត្វ បុគ្គល ទេវតា ព្រហ្មនោះ គ្រាន់តែ ជានាមរូប ជាធាតុ១ប៉ុណ្ណោះ មិនមែនជារបស់ទៀងទាត់សុខសាន្តទេ ក៏លះកាត់ សេចក្ដីអាល័យស្នេហា ចំពោះបុគ្គលនោះចេញ ពិចារណារូចកាន់យកព្រះនិព្វាន មកជាអារម្មណ៍ ។ ប្រាជ្ញដ៏បរិសុទ្ធ ម៉ត់ចត់ ព្រោះការឃើញច្បាស់នេះចាត់ថា ទិដ្ឋិវិសុទ្ធិ ជាសរីរៈ គឺជាតួនៃវិបស្សនាទី១ ។

## វិសុទ្ធិទី ៤

កុលបុត្រអ្នកបំពេញព្យាយាម កាលបើបានចំរើន ធ្វើឱ្យទិដ្ឋិវិសុទ្ធិ កើតឡើងបរិបូណ៌ហើយ គួរចំរើនវិបស្សនា ពិចារណាស្វែងរកហេតុនិងបច្ច័យ របស់នាមរូប ដែលជា សមុដ្ឋាន ជាដើមកំណើតនៃទុក្ខតទៅ ។

ពេទ្យអ្នកឆ្លៀវឆ្លាស ក្នុងការពិនិត្យអាការរោគ កាលបើឃើញរោគច្បាស់ហើយ តែងជញ្ជឹងគិតស្វែងរកសមុដ្ឋាន ដែលជាមូលហេតុនៃរោគយ៉ាងណាមិញ បុគ្គលអ្នកបំពេញព្យាយាមក្នុងផ្លូវវិបស្សនា កាលបើឃើញនាមរូបច្បាស់លាស់ហើយ ក៏គួរស្វែងរកហេតុផលបច្ច័យរបស់នាមរូបនោះដែរ មួយទៀត បុរសស្ត្រីអ្នកមានសន្តានចិត្តអនុគ្រោះ កាលបើបានឃើញកូនក្មេងតូចដែលកំពុងដេកផ្ងារទៀបច្រកផ្លូវ , គេតែងនឹករកដល់មាតាបិតារបស់កូនក្មេងថា "ក្មេងនេះជាកូនរបស់អ្នកណា ? " សេចក្តីនេះដូចម្តេចមិញ យោគាវចរពិចារណារកហេតុបច្ច័យ ដើមពូជរបស់នាមរូបក៏ដូច្នោះដែរ , កាលបើឃើញច្បាស់ហេតុនិងបច្ច័យរបស់នាមរូបនោះបានដោយសព្វគ្រប់ហើយ ក៏រមែងឆ្លងនូវកង្ខាសេចក្តីសង្ស័យចំពោះនាមរូប ក្នុងកាលទាំង ៣ បានដោយពិត ។

## ហេតុបច្ច័យរបស់នាមរូប

Très importance

ចុះធម៌ដែលជាហេតុបច្ច័យរបស់នាមរូប តើមានប៉ុន្មានយ៉ាង ? នាមរូបតើអាស្រ័យនូវអ្វីទើបកើតឡើងបាន ? ធម៌ជាហេតុបច្ច័យរបស់នាមរូបនោះមាន ៥ យ៉ាងគឺ អវិជ្ជា សេចក្តីល្ងង់ខ្លៅ មិនអាចដឹងច្បាស់ក្នុងអរិយសច្ចធម៌ដែលជារបស់ពិតមែន១ តណ្ហា សេចក្តីប្រាថ្នា អន្ទះសា ឆ្លេឆ្លា ញាប់ញ័រ សស្សើត សស្លក់ក្នុងកាមារម្មណ៍១ ឧបាទាន ចិត្តចំពាក់ចាក់ស្រែះថ្កក់ជាប់ក្នុងខន្ធទាំង៥ជា ដើម១ កម្ម អំពើជា កុសល អកុសល ដែលជាធម៌មានសំទុះនាំសត្វ ឱ្យស្ទុះទៅកាន់កំណើតក្នុងភពតូចធំ១ អាហារ គ្រឿងបរិភោគក្រេបផឹកលេបចូលទៅកើតមានឱជារស ទំនុកបំរុងកាយ១ ។ អវិជ្ជា តណ្ហា ឧបាទាន កម្ម ទាំង៤នេះ

ជាហេតុរបស់នាមរូប ព្រោះជាអ្នកផ្តួចផ្តើមឱ្យកើតឡើងជាដំបូង , អាហារជាបច្ច័យរបស់នាមរូប ព្រោះជាអ្នកជួយឧបត្ថម្ភខាងការបំប៉នកំឡាំង ឱ្យចំរើនសាច់ឈាមធាត់ធំឡើង ។ មួយទៀត អវិជ្ជា តណ្ហា ឧបាទាន ទាំង៣នេះជាឧបនិស្ស័យ គឺជាទីអាស្រ័យនៅនៃរូបកាយ ដូចមាតាជាទីអាស្រ័យនៅនៃទារក , កម្ម ជាទីញ៉ាំងសត្វឱ្យកើត ដូចជាមាតារបស់បុត្រ , អាហារជាជំនួយជ្រោមជ្រែងដូចមេនំ ជាអ្នកបីបាច់រក្សាទារក ។ នាមរូប ដែលកើតឡើងបាន ព្រោះអាស្រ័យធម៌ ៥ យ៉ាងដូចពោលមកនេះឯង ។

ពួកសត្វដែលមានធម៌៥យ៉ាងនេះ តាំងនៅក្នុងខន្ធសន្តាន ដរាបណាក៏រមែងទទួលយក នូវការកើត ចាស់ ឈឺ ស្លាប់ ក្នុងភព តទៅទៀតដរាបនោះ។

មួយទៀត អាហារ ជាបច្ច័យរបស់រូបធម៌ ដោយសេចក្តីថា មហាភូតរូបទាំង ៤ គឺ ដី ទឹក ភ្លើង ខ្យល់ តែងចំរើនឡើងត១មកជាសន្តតិរូបបាន ក៏ព្រោះអាស្រ័យអាហារ , ផស្សៈជាបច្ច័យរបស់នាមធម៌គឺ វេទនា សញ្ញា សង្ខារ , ចំណែកខាងនាមធម៌ទាំងនេះអាស្រ័យបច្ច័យ គឺ ផស្សៈ ទើបកើតឡើងបាន , នាមនឹងរូប ជាបច្ច័យរបស់នាមធម៌គឺ វិញ្ញាណ ។ មួយវិញទៀត ធម៌ដែលជាហេតុ ជាបច្ច័យ របស់នាមរូបនេះ បណ្ឌិតគប្បីសន្និដ្ឋាន ដោយសេចក្តីជាក់ច្បាស់ដូច្នេះ គឺ អវិជ្ជា តណ្ហា ឧបាទាន កម្ម អាហារ ជាហេតុជាបច្ច័យរបស់រូបធម៌ , អវិជ្ជា តណ្ហា ឧបាទាន កម្ម ផស្សៈ ជាហេតុជាបច្ច័យរបស់នាមធម៌ គឺ វេទនា សញ្ញា សង្ខារ , អវិជ្ជា តណ្ហា ឧបាទាន កម្ម នាមរូប ជាហេតុជាបច្ច័យរបស់នាមធម៌ គឺ វិញ្ញាណ ។

បុគ្គលអ្នកមានប្រាជ្ញា កាលបើកំណត់ដឹងឃើញច្បាស់ហេតុបច្ច័យដែលជាដើមកំណើតរបស់នាមរូប ដូច្នេះហើយ ក៏រមែងឆ្លងនូវសេចក្ដីសង្ស័យទាំង១៦យ៉ាង ក្នុងកាលទាំង៣បាន គឺសេចក្ដីសង្ស័យ ក្នុងអតីតកាល៥ អនាគតកាល៥ បច្ចុប្បន្នកាល៦ ដូចតទៅនេះ

## សេចក្ដីសង្ស័យក្នុងអតីតកាល៥នោះគឺ

១. អហោសិ នុខោ អាត្មាអញធ្លាប់បានកើតមែន ឬ ហ្ន៎ ?

២. ននុខោ អហោសិ អាត្មាអញមិនធ្លាប់កើតទេ ឬ ហ្ន៎ ?

៣. កិន្នុខោ អហោសិ អាត្មាអញធ្លាប់កើតមកជាអ្វី ហ្ន៎ ?

៤. កថំ នុខោ អហោសិ អាត្មាអញបានកើតមកដោយប្រការដូចម្ដេច ហ្ន៎ ?

៥. កឹ ហុត្វា កឹ អហោសិ អាត្មាអញបានជាអ្វីហើយ ទើបកើតទៅជា អ្វីទៀត ?

## សេចក្ដីសង្ស័យក្នុងអនាគតកាល ៥ គឺ

១. ភវិស្សាមិ នុខោ អាត្មាអញនឹងកើតមែនឬហ្ន៎ ?

២. ននុខោ ភវិស្សាមិ អាត្មាអញនឹងមិនកើតទេឬហ្ន៎ ?

៣. កិន្នុខោ ភវិស្សាមិ អាត្មាអញនឹងកើតជាអ្វីហ្ន៎ ?

៤. កថំ នុខោ ភវិស្សាមិ អាត្មាអញនឹងកើតឡើង បានដោយប្រការ ដូចម្ដេច ហ្ន៎ ?

៥. កឹ ហុត្វា កឹ ភវិស្សាមិ    អាត្មាអញនឹងកើតបានជាអ្វី ទើបនឹងទៅជា អ្វីទៀត ?

## សេចក្តីសង្ស័យក្នុងបច្ចុប្បន្នកាល ៦ គឺ

១. អហំ នុខោស្មិ អាត្មាអញមាន ឬហ្ន៎ ?

២. នោ នុខោស្មិ អាត្មាអញមិនមានទេ ហ្ន៎ ?

៣. កិន្នុ ខោស្មិ អាត្មាអញមានដូចម្តេច ហ្ន៎ ?

៤. កថំ នុខោស្មិ អាត្មាអញមានដោយប្រការដូចម្តេច ហ្ន៎ ?

៥. អយំ នុខោ សត្តោ កុតោ អាគតោ សត្វនេះមកអំពីទីណា ហ្ន៎ ?

៦. សោកុហឹ គាមី ភវិស្សតិ សត្វនោះនឹងទៅក្នុងទីណាទៀតអេះ ?

កាលបើ វិបស្សនាយានិកបុគ្គល ( បុគ្គលអ្នកឋិតនៅក្នុងយានគឺវិបស្សនា ) បានកំណត់ពិចារណាយល់ច្បាស់ហេតុបច្ច័យ របស់នាមនិងរូបដូច្នេះហើយ ទើបអាចឆ្លងផុតសេចក្តីសង្ស័យទាំង១៦យ៉ាងបាន រមែងជាអ្នកមិនមានសេចក្តីងឿងឆ្ងល់ចំពោះនាមនិងរូប ក្នុងចំណែកអតីត អនាគត បច្ចុប្បន្ន ។ បញ្ញារបស់បុគ្គលជាវិបស្សនាយានិកៈ ដែលមានកំឡាំងក្លៀវក្លា ពិចារណាឃើញច្បាស់ហេតុបច្ច័យ របស់នាមនិងរូប ហើយឆ្លងផុតសេចក្តីសង្ស័យ ក្នុងកាលទាំង៣បាន យ៉ាងនេះឯង ចាត់ជាកង្ខាវិតរណវិសុទ្ធិ ជាតួនៃ វិបស្សនាទី២ ។

## វិសុទ្ធិទី ៥

វិបស្សនាយានិកកុលបុត្រ កាលបើបានពិចារណាស្ទាប់ស្ទង់ឃើញ ហេតុបច្ច័យ របស់នាមនិងរូប បានឆ្លងផុតចាកសេចក្តីសង្ស័យដោយពេញហើយ គួរចំរើន

វិបស្សនា គឺកំណត់ទុកដោយបញ្ញានូវនាមរូប ព្រមទាំងហេតុបច្ច័យរបស់រូបតទៅទៀត ឱ្យឃើញប្រាកដថា នាមរូបណា ដែលកើតក្នុងអតីតកាល នាមរូបនោះក៏បាត់ទៅក្នុងអតីតកាល ,  នាមរូបណា ដែលកើតក្នុងអនាគតកាល នាមរូបនោះ ក៏នឹងត្រូវវិនាសទៅក្នុងអនាគតកាល , នាមរូបណា ដែលកើតឡើងក្នុងបច្ចុប្បន្នកាល នាមរូបនោះក៏រមែងទ្រុឌទ្រោមសាបសូន្យក្នុងបច្ចុប្បន្នកាល , នាមរូបណាទោះបីខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ខ្ពង់ខ្ពស់ក្តី ឆ្ងាយក្តី ជិតក្តី នាមរូបទាំងអស់នោះ ក៏រមែងទទួលយកនូវការមិនទៀង ព្រាត់ប្រាស់ និរាសទៅតាមចំណែករបស់ខ្លួនៗ ។

ព្រោះហេតុនេះ នាមរូបនោះឯង ទើបឈ្មោះថា ជារបស់មិនពិតតាមបរមត្ថឡើយ នាមរូបដែលកើតប្រាកដឡើងក្នុងលោក ក៏តែងវិបត្តិប្រែប្រួលទៅផ្សេងៗប្រាកដនៅក្នុងលោក រមែងមិនកន្លងសភាវៈដើមបានទេ គឺនាមរូបណាមិនទៀង នាមរូបនោះឯងជាទុក្ខ , នាមរូបណាជាទុក្ខ នាមរូបនោះជាអនត្តា , នាមរូបណាជាអនត្តា នាមរូបនោះមិនមែនជារបស់យើង មិនមែនជាយើង មិនមែនជាខ្លួនប្រាណរបស់យើងឡើយ ។ កាលបើយោគីអ្នកចំរើនវិបស្សនាបានលើកយកសង្ខារគឺខន្ធ៥ និងអាយតនៈ ធាតុ ឥន្ទ្រិយ ឡើងកាន់ត្រៃលក្ខណៈពិចារណាឃើញជាក់ច្បាស់តាមដំណើរនៃអនុបស្សនា ៣ យ៉ាងឃើញរឿយៗ ថា មិនទៀង ជាទុក្ខ ជាអនត្តាហើយ រមែងលះបង់នូវសញ្ញា៣ ប្រការចេញបាន ។

សញ្ញា៣ប្រការនោះគឺ សន្តតិសញ្ញា សំគាល់ថា មានជីវិតរស់នៅយូរអង្វែងតទៅ១ ឥរិយាបថសញ្ញា សំគាល់ថានឹងប្រព្រឹត្តគ្រប់ឥរិយាបថទាំង៤ គឺ ដើរ ឈរ អង្គុយ ដេក បានដោយស្រួល១ ឃនសញ្ញា សំគាល់ថា

មានខ្លឹមសារតាំងនៅប្រាកដដូចជាដុំថ្មតាន់១ ។ ចំណែកខាងត្រៃលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ដែលចេះតែស្រពេចស្រពិលមិនជាក់ច្បាស់ប្រាកដ ដល់យោគីនោះ ក៏ព្រោះសញ្ញា ៣ប្រការនេះឯង តែងគ្របសង្កត់បិទបាំង ដូច ពពកបាំងព្រះចន្ទ លុះតែយោគី ឃើញជាក់ច្បាស់ ដោយអនុបស្សនា ៣យ៉ាងទើប អាចនឹងកំចាត់នូវសញ្ញា ៣ប្រការនោះចេញបាន ។

អនុបស្សនា ៣យ៉ាងគឺ អនិច្ចានុបស្សនា ការពិចារណាឃើញរឿយៗថា មិនទៀង (អាចកំចាត់បង់នូវសន្តតិសញ្ញា)១ ទុក្ខានុបស្សនា ពិចារណាឃើញ រឿយៗ ថាជាទុក្ខ (អាចកំចាត់បង់នូវឥរិយាបថសញ្ញា)១ អនត្តានុបស្សនា ពិចារណាឃើញរឿយៗថាជាអនត្តា (អាចកំចាត់បង់នូវឃនសញ្ញា១) ។ កាលបើ យោគីបានពិចារណាតាមដំណើរនៃអនុបស្សនា៣ . លះបង់សញ្ញា ៣ប្រការបាន ហើយ គប្បីលើកយកវ័យ៣ និងរយៈកាល របស់វ័យ១០ប្រការឡើងកាន់ ត្រៃលក្ខណៈ កំណត់ពិចារណានាមរូបទាំងសេចក្តីវិនាស និងសេចក្តីចំរើនឡើង នៃនាម រូបតទៅទៀត ។

## វ័យ៣ប្រការ(១) នោះគឺ

**បឋមវ័យ** កំណត់យកអាយុនៃមនុស្សត្រឹម៣៣ឆ្នាំ រាប់តាំងអំពីឆ្នាំ កំណើតមក១ ។

**មជ្ឈិមវ័យ** កំណត់យកអាយុ៣៤ឆ្នាំ រាប់តាំងអំពីឆ្នាំតំណនៃឆ្នាំទីបំផុត បឋមវ័យ នោះមក១ ។

*(១) បើរាប់តាមវ័យ របស់មនុស្សជាន់ ឥឡូវនេះ កំណត់ត្រឹមអាយុ ២៥ គ្រប់វ័យទាំង៣បានជា អាយុ ៧៥ ឆ្នាំ ចាត់ជាអាយុក្ខ័យ ។*

បច្ឆិមវ័យ កំណត់យកអាយុ៣៣ឆ្នាំ រាប់តាំងអំពីតំណនៃឆ្នាំទីបំផុតមជ្ឈិមវ័យ នោះមក ១ ។

វ័យដែលរាប់មកនេះ កំណត់យកមនុស្សជាន់មុនដែលមានអាយុ ១០០ឆ្នាំ។ យោគីគប្បីពិចារណា នាមរូប ដែលឋិតនៅក្នុងវ័យទាំង៣ ឱ្យឃើញថា នាមរូបដែលឋិតនៅក្នុងបឋមវ័យ ចូនកាលក៏ វិនាសបាត់បង់ទៅ ក្នុងបឋមវ័យ , នាមរូបដែលឋិតនៅក្នុងមជ្ឈិមវ័យ, ចូនកាលក៏ វិនាសបាត់បង់ទៅក្នុងមជ្ឈិមវ័យ, នាមរូបដែលឋិតនៅក្នុងបច្ឆិមវ័យ ចូនកាលក៏ វិនាសបាត់បង់ទៅក្នុងបច្ឆិមវ័យ ។ ជំនាន់វ័យ ៣ប្រការនេះ វ័យណាមួយ សុទ្ធតែជាលំនៅ ឬជាទីកន្លែងរបស់ អនិច្ចតា ទុក្ខតា អនត្តា ធម៌ទាំងអស់ ។ វ័យទាំងនេះ តែងលះចោលនូវនាមរូបទៅជាលំដាប់ៗរាល់យប់ថ្ងៃធម្មតា ។

មួយទៀត រយៈកាលរបស់វ័យ១០ប្រការនោះគឺ

១. មន្ទទសកៈ រវាងកូនក្មេងអាយុ១០ឆ្នាំ នៅតូចជំទើ ទន់ភ្លន់ កំពុងរពឹសដៃ ជើង ។

២. ខិឌ្ឌាទសកៈ អាយុ១០ឆ្នាំមកទៀត ក្នុងកាលដែលខ្លួនធំពេញជំទង់ កំពុងត្រេកអរដោយល្បែងផ្សេងៗ ។

៣. វណ្ណទសកៈ ១០ឆ្នាំមកទៀត ក្នុងកាលដែលខ្លួនពេញកំឡោះ ក្រមុំ កំពុងពេញសម្បុរកាយ ។

៤. ពលទសកៈ ១០ឆ្នាំមកទៀត ក្នុងកាលដែលខ្លួនមានសាច់ធំរឹងប៉ឹង កំពុងពេញកំឡាំងកាយ ១ ។

៥. បញ្ញាទសកៈ ១០ឆ្នាំមកទៀត ក្នុងកាលដែលខ្លួនកំពុងមាន

ឧបាយគំនិត ប្រាជ្ញា ស្គាល់ហេតុផលល្អអាក្រក់ ។

៦. ហានិទសកៈ ១០ឆ្នាំមកទៀត ក្នុងកាលដែលខ្លួនចាស់ជរា ថយសេចក្ដីអង់អាចគ្រប់យ៉ាង ដោយលំដាប់ ។

៧. បព្ភារទសកៈ ១០ឆ្នាំមកទៀត ក្នុងកាលដែលខ្លួនមានរាងកាយទោរទន់ ទ្រុឌទ្រោម ញាប់ញ័រ អស់ទាំងសរីរៈ ។

៨. វង្កទសកៈ ១០ឆ្នាំមកទៀត ក្នុងកាលដែលខ្លួនមានអត្តភាពចាស់ព្រាំព្រា ខ្នងកោងដូចយាមនង្គ័ល ។

៩. មោមូហទសកៈ ១០ឆ្នាំមកទៀត ក្នុងកាលដែលខ្លួនមានប្រាជ្ញាស្មារតី ងេងងោង ភ្លេចភ្លាំង ។

១០. សយនទសកៈ ១០ឆ្នាំមកទៀត ក្នុងកាលដែលខ្លួនដេកជ្រលៀក ស្រតឹកនៅលើដំណេក ។

រយៈកាលរបស់វ័យ ១០ប្រការនេះ កំណត់យកមនុស្សមានអាយុ១០០ឆ្នាំ . ជំនាន់វ័យនិងរយៈកាលរបស់វ័យ ដូចពោលមកនេះ យោគីគប្បីលើកឡើងកាន់ត្រៃលក្ខណៈ ពិចារណានឹកជញ្ជឹង ឱ្យឃើញថាជាទីតាំងនៅនៃគ្រោះថ្នាក់ទុក្ខភ័យ ដើម្បីឱ្យកើតសង្វេគលន្លង់លន្លោច ចំពោះសេចក្ដីវិនាសទៅនៃនាមរូបទាំងអស់ ។ មួយទៀត នាមរូបនេះ រមែងវិនាសទៅដោយសត្រូវច្រើនយ៉ាង គឺ វិនាសទៅព្រោះ ក្ដៅណាស់ ត្រជាក់ណាស់ ស្រេកណាស់ ឃ្លានណាស់ ជាដើម ។ មួយវិញទៀត នាមរូបនេះ ចួនកាលក៏ភប់ភាន់ប្រទះនឹងអន្តរកប្ប គឺសេចក្ដីវិនាសដោយមរណៈ ពុំជូនកាលស្រាប់តែកើតឡើង តាមកាលសម័យ ។

## អន្តរកប្បនេះមាន៣យ៉ាងគឺ

១. ទុព្ភិក្ខន្តរកប្ប នាមរូបរបស់មនុស្សសត្វ វិនាសដោយទុរភិក្ស គឺអត់អាហារ ។

២. រោគន្តរកប្ប វិនាសដោយរោគាពាធផ្សេង១ មានជម្ងឺគ្រុនក្តៅជាដើម ។

៣. សត្ថន្តរកប្ប វិនាសដោយសស្ត្រាវុធក្នុងកាលដែលមានគ្រោះថ្នាក់មានសង្គ្រាមជាដើម ។

យោគីអ្នកចំរើនវិបស្សនា កាលបើពិចារណាឃើញសង្ខារគឺនាមរូបដោយឧបាយបញ្ញា ដ៏ម៉ត់ចត់ ជាហេតុនឹងឱ្យដាច់ចិត្ត ចាកអាល័យក្នុងនាមរូប ។ ចិត្តរបស់យោគីនោះ ក៏រមែងមិនតាំងនៅស៊ប់ក្នុងសង្ខារ ជាចិត្តអង់អាចក្លៀវក្លាក្នុងការរើចេញចាកសង្ខារ ជាចិត្តព្រមព្រៀងមូលមិត្ត ដោយបញ្ញាស្មារតីក្នុងត្រៃលក្ខណៈ។ វិបស្សនាបញ្ញាបរិបូណ៌ ចាស់ក្លា ដែលយោគីបានចំរើនរឿយ១រហូតដល់មកថ្នាក់នេះហើយ ច្រើនតែវិបស្សនូក្កិលេស ចូលជ្រៀតជ្រែកធ្វើបញ្ញារបស់យោគីនោះ ឱ្យភ័ន្តភាំង ច្រឡំឃ្លាងទៅតាមឧបក្កិលេសនោះជាធម្មតា ។

## វិបស្សនូបក្កិលេសមាន១០ប្រការគឺ

១. ឱភាសោ ពន្លឺស្វាងកើតឡើងផ្សាយចេញអំពីសរីរាវយវៈដោយអំណាច វិបស្សនា ។

២. ញាណំ បញ្ញាក្លៀវក្លា ឃើញនាមរូប ជាក់ច្បាស់កើតឡើងដោយល្អ ។

៣. បីតិ សេចក្តីត្រេកអរ ធ្វើកាយនិងចិត្ត ឱ្យឆ្អែតក៏ផ្សាយទូទៅក្នុងសរីរៈ ។

៤. បស្សទ្ធិ សេចក្តីស្ងប់រម្ងាប់កាយនិងចិត្ត ឥតក្រវល់ក្រវាយក្នុងអារម្មណ៍ ផ្សេងៗ ។

៥. សុខំ សេចក្តីសុខស្រួលកាយនិងចិត្ត ជាឯកគ្គតារម្មណ៍ដ៏ប្រសើរ ។

៦. អធិមោក្ខា សេចក្តីចុះចិត្ត ជឿស៊ប់ ជាទីជ្រះថ្លានៃចិត្តនិងចេតសិក ដោយក្រៃលែង ។

៧. បគ្គាហោ សេចក្តីព្យាយាមមិនតឹងពេក មិនធូរពេក តែងផ្គងចិត្តទុកដោយ ល្អក្នុងអារម្មណ៍ ។

៨. ឧបដ្ឋានំ មានសតិតាំងមាំ ក្នុងការរក្សាអារម្មណ៍ ទុកឱ្យឋិតនៅប្រាកដក្នុងផ្ទៃវិបស្សនា ។

៩. ឧបេក្ខា មានចិត្តព្រងើយកន្តើយ ក្នុងសង្ខារទាំងពួងដ៏មានកម្លាំងក្លៀវក្លា ។

១០. និក្កន្តិ សេចក្តីត្រេកអរដ៏សុខុមល្អិតក្រៃលែង ក្នុងផ្ទៃនៃវិបស្សនា ក៏កើតឡើង ។

វិបស្សនូបក្កិលេស ទាំង១០យ៉ាងនេះ ជាគ្រឿងសៅហ្មងរបស់វិបស្សនាដោយពិត ព្រោះថា កាលបើឧបក្កិលេសទាំងនេះ កើតឡើងហើយ តែងធ្វើយោគីអ្នកចំរើនវិបស្សនា ឱ្យភ័ន្តភាំង ឱ្យវង្វេងស្មានថា "នេះជាមគ្គផលកើតឡើងដល់អាត្មាអញៗបានសម្រេចមគ្គផលជាទីបំផុតនៃគុណវិសេសហើយ " ក៏ឈប់ផ្អាកសេចក្តីព្យាយាម លែងចំរើន វិបស្សនាតទៅ ជាហេតុបើកឱកាសឱ្យ តណ្ហា

មានៈ ទិដ្ឋិ មានកម្លាំងឡើងវិញ ត្រឡប់ប្រកាន់ថា "នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនប្រាណរបស់អញ " ដូច្នេះទៅវិញ ព្រោះហេតុនេះ ឧបក្កិលេសទាំង ១០យ៉ាង ទើបឈ្មោះថាជាគ្រឿងសៅហ្មងនៃវិបស្សនា ។

យោគីអ្នកបំពេញព្យាយាម ក្នុងការចំរើនវិបស្សនាដោយល្អ កាលបើឧបក្កិលេស ១០យ៉ាង ឧបក្កិលេសណាមួយ កើតឡើង ក៏មិនត្រេកអរ មិនវង្វេង មិនភ័ន្តច្រឡំក្នុងឧបក្កិលេសដែលកើតនោះ មិនឈប់សម្រាកសេចក្តីព្យាយាមរបស់ខ្លួនចោល ដោយសេចក្តីចូលចិត្តច្បាស់ថា " ឧបក្កិលេសទាំងនោះមិនមែនជាផ្លូវ វិបស្សនា មិនមែនជាតួមគ្គ មិនមែនជាតួផលទេ គឺគ្រាន់តែជាអានិសង្សនៃវិបស្សនាប៉ុណ្ណោះ " ។ យោគីនោះក៏មានសេចក្តីត្រិះរិះថា អាត្មាអញនឹងផ្គងព្យាយាម ចំរើនវិបស្សនា ឱ្យមានកម្លាំងក្លៀវក្លា តទៅទៀត ដោយបញ្ញាយល់ច្បាស់ថា "នេះជាមគ្គផល នេះជាវិបស្សនូបក្កិលេស " គឺមិនមែនជាមគ្គផល ។ បញ្ញាដ៏មានកម្លាំងរបស់យោគី ដែលឧបក្កិលេស បំភន្តមិនបាន ឬ មិនវង្វេងទៅតាមឧបក្កិលេស ជាបញ្ញាតាំងនៅដោយល្អចាត់ជាបគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ជាតួនៃ វិបស្សនាទី ៣ ។

## វិសុទ្ធិទី ៦

យោគីអ្នកចំរើនវិបស្សនា កាលបើបានធ្វើមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ឱ្យតាំងនៅដ៏បរិសុទ្ធបរិបូណ៌ហើយ បានកំណត់ទុកក្នុងចិត្តដោយជាក់ច្បាស់ថា "នេះជាតួអរិយមគ្គ នេះជាឧបក្កិលេស មិនមែនជាអរិយមគ្គ " ដូច្នេះហើយ គួរចំរើនវិបស្សនាញ្ញាណទាំង ៩ប្រការ ដែលជាប់មកក្នុងផ្ទៃនៃ បដិបទាញាណ

ទស្សនវិសុទ្ធិ ជាឧបាយដ៏បរិសុទ្ធវិសេស ជាហេតុឱ្យរួចស្រឡះ ចាកឧបក្កិលេស ដើម្បីឱ្យបានអរិយមគ្គ អរិយផលជាន់ខ្ពស់ ជាលំដាប់ តទៅ ។

## វិបស្សនាញ្ញាណ៩ប្រការ(១) នោះគឺ

១. **ឧទយព្វយានុបស្សនាញាណ** បញ្ញាពិចារណាឃើញច្បាស់នូវនិព្វត្តិលក្ខណៈ គឺលក្ខណៈដែលកើតឡើងនៃនាមរូប និងវិបរិណាមលក្ខណៈ គឺលក្ខណៈ ដែលប្រែប្រួល បែកធ្លាយទៅនៃនាមរូប ។

និព្វត្តិលក្ខណៈមាន៥យ៉ាងគឺ **អវិជ្ជា១ តណ្ហា១ ឧបាទាន១ កម្ម១ អាហារ១** , ចំណែកវិបរិណាមលក្ខណៈ ក៏មាន៥យ៉ាងដូចគ្នាគឺ ខន្ធទាំង៥នេះ ខន្ធមួយៗមានលក្ខណៈ១០ៗ គឺការកើតឡើង៥ ប្រែក្លាយរលត់រលាយទៅវិញ៥ រួបរួមខន្ធទាំង៥ ក៏បានទៅជា លក្ខណៈ៥០គត់ ។

ក្នុងរូបខន្ធនោះ យោគីគប្បីពិចារណា ចំពោះនិព្វត្តិលក្ខណៈនៃរូបថា រូបនេះ តែងកើតឡើង ព្រោះអវិជ្ជា ដែលជាកិលេសជាតិ នាំសត្វឱ្យវង្វេងមិនឱ្យដឹងច្បាស់នូវការពិត១ រូបកើតឡើងព្រោះតណ្ហា ដែលជាកិលេសជាតិនាំសត្វឱ្យញាប់ញ័រអន្ទះសា១ រូបកើតឡើងព្រោះឧបាទាន ដែលជាកិលេសជាតិ នាំសត្វឱ្យថ្កក់ជាប់នៅក្នុងសំសារវដ្ត១ រូបកើតឡើងព្រោះកម្ម ជាកុសលនឹងអកុសល ដែលជាផ្លូវនាំសត្វឱ្យគ្រាន់តែអន្ទោលវិលវល់ក្នុងភព១ រូបកើតឡើងព្រោះអាហារ ដែលនាំរូបកាយឱ្យចំរើន១ ។

*(១) ក្នុងទីឯទៀតខ្លះថា វិបស្សនាញ្ញាណ១០ ប្រការ គឺលោកដាក់សម្មសនញ្ញាណខាងដើមរួមជា ១០ តែក្នុងទីនេះមានតែត្រឹម ៩ប្រការ ។*

ចំណែកខាងវិបរិណាមលក្ខណៈនៃរូបនោះ កំគួរយោគីពិចារណាថា "រូបតែងប្រែប្រួលរលត់ទៅ ក៏ព្រោះអវិជ្ជារលត់១ រូបរលត់ទៅក៏ព្រោះតណ្ហារលត់១ រូបរលត់ទៅក៏ព្រោះឧបាទានរលត់១ រូបរលត់ទៅក៏ព្រោះកម្មរលត់១ រូបរលត់ទៅក៏ព្រោះអាហាររលត់១" កាលបើយោគី បានពិចារណាចំពោះនិព្វត្តិលក្ខណៈ៥ វិបរិណាមលក្ខណៈ៥រួមជា ១០ ក្នុងរូបក្ខន្ធមួយដោយប្រការដូច្នេះហើយ គប្បីពិចារណាខាងនិព្វត្តិលក្ខណៈ៥ និងវិបរិណាមលក្ខណៈ៥ របស់វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ តទៅទៀត ដូចគ្នានឹងរូបក្ខន្ធដែរ ផ្សេងគ្នាតែត្រង់អាហារនោះ ឱ្យយកផស្សៈដាក់ជំនួសដូច្នេះ គឺវេទនាកើតឡើងព្រោះការកើតឡើងនៃផស្សៈ , វេទនារលត់ទៅ ក៏ព្រោះរលត់ទៅនៃផស្សៈ , សញ្ញាកើតឡើង ព្រោះការកើតឡើងនៃផស្សៈ , សញ្ញារលត់ទៅ ក៏ព្រោះរលត់ទៅនៃផស្សៈ , សង្ខារកើតឡើង ព្រោះការកើតឡើងនៃផស្សៈ , សង្ខាររលត់ទៅក៏ព្រោះរលត់នៃផស្សៈ . ក្នុងវិញ្ញាណក្ខន្ធ យកអាហារចេញ ហើយដាក់នាមរូបជំនួស ដូច្នេះគឺ វិញ្ញាណកើតឡើងព្រោះការកើតឡើងនៃនាមរូប វិញ្ញាណរលត់ទៅ ក៏ព្រោះរលត់ទៅនៃនាមរូប ។ និព្វត្តិលក្ខណៈ និងវិបរិណាមលក្ខណៈរបស់វេទនា សញ្ញា សង្ខារ វិញ្ញាណ មានសេចក្តីដូចគ្នា ប្លែកគ្នាអំពីលក្ខណៈរបស់រូប ដូចន័យដែលពោលមកប៉ុណ្ណេះ ។

បញ្ញារបស់យោគី ដែលយល់ច្បាស់ក្នុងនិព្វត្តិលក្ខណៈ និងវិបរិណាមលក្ខណៈ គឺទីកើត និងទីរលត់ នៃខន្ធទាំង៥ ដូច្នេះឈ្មោះថា ជាកិច្ចនៃឧទយព្វយានុបស្សនាញាណ ។

**២. ភង្គានុបស្សនាញាណ** បញ្ញារបស់យោគីពិចារណាចំពោះការបែកធ្លាយទៅនៃនាមរូប មកជាអារម្មណ៍មិនបានពិចារណាអំពីទីកើតទីរលត់នៃសង្ខារ និងហេតុបច្ច័យរបស់សង្ខារគឺនាមរូបនោះទេ ។ ព្រោះថាយោគីកាលបើបានចំរើនវិបស្សនា ដល់ថ្នាក់នៃភង្គានុបស្សនាញាណនេះហើយ តែងពិចារណាកំណត់ទុកក្នុងចិត្ត ចំពោះតែផលរបស់នាមរូបប៉ុណ្ណោះ មិនបាច់ពិចារណាស្រាវរកមូលហេតុ របស់នាមរូបនោះទៀតទេ ព្រោះធ្លាប់បានសន្សំស្ទាត់ជំនាញ ចាំជាក់ ចំពោះហេតុបច្ច័យរបស់នាមរូបនោះហើយ ។ សភាវៈដែលមិនទៀង ជាទុក្ខ ជាអនត្តា និងការប្រែប្រួលទៅនៃនាមរូប នេះឯងឈ្មោះថាជាផល ឬជាទោសរបស់នាមរូប ។

យោគីពិចារណាចំពោះតែផលរបស់សង្ខារ គឺនាមរូបប៉ុណ្ណោះ កាលបើពិចារណាឃើញថា "សង្ខារមិនទៀង" ជាហេតុនឹងលះបង់នូវនិច្ចសញ្ញាដែលធ្លាប់សំគាល់ថា ទៀង, ឃើញច្បាស់ថា "សង្ខារ ជាទុក្ខ " ជាហេតុនឹងលះបង់នូវសុខសញ្ញា ដែលធ្លាប់សំគាល់ថា សុខ , ឃើញច្បាស់ថា "សង្ខារជាអនត្តា " ជាហេតុនឹងលះបង់នូវអត្តសញ្ញា ដែលធ្លាប់សំគាល់ថា អត្តា នោះចេញ ។ ចំណែកខាងចិត្តក្នុងប្រភេទណាដែលធ្លាប់មានរូបជាអារម្មណ៍ ក្តី សម្លេង ក្លិន រស ផ្សព្វ ជាអារម្មណ៍ក្តី ចិត្តនោះ រមែងប្រទះនឹងការព្រាត់ប្រាស់ បែកឃ្លាតចាកអារម្មណ៍ទាំងនោះទៅជាធម្មតា . ចិត្តដែលមានវេទនា សញ្ញា ៹សង្ខារជាអារម្មណ៍ ក៏រមែងប្រាសចាកគ្នា . ដូចដំណក់ទឹកភ្លៀងដែលត្រូវខ្យល់បក់ផាត់ . បញ្ញារបស់យោគី ដែលឃើញច្បាស់ចំពោះការបែកធ្លាយទៅនៃសង្ខារ និងការព្រាត់ប្រាស់ចាកអារម្មណ៍របស់ចិត្តដូច្នេះឈ្មោះថាជាកិច្ចនៃភង្គានុបស្សនាញាណ ។

៣. ភយតុបដ្ឋានញ្ញាណ បញ្ញាពិចារណាឃើញសង្ខារទាំងឡាយប្រាកដថាគួរខ្លាច គួរភយ័តក់ស្លុត ។ ទោះបីសង្ខារដែលកើតហើយក្នុងអតីត ឬសង្ខារដែលកំពុងកើត កំពុងរស់នៅក្នុងបច្ចុប្បន្ន ឬក៏សង្ខារដែលនឹងត្រូវកើតឡើងក្នុងអនាគត ក៏សុទ្ធតែជាសភាព គួររអា គួរតក់ស្លុត ទាំងអស់ ។ បញ្ញារបស់យោគី ដែលពិចារណាឃើញសង្ខារទាំងឡាយថា ជាផ្លូវហូរមកនៃទុក្ខភ័យ ដែលបុគ្គលគួររាងចាលដូច្នេះ ឈ្មោះថាជាកិច្ចនៃ ភយតុបដ្ឋានញ្ញាណ ។

៤. អាទីនវានុបស្សនាញាណ បញ្ញារបស់យោគី ពិចារណាឃើញរឿយៗក្នុងសង្ខារទាំងឡាយថាជាសភាព មានទុក្ខទោសច្រើនក្រៃលែង ។ យោគីនោះក៏មិនត្រេកអររីករាយចំពោះសង្ខារទាំងនោះ ដូចជាបុគ្គលមានសេចក្តីអាល័យក្នុងជីវិត លុះដឹងថាភោជនដែលលាយដោយថ្នាំពិស ហើយក៏មិនត្រេកអរចំពោះភោជននោះឡើយ , ពុំនោះដូចបុរសដឹងថាព្រៃមានសត្វសាហាវមានរាជសីហ៍ និងខ្លាជាដើម , ពុំនោះសោត ដូចបុរសដឹងថាទឹកមានក្រពើ , បុរសដែលដឹងថាព្រៃ ដឹងថាទឹក នោះជាទោសហើយ មិនហ៊ានរុកចូលទៅក្នុងព្រៃ មិនហ៊ានចុះទៅក្នុងទឹក ក៏ព្រោះការដឹងនោះជាហេតុ , យោគីពិចារណាឃើញច្បាស់ថា ការកើតឡើងនៃសង្ខារទាំងឡាយ ជាទុក្ខ ជាទោស. ការដែលមិនកើតឡើងទើបជាសុខក្សេមក្សាន្ត ទោះបីបានទទួលសេចក្តីសុខសោមនស្សម្តងៗ ដែលជាអាទីសង្សរបស់សង្ខារ ក៏រមែងមិនត្រេកអរ មិនវង្វេងត្រឹមតែសេចក្តីសុខនិងសោមនស្សប៉ុណ្ណោះ ដឹងច្បាស់ថាសុខនិងសោមនស្សនេះជាឧបក្កិលេសរបស់សង្ខារ ។ បញ្ញារបស់យោគីដែលឃើញទោសរបស់សង្ខារទាំងនោះ ហើយក៏មិនត្រេកអរ មិនភ្លេចខ្លួនក្នុងអំពើរអាក្រក់ផ្សេងៗ ដូច្នេះ

ឈ្មោះថា ជាកិច្ចនៃអាទីនវានុបស្សនាញាណ ។

៥. និព្វិទានុបស្សនាញាណ បញ្ញាពិចារណាឃើញរឿយៗ ក្នុងសង្ខារដែលគួរនឿយណាយ ។ បុគ្គលអ្នកចំរើនវិបស្សនា កាលបើបានចំរើនជាប់រហូតរៀងមក ដល់ថ្នាក់វិបស្សនានេះហើយ ក៏រមែងមានចិត្តនឿយណាយធុញទ្រាន់ ក្នុងកងសង្ខារ ដូចភារៈដ៏ធ្ងន់នៅលើស្មានៃបុរសខ្សោយកំឡាំង ឬដូចរាជសីហ៍ដែលគេដាក់ក្នុងគុហា ឬក៏ដូចដំរីឆទ្ទន្តដែលគេចងទុកក្នុងស្រុក ។ បញ្ញារបស់យោគី ដែលមានសេចក្តីអផ្សុក ធុញទ្រាន់ មិនត្រេកអរ មិនស្តាយស្រណោះសង្ខារ គឺត្រេកអរចំពោះតែប្រយោជន៍ដែលត្រូវបំពេញ ឱ្យកើតមានដរាបបានដល់សន្តិបទ គឺព្រះនិព្វានតែម្យាង ដូចសេចក្តីដែលពោលមកដោយសង្ខេប ដូច្នេះឈ្មោះថា ជាកិច្ចនៃនិព្វិទានុបស្សនាញាណ ។

៦. មុញ្ចិតុកម្យតាញាណ បញ្ញាពិចារណាឃើញទោសរបស់សង្ខារនឿយណាយចាកសង្ខារ ហើយមានប្រាថ្នា ដើម្បីរើខ្លួនឱ្យរួចចាកសង្ខារ ។ បញ្ញាយោគី ដែលប៉ុនប៉ងនឹងរកឧបាយដោះខ្លួនឱ្យផុតចេញ ដូចត្រីជាប់សំណាញ់ ឬដូចកង្កែបជាប់នៅក្នុងមាត់ពស់ ឬក៏ដូចមានព្រៃជាប់ជង់ ពុំនោះដូចបុរសដែលលង់ខ្លួនក្នុងចំណោមនៃសត្រូវ ។ បញ្ញារបស់បុគ្គលអ្នកចំរើនវិបស្សនាឃើញទោសរបស់សង្ខារហើយ ប្រាថ្នារកឧបាយនឹងដកខ្លួន ឱ្យផុតចេញចាកសង្ខារដូច្នេះ ឈ្មោះថាជាកិច្ចនៃមុញ្ចិតុកម្យតាញាណ ។

៧. បដិសង្ខានុបស្សនាញាណ បញ្ញាពិចារណាឃើញរឿយៗ ដោយការយល់ច្បាស់ថា សង្ខារទាំងឡាយ តែងធ្លាក់ទៅក្នុងសាមញ្ញលក្ខណៈ គឺអនិច្ចតា ទុក្ខតា អនត្តតា គ្រប់ឥរិយាបថទាំង៤ ។ កាលបើយោគី

បានបំពេញព្យាយាមធ្វើមុញ្ចិតុកម្យតាញាណ ឱ្យបរិបូណ៌ក្នុងសន្តានហើយ គប្បីលើកសង្ខារទាំងនោះឡើងកាន់ត្រៃលក្ខណៈពិចារណាថា "សង្ខារទាំងឡាយជាសភាពមិនទៀង នាំមកនូវទុក្ខ មិនមែនជាខ្លួនប្រាណ" គឺជាសឹកសត្រូវគួរខ្លាច គួរស្អប់ស្អែង ជាបន្ទុកនៃសេចក្ដីចង្អៀតចង្អល់ ជាទោសមានពិសដ៏ខ្លាំងក្លាក្រៃលែង តែងក្ដៅរោលរាលដោយភ្លើងកិលេសគឺ រាគៈ ទោសៈ មោហៈ និងភ្លើងទុក្ខគឺ ជាតិ ជរា មរណៈ ជាទីប្រជុំចុះ ជាទីអាស្រ័យនៅនៃរោគផ្សេងៗ មានចក្ខុរោគជាដើម ។ កាលបើយោគី អ្នកព្យាយាមបានលើកយកសង្ខារទាំងឡាយឡើងកាន់ត្រៃលក្ខណៈ ដោយប្រការដូច្នេះហើយ គប្បីជញ្ជីងរកឧបាយដើម្បីរំដោះខ្លួនចេញចាកសង្ខារ ដូចបុរសអ្នករុតត្រី កាលដែលចាប់អង្រុតក្រុងចុះទៅក្នុងទឹក ក៏ក្រុងត្រូវពស់មានពិស . បុរសនោះ ស្មានថាជាត្រី ក៏លូកដៃរាវចាប់ត្រូវកពស់ លើកឡើងស្រាប់តែឃើញខ្នួតកពស់៣ជាន់ ទើបស្គាល់ថាជាពស់មានពិស . លុះស្គាល់ហើយក៏ភិតភ័យគិតនឹងរលាស់ពស់ចេញ រួចក៏ទាញពស់ក្រវី ធ្វើឱ្យអន់កម្លាំង មិនឱ្យពស់ចឹកបាន ហើយគ្រវែងចោលអំពីដៃ ដកហ្លួតចេញបាន ក៏មានសេចក្ដីត្រេកអរ គិតថាអាត្មាអញ រួចរំពីពស់មានពិសនេះហើយ ។ ដំណើរនេះយ៉ាងណាមិញ យោគីអ្នកចំរើនវិបស្សនាដែលបានអត្តភាពគឺបញ្ចក្ខន្ធនេះរមែងប្រកាន់ថា "បញ្ចក្ខន្ធនេះជាអញ ជារបស់អញ" លុះដល់កាលខាងក្រោយក៏ដឹងថា "បញ្ចក្ខន្ធនេះមិនមែនជាអញ មិនមែនរបស់អញ គឺជារបស់ប្រកបដោយទោស មានពិសខ្លាំងដ៏ពន្លឹក ដូចពស់វែក មិនគួរប្រកាន់ដោយ តណ្ហា មានៈ ទិដ្ឋិឡើយ" ហើយក៏រកឧបាយនឹងរលាស់បញ្ចក្ខន្ធនេះចោលចេញ ក៏យ៉ាងនោះដែរ ។

ត្រង់ដែលយោគីឃើញសង្ខារមានលក្ខណៈ៣ មានអនិច្ចលក្ខណៈជាដើម ដូចបុរសឃើញខ្នុតកពស់វែកពជាន់ ، ឃើញច្បាស់សង្ខារដែលគួរភ័យតក់ស្លុត ដូចបុរសភិតភ័យនឹងពស់ ، ឃើញសង្ខារ ដែលប្រកបដោយទោស ដូចបុរស ឃើញច្បាស់ថាពស់វែកមានពិសដ៏ខ្លាំង ، ឃើញសង្ខារ ដែលគួរធុញទ្រាន់ ដូចបុរសកំពុងខំចាប់រឹតពស់ឱ្យជាប់នៅក្នុងដៃ ، ឃើញសង្ខារដែលជាភារៈធ្ងន់ ហើយបម្រុងនឹងដោះទម្លាក់ចេញ ដូចបុរសរកឧបាយត្រឹវរលាស់ពស់ចោលចេញ ត្រង់ដែលយោគី លើកសង្ខារឡើងកាន់ត្រៃលក្ខណៈ ដើម្បីផ្ងាញ់ផ្ងាលចិត្ត កុំឱ្យប្រកាន់ថា បញ្ចក្ខន្ធនេះទៀងទាត់ ជាសុខ ជាតួខ្លួនប្រាណនោះ ដូចបុរសចាប់ត្រឹវពស់ធ្វើឱ្យអន់កម្លាំងកុំឱ្យវាបែរចឹកខាំវិញបាន ។ បញ្ញារបស់យោគីដែលកំពុងពិចារណាស្វែងរកឧបាយ ដើម្បីរលាស់ខ្លួនចេញចាកសង្ខារ គឺបញ្ចក្ខន្ធ មានរូបក្ខន្ធជាដើម ដូច្នេះ ចាត់ជាកិច្ចនៃបដិសង្ខានុបស្សនាញាណ ។

៨. សង្ខារុបេក្ខាញាណ បញ្ញារបស់យោគី ពិចារណាឃើញសង្ខារទាំងឡាយថា "សុទ្ធតែសោះសូន្យចាកខ្លួនប្រាណ សត្វបុគ្គលចាកវត្ថុជារបស់ខ្លួន" ហើយក៏មានចិត្តព្រងើយកន្តើយក្នុងសង្ខារមិនមានសោមនស្ស ទោមនស្ស មិនតក់ស្លុតចំពោះសង្ខារ ព្រោះបានពិចារណាឃើញជាក់ច្បាស់ដោយ ភយតុបដ្ឋានញ្ញាណ និង បដិសង្ខានុបស្សនាញាណ នោះសព្វគ្រប់ហើយ ។ យោគីនោះក៏មានចិត្តតាំងនៅស៊ប់ក្នុងឧបេក្ខាជាអ្នក មិនអើពើ មិនស្អប់ មិនស្រឡាញ់សង្ខារ ដូចបុរសដែលលែងលះភរិយាដាច់ស្រឡះចាកគ្នា កាលបើជួបគ្នាម្តងៗ ក៏មានចិត្តព្រងើយកន្តើយ ដោយសំគាល់ថាស្រីនេះមិនមែនជាភរិយានៃខ្លួន។ បញ្ញារបស់បុគ្គលអ្នកចំរើន វិបស្សនា ដែលពិចារណាយល់ច្បាស់ ដូច្នេះហើយមានចិត្ត

ជាឧបេក្ខាក្នុងសង្ខារ បិនជាប់ចំពាក់ក្នុងអារម្មណ៍ ដែលជារាមិសៈដូចជានុយរបស់សង្ខារណាមួយ ។ លំដាប់អំពីនោះវិបស្សនាញាណ របស់យោគីក៏កាន់តែចាស់ក្លា មានកម្លាំងឡើង ពិចារណាស្រូតរូតដើម្បីចេញឱ្យផុតចាករូបធម៌ និងអរូបធម៌ ដែលជាអារម្មណ៍របស់ រូបជ្ឈាន និងអរូបជ្ឈាន ។ វិបស្សនានេះលោកហៅថា វុដ្ឋានគាមិនីវិបស្សនា ជាបញ្ចោមុតថ្លាវិសេស ព្រោះបានឃើញឧបាយសម្រាប់គេចចេញចាកបញ្ចក្ខន្ធ លះបង់សេចក្ដីអាល័យ មិនសង្ឃឹមកក់ក្ដៅក្នុងបញ្ចក្ខន្ធ រមែងសម្លឹងយកមគ្គផល មកជាអារម្មណ៍តែម្យ៉ាង ។ មួយទៀត វិបស្សនាភាវនា ដែលមានបញ្ចក្ខន្ធជាភូមិជាអារម្មណ៍នេះលោកពន្យល់ដោយឧបមា ១២យ៉ាង ដើម្បីឱ្យយោគីភ្លឺច្បាស់អំពី វុដ្ឋានគាមិនីវិបស្សនា មានគាថាដែលរូបរួម សេចក្ដីឧបមាមកដូច្នេះថា

វគ្គុលី កណ្ហសប្បោ ច ឃរំ គោ យក្ខិ ទារកោ

ខុទ្ទំ បិបាសំ សីតុណ្ហំ អន្ធការំ វិសេន ច ។

(ប្រែថា) សត្វប្រចៀវ១ ពស់វែក១ ផ្ទះ១ គោ១ យក្ខិនី១ ទារក១ តម្លាន១ សម្រេក១ ត្រជាក់១ ក្ដៅ១ ងងឹត១ ថ្នាំពិស១ រួមជាឧបមា១២យ៉ាង ។

ឧបមាទី១ អំពីសត្វប្រចៀវ ដែលហើរទៅទំលើដើមស្រគំ មានមែក៥ដោយគិតថា នឹងបានផ្លែស្រគំ លុះវាតោងស្ទាបមើលមែកទី១ ក៏មិនឃើញមានផ្លែ មែកទី២ ទី៣ ទី៤ ទី៥ ក៏មិនឃើញមានផ្លែ វាក៏គិតថាដើមឈើនេះមិនមានផ្លែទេតើ ! រួចក៏លះសេចក្ដីអាល័យអំពីឈើនោះ ហើរទៅទំមែកដែលត្រង់ទៅខាងលើ ងើបក្បាលងើយមើលទៅលើ ហើយក៏ហើរទៅទំដើម

ឈើឯទៀតដែលមានផ្លែ , ដំណើរសេចក្តីឧបមានេះ បណ្ឌិតគប្បីយល់ថា " យោគី ទុកដូចជាសត្វប្រចៀវ , ខន្ធទាំង៥ទុកដូចជាដើមស្រគំមានមែក៥ " , យោគីដែលធ្លាប់ចំពាក់ក្នុងខន្ធ៥ ទុកដូចជាប្រចៀវទំលើដើមស្រគំមានមែក៥ , បញ្ញាសម្រាប់ពិចារណារបស់យោគី ដែលឃើញច្បាស់ថាខន្ធទាំង៥នេះមិនមានអ្វីគួរប្រកាន់ទុក ដូចជាប្រចៀវប្រតោងស្ទាបរកគ្រប់មែកមិនឃើញមានផ្លែ , មុញ្ចិតុកម្យតាញាណ បដិសំខានុបស្សនាញាណ និងសង្ខារុបេក្ខាញាណ ទុកដូចជាប្រចៀវលះសេចក្តីអាល័យថា ឈើនេះគ្មានផ្លែ , អនុលោមញ្ញាណរបស់យោគី ទុកដូចជាប្រចៀវហើរទៅទំមែកត្រង់ទៅលើ , គោត្រភូញាណទុកដូចជាប្រចៀវងើយក្បាលមើលទៅលើ , មគ្គញ្ញាណ ទុកដូចជាប្រចៀវកំពុងហើរទៅ, ផលញ្ញាណ ទុកដូចជាប្រចៀវបានទៅទំលើដើមឈើឯទៀតដែលមានផ្លែ ។

ឧបមាទី២ ពស់វែក ដែលបុរសចាប់ស្មានថាជាត្រី ដូចបានពោលក្នុងបដិសង្ខានុបស្សនាញាណ ដោយពិស្តាររួចហើយ , គោត្រភូញាណ ទុកដូចជាបុរសរលាស់ពស់ចេញ, មគ្គញ្ញាណ ទុកដូចជាបុរសកំពុងរត់ចេញ , ផលញ្ញាណ ទុកដូចជាបុរសបានរត់ទៅដល់ទីកន្លែងដែលផុតភ័យអំពីពស់វែក ។

ឧបមាទី៣ ផ្ទះ ដែលមានមនុស្សកំពុងដេកលក់ស៊ប់ លុះត្រូវភ្លើងឆេះ អ្នកម្ចាស់ផ្ទះក៏ភ្ញាក់ឡើងភ័យម្ទីម្ទាគិតថា អញមិនបាច់កើបយកអ្វីទេ ក៏ស្ទុះរត់យកតែខ្លួនទៅឈរនៅក្នុងទីសុខ , បុគ្គលពាលបុថុជ្ជនដែលធ្លាប់ប្រកាន់ថា អញ ថាខ្លួនរបស់អញ ទុកដូចជាអ្នកម្ចាស់ផ្ទះកំពុងដេកលក់ស៊ប់, ភយតុបដ្ឋានញ្ញាណ ទុកដូចជាម្ចាស់ផ្ទះភ្ញាក់ឡើងឃើញភ្លើងកំពុងឆេះទ្រលោម , មុញ្ចិតុកម្យតាញាណ ទុកដូចជាម្ចាស់ផ្ទះស្ទុះរត់ទៅរកផ្លូវចេញ , អនុលោមញ្ញាណ ទុកដូចជា

ម្ចាស់ផ្ទះបានឃើញផ្លូវចេញ . គោត្រភូញាណ ទុកដូចកំពុងរត់ចេញ . អគ្គញ្ញាណ ទុកដូចជាបានរត់ចេញដោយរហ័ស . ផលញ្ញាណ ទុកដូចជាបានរត់ដល់ទីក្សេមដែលផុតអំពីភ្លើង ។

ឧបមាទី៤ គោ របស់បុរសម្នាក់ ទំលាយក្រោលបោលចេញក្នុងវេលាយប់ ក្នុងពេលដែលម្ចាស់កំពុងដេកលក់ លុះព្រឹកឡើងបុរសដឹងថា គោចេញអំពីក្រោលបាត់ក៏រត់តាមស្នាមជើង . បានឃើញគោរបស់ស្តេចស្មានថាគោរបស់ខ្លួន . លុះស្គាល់ជាក់ថាមិនមែនជាគោរបស់ខ្លួន ហើយក៏ភិតភ័យដោយគិតថាក្រែងស្តេចចាប់ចោទថា ជាចោរ , បុរសនោះក៏រត់គេចខ្លួនទៅដោយរលះរលាំង។ បុគ្គលពាលបុថុជ្ជនដែលធ្លាប់ប្រកាន់ថា អញ ថារបស់អញទុកដូចជាបុរសឃើញគោស្តេចស្មានថាជាគោរបស់ខ្លួន . ការដែលយោគីបានស្គាល់ច្បាស់ថា "សង្ខារទាំងឡាយមិនទៀង ជាទុក្ខ មិនមែនខ្លួនប្រាណទុកដូចជាបុរសស្គាល់ច្បាស់ថាជាគោរបស់ស្តេច" . ភយតុបដ្ឋានញ្ញាណ ទុកដូចជាបុរសភិតភ័យ . មុញ្ចិតុកម្យតាញាណ ទុកដូចជាបុរសបម្រុងនឹងគេចខ្លួន . គោត្រភូញាណ ទុកដូចជាបុរសលះអាល័យអំពីគោ , មគ្គញ្ញាណ ទុកដូចជាបុរសកំពុងរត់ចេញ . ផលញ្ញាណ ទុកដូចជាបុរសដែលបានរត់ទៅកាន់ទីដែលផុតអំពីភ័យ ។

ឧបមាទី៥ យក្ខិនី តាំណែងខ្លួនជាស្ត្រីមនុស្ស ឱ្យបុរសម្នាក់រួមសង្វាសជាមួយក្នុងព្រៃស្មសាន លុះវេលាយប់ យក្ខិនីដឹងថា បុរសនោះដេកលក់ហើយក៏ចូលទៅក្នុងព្រៃស្មសាន ស៊ីសាច់មនុស្សលុះបុរសនោះភ្ញាក់ឡើង ក្រោកដើរទៅតាម ក៏ឃើញយក្ខិនីកំពុងតែស៊ីសាច់មនុស្ស បុរសនោះនឹកឃើញហើយ

ក៏ភិតភ័យដោយគិតថា អញនឹងរត់ចេញ កុំឱ្យវាស៊ីអញទាន់ ។ បុគ្គលពាលបុថុជ្ជន ដែលធ្លាប់ប្រកាន់ថា អញ ថាខ្លួនរបស់អញ ទុកដូចជាបុរសរួមសង្វាស់ជាមួយនឹងយក្ខិនី កាលដែលយោគីដឹងច្បាស់ថា សង្ខារមិនទៀងជាដើម ទុកដូចជាបុរសស្គាល់ជាក់ថា នេះជាយក្ខិនី , ភយតុបដ្ឋានញ្ញាណ ទុកដូចជាបុរសភិតភ័យ , មុញ្ចិតុកម្យតាញ្ញាណ ទុកដូចជាបុរស ប្រុងនឹងរត់ចេញ , គោត្រភូញាណ ទុកដូចជាបុរស លះចេញពីព្រៃស្មសាន , មគ្គញ្ញាណ ទុកដូចជាបុរសកំពុងរត់ចេញ , ផលញ្ញាណ ទុកដូចជាបុរសបានរត់ចេញទៅដល់ទីដែលផុតអំពីភ័យហើយ ។

ឧបមាទី៦ ដំណោលថា ស្ត្រីម្នាក់ ជាអ្នកជាប់ចិត្តនឹងកូន ស្ត្រីនោះកំពុងអង្គុយលើប្រាសាទ លុះឮសំឡេងទារកយំក្នុងចន្លោះផ្លូវគិតថា អ្នកណាបៀតបៀនកូនអញទេដឹង ? ក៏ស្ទុះប៉ាត់រញ៉ាត់ទៅចាប់យកកូនគេស្មានថាជាកូនរបស់ខ្លួន លុះស្គាល់ច្បាស់ថា កូនអ្នកដទៃទេ ក៏ភិតភ័យដាក់ទារកនោះចេញ ក្រឡេកមើលខាងណេះខាងណោះ ដោយគិតថាក្រែងគេចោទថាខ្លួនជាស្រីចោរ រួចរត់ឡើងទៅអង្គុយលើប្រាសាទ កាលដែលយោគី ធ្លាប់ប្រកាន់បញ្ចក្ខន្ធថា អញ ថារបស់អញ ទុកដូចជាស្ត្រីប្រកាន់កូនគេស្មានថាជាកូនខ្លួន ។ យោគីស្គាល់បញ្ចក្ខន្ធច្បាស់ថា "មិនមែនអញ មិនមែនរបស់អញ " ទុកដូចជាស្ត្រីស្គាល់ច្បាស់ថា ទារកនេះជាកូនរបស់អ្នកដទៃ , ភយតុបដ្ឋានញ្ញាណ ទុកដូចជាស្ត្រីភ័យតក់ស្លុត , មុញ្ចិតុកម្យតាញ្ញាណ ទុកដូចជាស្ត្រីកំពុងក្រឡេកមើលខាងណេះ ខាងណោះ , អនុលោមញ្ញាណ ទុកដូចជាស្ត្រីកំពុងដាក់ទារកចេញ , គោត្រភូញាណ ទុកដូចជាស្ត្រីបានដាក់ទារកទារកក្នុងចន្លោះផ្លូវ ,

មគ្គញ្ញាណ ទុកដូចជាស្ត្រីកំពុងរត់ឡើងលើប្រាសាទ . ផលញ្ញាណ ទុកដូចជាស្ត្រីបានឡើងទៅអង្គុយលើប្រាសាទ ។

ឧបមាទី៧ បុរសដែលសេចក្តីឃ្លានគ្របសង្កត់ តែងត្រូវការរកភោជនមានរសឆ្ងាញ់ យ៉ាងណាមិញ , យោគាវចរ កាលបើគម្លាន គឺសំសារវដ្ត ដែលជាអន្លង់នៃទុក្ខភ័យប៉ះពាល់ ក៏រមែងត្រូវការរកភោជន គឺកាយគតាសតិ ដែលមានរសជាប់មិនដាច់ ក៏យ៉ាងនោះដែរ ។

ឧបមាទី៨ បុរសស្រេកទឹកស្ងួតបំពង់ក តែងត្រូវការរកទឹកផឹក យ៉ាងណាមិញ , យោគាវចរ កាលបើសម្រេក គឺសំសារវដ្តប៉ះពាល់ ក៏រមែងត្រូវការរកទឹក គឺអដ្ឋង្គិកមគ្គ ដែលជាផ្លូវដ៏ប្រសើរ មកស្រោចស្រប់ មកផឹក ក៏យ៉ាងនោះដែរ ។

ឧបមាទី៩ បុរសត្រូវត្រជាក់រងាប៉ះពាល់ តែងត្រូវការរកកំដៅ យ៉ាងណាមិញ . យោគាវចរ កាលបើត្រូវត្រជាក់រងា គឺតណ្ហាដែលជាជ័រស្អិតប៉ះពាល់ ក៏រមែងត្រូវការរកភ្លើង គឺអរិយមគ្គ សម្រាប់ដុតរោលកំដៅនូវកិលេស ក៏យ៉ាងនោះដែរ ។

ឧបមាទី១០ បុរសត្រូវកំដៅប៉ះពាល់ តែងត្រូវការរកត្រជាក់ យ៉ាងណាមិញ យោគាវចរ កាលបើក្តៅដោយកំដៅនៃភ្លើង១១កង(១)ក្នុងសំសារវដ្ត ក៏រមែងត្រូវការរកព្រះនិព្វាន ជាទីរម្ងាប់នូវភ្លើង១១កង ក៏យ៉ាងនោះដែរ ។

*(១) ភ្លើងកិលេសភ្លើងទុក្ខ ១១កងគឺ រាគៈ , ទោសៈ , មោហៈ , ជាតិ , ជរា , មរណៈ , សោកៈ , បរិទេវៈ , ទុក្ខ , ទោមនស្ស , ឧបាយាសៈ ។*

ឧបមាទី១១ បុរសប្រទះងងឹត តែងត្រូវការរកពន្លឺ យ៉ាងណាមិញ , យោគាវចរ កាលបើងងឹតគឺអវិជ្ជារួបរឹត ក៏រមែងត្រូវការរកពន្លឺ គឺប្រាជ្ញា ក៏យ៉ាងនោះដែរ ។

ឧបមាទី១២ បុរសត្រូវថ្នាំពិសប៉ះពាល់ តែងត្រូវការរកឱសថសំរាប់បន្សាបនូវថ្នាំពិស យ៉ាងណាមិញ , យោគាវចរ កាលបើត្រូវថ្នាំពិស គឺកិលេសប៉ះពាល់ ក៏រមែងត្រូវការរកព្រះនិញ្វនដែលជាឱសថឈ្មោះអមតៈ សំរាប់បន្សាបពិសគឺកិលេស ក៏យ៉ាងនោះដែរ ។ បញ្ញារបស់យោគី ដែលពិចារណាឃើញច្បាស់ធ្វើចិត្តមិនឱ្យកៀចក្រាញ លុះលង់នៅក្នុងសង្សារ ដូចពណ៌នាមកនេះ ចាត់ជាកិច្ចនៃសង្ខារុបេក្ខាញ្ញាណ ។

មុញ្ចិតុកម្យតាញ្ញាណ , បដិសង្ខានុបស្សនាញ្ញាណ និង សង្ខារុបេក្ខាញ្ញាណ ទាំង៣នេះ មានអត្ថស្រដៀងគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ប៉ុន្តែសង្ខារុបេក្ខាញ្ញាណនេះ លោកចាត់ជាកំពូលនៃវិបស្សនាញ្ញាណ ទាំងអស់ដោយពិត ។

៩. អនុលោមញ្ញាណ បញ្ញារបស់យោគី ដែលបានចំរើនធ្វើឱ្យថ្មីករឿយៗ អនុលោមទៅតាមក្រសែនៃពោធិបក្ខិយធម៌ ទាំង៣៧ប្រការ ជាបញ្ញាប្រកបដោយសទ្ធា វីរិយៈ សតិ សមាធិ មានកំឡាំងក្លៀវក្លាកើតឡើងក្នុងលំដាប់នៃសង្ខារុបេក្ខាញ្ញាណ ពិចារណាឃើញច្បាស់គ្រប់ឥរិយាបថថា "សង្ខារទាំងឡាយ ប្រាកដជាសភាព មិនទៀង ជាទុក្ខ ជាអនត្តា " , បន្ទាប់អំពីនោះ សង្ខារុបេក្ខាញ្ញាណ របស់យោគីនោះក៏ចុះកាន់ភវង្គចិត្ត , លំដាប់អំពីភវង្គនោះ មនោទ្វារាវជ្ជនៈ ( ការពិចារណាភាវរកក្នុងមនោទ្វា ) ក៏កើតឡើង ព្រោះយក

សង្ខារជាអារម្មណ៍ បើយក៏ធ្លាក់ចុះកាន់ភវង្គវិញ ‚ បន្ទាប់អំពីភវង្គនោះទៀត ជវនចិត្តទី១ក៏កើតឡើង ព្រោះធ្វើលក្ខណៈ៣ យ៉ាងណាមួយ ឱ្យជាអារម្មណ៍ ដែលលោកហៅថា បរិកម្ម បន្ទាប់អំពីបរិកម្មនោះ ជវនចិត្តទី២ ក៏កើតឡើង ដែលលោកហៅថា ឧបចារ ‚ បន្ទាប់អំពីឧបចារនោះ ជវនចិត្តទី៣ ក៏កើតឡើងទៀត ដែលលោកហៅថា អនុលោម ត្រង់អនុលោមជវ័ននេះ ក៏គឺអនុលោម-ញ្ញាណនោះឯងព្រោះញាណនេះតែងអនុលោម ប្រព្រឹត្តទៅតាម វិបស្សនាញាណទាំង៨ ខាងដើម ទាំងអនុលោមតាមពោធិបក្ខិយធម៌ទាំង៣៧ផង ព្រោះហេតុនោះញាណនេះទើបលោកពោលថា "អនុលោមញ្ញាណ" ។ អនុលោមញ្ញាណនេះ លោកប្រៀបថា ទុកដូចជាស្តេចធម្មិករាជ ‚ វិបស្សនាញាណទាំង៨ ទុកដូចជាមហាមាត្យទាំង៨នាក់ ជាអ្នកវិនិច្ឆ័យសេចក្តី ‚ ពោធិបក្ខិយធម៌ ៣៧ប្រការ ទុកដូចជារដ្ឋធម្មសាស្ត្រ គឺជាច្បាប់ក្នុងដែនរបស់ស្តេច ។ បញ្ញាពិចារណា អនុលោមតាមកុសលធម៌ ជាចំណែកនៃភាវេតព្វធម៌ ដែលជាធម៌ត្រូវចំរើនឱ្យរឿយ១ ដូចពោលមកនេះឯង ចាត់ជាកិច្ចនៃអនុលោមញ្ញាណ ។

វិបស្សនាញាណទាំង៩ មានឧទយព្វយានុបស្សនាញាណ ជាដើម មានអនុលោមញ្ញាណ ជាទីបំផុត ដូចពណ៌នាមកនេះ រាប់ថាជា ធុរៈទី២ អំពីគន្ថធុរៈ នៃពុទ្ធសាសនា (១) ‚ វិបស្សនាញាណទាំង ៩នេះ លោកចាត់ជា

*(១) ពុទ្ធសាសនាមានធុរៈ២យ៉ាង ទី១ គន្ថធុរៈ ជាទីចងក្រងនូវព្រះត្រៃបិដកជាគោលយ៉ាងធំនាំឱ្យព្រះពុទ្ធសាសនារុងរឿង ‚ ទី២ វិបស្សនាធុរៈ ជាកិច្ចប្រព្រឹត្តបំស្រាលកាមវិតក្ក ព្រោះធ្វើពិចារណា មិនចាំបាច់មានកិច្ចសិក្សាច្រើន រាប់ថាជាធុរៈ ជំនួយបន្ទាប់បន្សំនៃព្រះពុទ្ធ សាសនា ។*

បដិបទាញាណទស្សនវិសុទ្ធិ ជាតួនៃវិបស្សនាទី ៤ ។

## វិសុទ្ធិទី៧

យោគីអ្នកចំរើនវិបស្សនា កាលបើបានចំរើន ស្ទាត់ជំនាញ តាមដំណើរនៃអនុលោមញ្ញាណហើយ លំដាប់នោះ គោត្រភូញាណ ក៏កើតឡើង ។ ពាក្យថា "គោត្រភូញាណនេះជាឈ្មោះប្រាជ្ញាដ៏ថ្លៃវផង់ តែមិនទាន់ចាត់ថាជាមគ្គ ជាផល នៅឡើងទេ " គោត្រភូនេះមានបទវិគ្រោះថា

ឧប្បាទំ អភិភុយ្យតីតិ គោត្រភូ . បវត្តំ អភិភុយ្យតីតិ គោត្រភូ

ប៉ុណ្ណេះ ជាដើមប្រែថា ញាណគឺជាប្រាជ្ញាណោ រមែងគ្របសង្កត់នូវការកើតឡើង នៃនាមរូប ញាណនោះឈ្មោះថា គោត្រភូ . ញាណណោ រមែងគ្របសង្កត់នូវនាមរូបដែលប្រព្រឹត្តទៅ ញាណនោះឈ្មោះថា គោត្រភូ , មួយទៀត ញាណណោ ដែលអាចឈានកន្លងនូវបុថុជ្ជនភូមិ ឬគ្របសង្កត់នូវធមិជាត្រកូលរបស់បុថុជ្ជន ដើម្បីផ្តាច់ពូជកិលេសនៃបុថុជ្ជនហើយរំពឹងពិចារណោ ឈោងចាប់មគ្គ ផល និព្វាន មកជាអារម្មណ៍ ញាណនោះឈ្មោះថា គោត្រភូ , មួយទៀត ញាណណោដែលកំពុងឈានកន្លងចាកភពទាំង៣ ដែលជាត្រើយខាងអាយ ឈោងចាប់យកព្រះនិព្វានដែលជាត្រើយខាងនាយ ញាណនោះឈ្មោះថា គោត្រភូ . ប្រៀបដូចបុរសមានបំណងនឹងលោតកន្លងប្រឡាយទឹកធំ ហើយចាប់ប្រតោងមែកឈើដើម្បីនឹងយោលខ្លួនផ្លោងផ្លោះឱ្យផុតប្រឡាយទឹកទៅត្រើយខាងនាយ ។

ចំណែកខាងអនុលោមញ្ញាណ អាចកំចាត់បង់បានតែត្រឹមងងឹត គឺកិលេសដែលបិទបាំងនូវអរិយសច្ចៈប៉ុណ្ណោះ មិនអាចទាញយកព្រះនិព្វានមកជា

អារម្មណ៍បានទេ មានតែគោត្រភូញាណ ទើបអាចនឹងកំណត់យកនិព្វានមកជាអារម្មណ៍បាន ប្រៀបដូចបុរសអ្នកមានចក្ខុ ជាអ្នកចេះតម្រានក្ខត្តឫក្ស ក្រឡេកមើលទៅដួងព្រះចន្ទក្នុងវេលារាត្រី ចួនវេលានោះព្រះចន្ទក៏មិនភ្លឺច្បាស់ ព្រោះពពកក្រាស់បិទបាំង លំដាប់នោះខ្យល់មួយផ្ទែក ក៏ផាត់ពពកក្រាស់នោះចេញ តែនៅសល់ពពកជាន់កណ្ដាល ខ្យល់មួយផ្ទែក ក៏បក់បោកពពកជាន់កណ្ដាល តែនៅសល់ពពកជាន់ល្អិតស្ដើងស្ដួច ខ្យល់មួយផ្ទែកទៀត ក៏បក់បោកពពកជាន់ល្អិតចេញបានដោយជ្រះស្រឡះ លុះព្រះចន្ទស្រឡះផុតចាកពពកហើយ បុរសអ្នកចេះនក្ខត្តឫក្ស ទើបអាចដឹងច្បាស់នក្ខត្តឫក្សបាន ។ ឯពីតីកិលេសដ៏គ្រោតគ្រាត កណ្ដាល ល្អិត ដែលបិទអរិយសច្ច ទុកដូចជាពពក៣ជាន់បិទបាំងដួងព្រះច័ន្ទ ។ ជវនចិត្ត៣យ៉ាង(១) ទុកដូចជាខ្យល់៣ផ្ទែក ។ គោត្រភូញាណ ទុកដូចជាបុរសអ្នកចេះតម្រាមើលនក្ខត្តឫក្ស ។ ព្រះនិព្វានទុកដូចជាដួងព្រះចន្ទ ។

មគ្គញាណ ដែលកើតមកអំពីគោត្រភូញាណ គឺមានគោត្រភូញាណជាអ្នកឱ្យសញ្ញា ក្នុងការកំចាត់បង់នូវគំនរកិលេស ។ មគ្គញាណនេះរមែងត្រកងយកនូវអរិយទ្រព្យទាំង៧ប្រការ ឱ្យតាំងនៅចំពោះមុខ អាចលះបង់នូវ មិច្ឆាមគ្គ ៨ ប្រការ បិទបាំងនូវទ្វារអបាយភូមិបាន ។

## មគ្គនេះរមែងបាននូវឈ្មោះដោយហេតុ៥យ៉ាងគឺ

សរសេន ដោយកិច្ចរបស់ខ្លួន១ បច្ចនិកេន ដោយការលះធម៌ជាសត្រូវ១ សគុណេន ដោយគុណរបស់ខ្លួន១ អារម្មណេន ដោយអារម្មណ៍១

(១) គឺ បរិកម្មជវន១ ឧបចារជវន១ អនុលោមជវន១ ។

អាគមនេន ដោយដំណើរជាទីមក១ ។

ទី១ ពាក្យថា "កិច្ចរបស់ខ្លួននោះ" អធិប្បាយថា សង្ខារុបេក្ខាញាណ បញ្ញាពិចារណាសង្ខារទាំងឡាយឃើញថា ប្រកបដោយត្រៃលក្ខណៈ , ចិត្តក៏រមែងរួចស្រឡះចាកកិលេសមានរាគៈជាដើម ឈ្មោះថា រួចដោយវិមោក្ខ៣យ៉ាង គឺ អនិមិត្តវិមោក្ខ រួចស្រឡះព្រោះ មិនមានកំណត់ទីនៅនៃកិលេស១ អប្បណិហិតវិមោក្ខ រួចស្រឡះព្រោះ មិនមានទីតំកល់នៅនៃកិលេស១ សុញ្ញតវិមោក្ខ រួចស្រឡះ ព្រោះសូន្យឈឹងចាកកិលេស១ , បើពិចារណាឃើញ អនិច្ចលក្ខណៈឈ្មោះថា រួចស្រឡះចាកកិលេស ដោយអនិមិត្តវិមោក្ខ , បើពិចារណាឃើញ ទុក្ខលក្ខណៈឈ្មោះថា រួចស្រឡះដោយ អប្បណិហិតវិមោក្ខ , បើពិចារណាឃើញ អនត្តលក្ខណៈឈ្មោះថា រួចស្រឡះដោយ សុញ្ញតវិមោក្ខ ។

ទី២ពាក្យថា "លះធម៌ជាសត្រូវនោះ" គឺមគ្គ រមែងលះបង់និច្ចសញ្ញា ដែលជាសត្រូវ ជាគូប្រឆាំងចំពោះអនិច្ចានុបស្សនា , លះបង់សុខសញ្ញា ដែលជាសត្រូវចំពោះទុក្ខានុបស្សនា , លះបង់អត្តសត្តបុគ្គលសញ្ញា ( សេចក្ដីសំគាល់ថាខ្លួន ថាសត្វ ថាបុគ្គល ) ដែលជាសត្រូវចំពោះ អនត្តានុបស្សនា ។

ទី៣ ពាក្យថា "គុណរបស់ខ្លួននោះ" បានដល់មគ្គដែលបង្ក្រាបនូវកិលេសទាំងពួងមាន រាគៈ ជាដើម ឱ្យស្ងប់សូន្យឈឹង មិនឱ្យកើតនិមិត្តជាដើមតទៅទៀត ។

ទី៤ ពាក្យថា "អារម្មណ៍នោះ" បានដល់មគ្គដែលទាញយកព្រះនិព្វានមកជាអារម្មណ៍បាន ។

ទី៥ ពាក្យថា "ដំណើរជាទីមកនោះ" បានដល់ដំណើរជាទីមក២យ៉ាងគឺ

វិបស្សនាគមនំ ដំណើរជាទីមកនៃវិបស្សនាដែលឋិតនៅមាំ១ ផលោមគ្គាគមនំ ដំណើរជាទីមកនៃមគ្គ ( ដែលប្រព្រឹត្តទៅ ) ចំពោះផល១ ។

## មគ្គញ្ញាណ អាចលះសំយោជនៈ

មគ្គដែលជាក្រសែ ឬជាប្រឡាយហូរទៅកាន់ព្រះនិព្វាន លោកហៅថា សោតាបត្តិមគ្គ . បញ្ញាដែលដឹងច្បាស់ក្នុងការលះសំយោជនៈ ឱ្យដាច់ស្រឡះ ហៅថា "មគ្គញ្ញាណ" . មគ្គញ្ញាណនេះចែកចេញជា៤គឺ សោតាបត្តិមគ្គញ្ញាណ លះសំយោជនៈបាន ៣យ៉ាងគឺ សក្កាយទិដ្ឋិ សេចក្តីឃើញថា កាយរបស់ខ្លួន១ វិចិកិច្ឆាសេចក្តីសង្ស័យ១ សីលព្វតបរាមាសៈ សេចក្តីប្រកាន់សីលវត្ត១ . សកទាគាមិមគ្គញ្ញាណ លះសំយោជនៈបាន៣ដូចគ្នា តែបានធ្វើកាមរាគៈតម្រេកក្នុងកាម និងបដិឃៈ ផ្ទាំងថ្នាក់ចិត្តឱ្យស្រាលស្តើង . អនាគាមិមគ្គញ្ញាណ លះសំយោជនៈបាន៥គឺលះសំយោជនៈ៣ខាងដើម ព្រមទាំងធ្វើកាមរាគៈនិងបដិឃៈ ឱ្យដាច់ស្រឡះ អរហត្តមគ្គញ្ញាណ . លះសំយោជនៈបាន១០ គឺ រូបរាគៈ តម្រេកក្នុងរូបធម៌ . អរូបរាគៈ តម្រេកក្នុងអរូបធម៌ . មានះប្រកាន់រំងរូស . ឧទ្ធច្ចៈរាយមាយ . អវិជ្ជា មិនដឹងពិត . រាប់យកខាងដើម៥ផងត្រូវជា១០យ៉ាង ។ ចិត្តនិងចេតសិក ដែលបរិសុទ្ធ ផូរផង់ក្រៃលែង កើតឡើងក្នុងលំដាប់នៃមគ្គញ្ញាណ របស់ព្រះអរិយៈ ទទួលសោយនូវកម្រៃអារម្មណ៍នោះ ហៅថា "ផលញ្ញាណ" . ផលញ្ញាណនេះក៏មាន៤យ៉ាងដូចគ្នា ។

## កិច្ចរបស់មគ្គញ្ញាណ៤យ៉ាង

មគ្គញ្ញាណមួយៗមានកិច្ចបួនៗ ដែលប្រព្រឹត្តទៅក្នុងអរិយសច្ចទាំង៤ ក្នុងខណៈដំណាលគ្នា មិនមុនមិនក្រោយ . រួមកិច្ចរបស់មគ្គញ្ញាណបួនៗ ក្នុងអរិយសច្ចទាំង៤ ត្រូវជាកិច្ច១៦ ហៅថា "សោឡសកិច្ច" ។ កិច្ចរបស់មគ្គញ្ញាណ៤នោះគឺ បរិញ្ញាកិច្ច កិច្ចខាងការកំណត់ដឹងកងទុក្ខ១ បហានកិច្ច កិច្ចខាងការលះសមុទយៈគឺតួតណ្ហា១ សច្ឆិកិរិយាកិច្ច កិច្ចខាងការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន១ ភាវនាកិច្ច កិច្ចខាងការចំរើននូវអរិយមគ្គ១ . កិច្ចទាំង៤យ៉ាងនេះសម្រេចបានក្នុងអរិយសច្ច៤ ក្នុងខណៈជាមួយគ្នា ដូចសេចក្តីពន្យល់ដើម្បីឱ្យបុគ្គលអ្នកសិក្សា ដឹងបានដោយងាយ . លោកសំដែងឧបមាដូចប្រទីប (ដែលគេអុជ) រមែងសម្រេចកិច្ចបាន៤យ៉ាងក្នុងខណៈដំណាលគ្នា មិនមុនមិនក្រោយ ដូចតទៅនេះ

## កិច្ចរបស់ប្រទីប៤យ៉ាងនោះគឺ

វដ្តឹ ឈាបេតិ ឆេះត្រង់ប្រឆេះ១ អន្ធការំ វិធមតិ កំចាត់នូវងងឹត១ អាលោកំ បរិវិទំសេតិ បញ្ចេញនូវពន្លឺ១ សិនេហំ បរិយាទិយតិ ស្រូបបឹតយកប្រេង១ . ប្រទីបអាចសម្រេចកិច្ច៤យ៉ាងបាន យ៉ាងណាមិញ . មគ្គញ្ញាណក៏សម្រេចកិច្ចបាន៤ ក្នុងអរិយសច្ចទាំង៤ ក៏យ៉ាងនោះដែរ ។ មួយទៀត ព្រះអាទិត្យ កាលរះឡើង រមែងសម្រេចកិច្ចបាន៤យ៉ាង ក្នុងខណៈជាមួយគ្នា មិនមុនមិនក្រោយ ដូចខាងក្រោមនេះ ។

## កិច្ចរបស់ព្រះអាទិត្យ៤យ៉ាងនោះគឺ

រូបគតានិ ឱភាសេតិ ឆ្លុះបំភ្លឺឱ្យឃើញរូបទាំងឡាយបាន១ អន្ធការំ វិធមតិ កំចាត់នូវងងឹត១ អាលោកំ ទស្សេតិ សំដែងចេញនូវពន្លឺ១ សីតំ បដិប្បស្សម្ភេតិ រម្ងាប់នូវត្រជាក់១ . ព្រះអាទិត្យកាលបើរះឡើងភ្លាម អាចសម្រេចកិច្ច៤យ៉ាងបាន យ៉ាងណាមិញ . មគ្គញ្ញាណរមែងសម្រេចកិច្ច ៤យ៉ាងបាន ក៏យ៉ាងនោះដែរ , មួយវិញទៀត នាវាក៏រមែងសម្រេចកិច្ចបាន៤ យ៉ាងក្នុងខណៈជាមួយគ្នា មិនមុនមិនក្រោយ ។

## កិច្ចរបស់នាវា៤យ៉ាងនោះគឺ

ឱរិមំ តីរំ បជហតិ លះនូវត្រើយខាងអាយ១ សោតំ ឆិន្ទតិ កាត់នូវខ្សែទឹក១ ភណ្ឌំ វហតិ នាំយកនូវគ្រឿងផ្ទុកបាន១ បារិមំ តីរំ អប្បេតិ ឈមមុខ ឬអែបទៅត្រើយខាងនាយ១ , នាវាអាចសំរេចកិច្ច៤ យ៉ាងបាន យ៉ាងណាមិញ . មគ្គញ្ញាណ ក៏រមែងសម្រេចកិច្ច៤យ៉ាងបាន ក៏យ៉ាងនោះដែរ ។ ក្នុងមគ្គជវនវិថីនោះ លោកកំណត់ថា បើកុលបុត្រអ្នកមាន ប្រាជ្ញា ជាទន្ធាភិញ្ញា ត្រាស់ដឹង ដោយយឺតយូរ ជវនចិត្តលឿនទៅបាន៧ខណៈ គឺជវនចិត្តទី១ ឈ្មោះបរិកម្ម ជវនចិត្តទី២ ឈ្មោះឧបចារ , ជវនចិត្តទី៣ ឈ្មោះ គោត្រភូ , ជវនចិត្តទី៤ ជាតួមគ្គ , ជវនចិត្តទី៥ ទី៦ ទី៧ ( បីនេះជាតួផល ) ។ បើកុលបុត្រមានប្រាជ្ញា ជាខិប្បាភិញ្ញា ត្រាស់ដឹង ដោយឆាប់រហ័សនោះមិនមាន បរិកម្មកជវនទេ គឺជវនចិត្តទី១ ឈ្មោះឧបចារ , ទី២ឈ្មោះអនុលោម . ទី៣ឈ្មោះគោត្រភូ ទី៤ជាតួមគ្គ ទី៥ ទី ៦ ទី៧ បីនេះជាតួផល , អាស្រ័យហេតុ

នេះ ទើបលោកពោលថា ផលចិត្ត តែងកើត ឡើងក្នុងលំដាប់នៃមគ្គចិត្ត ក្នុងរវាង២ខណៈខ្លះ ៣ខណៈខ្លះ ហើយទើបធ្លាក់ចុះកាន់ភវង្គចិត្ត , មុនដំបូងអំពីភវង្គចិត្តនោះ មនោទ្វារាវជ្ជនចិត្ត ដែលឈមទៅរកមគ្គផលក៏កើតឡើង , បន្ទាប់អំពីមនោទ្វារាវជ្ជនចិត្តនោះ បច្ចវេក្ខណញ្ញាណ គឺប្រាជ្ញាដែលសម្រាប់ពិចារណានូវមគ្គផល និព្វាន និងកិលេស ដែលលះបានហើយ ឬអនុសយក្កិលេសដែលនៅសល់ទាំងប៉ុន្មានក៏កើតឡើង ។ បញ្ញារបស់យោគីដែលប្រកបដោយអរិយមគ្គទាំង៤មានសោតាបត្តិមគ្គជាដើម ដែលអាចកំចាត់នូវសំយោជនក្កិលេសបាន ដូចពោលមកនេះ ឈ្មោះថា "ញាណទស្សនវិសុទ្ធិ" ជាតួនៃវិបស្សនាទី៥ ចាត់ជាកំពូលនៃវិបស្សនាញាណទាំងអស់ ដូចបានរៀបរាប់មកដោយសង្ខេបប៉ុណ្ណោះ , លំដាប់អំពីនេះនឹងសំដែងអានិសង្សនៃបញ្ញាភាវនាដោយសង្ខេបតទៅទៀត ។

## អានិសង្សនៃបញ្ញាភាវនានេះមាន៤យ៉ាង

អានិសង្សរបស់បញ្ញាភាវនានេះ មានច្រើនយ៉ាង តែបើពោលដោយរួបរួម មាន៤ យ៉ាង ដូចសេចក្តីវែកញែកតទៅនេះ

ទី១. នានាកិលេសវិទ្ធំសនំ កំចាត់នូវកិលេសផ្សេងៗ មានលោភៈជាដើម ។

ទី២. អរិយផលរសានុភវនំ ទទួលត្រេកផឹកនូវរសនៃអរិយផល មានសោតាបត្តិផល ជាដើម ។

ទី៣. និរោធសមាបត្តិសមាបជ្ជនសមត្ថតា អាចវាងវៃចូលកាន់

និរោធ សមាបត្តិបាន ។

ទី៤. អាហុនេយ្យភាវាទិសិទ្ធិ សម្រេចនូវភាពជា អាហុនេយ្យបុគ្គល ជាដើម ។ បុគ្គលអ្នកបរិបូណ៌ដោយបញ្ញា រមែងកំចាត់នូវកិលេសផ្សេងៗ ទោះបីមិនទាន់ដាច់ស្រឡះ ក៏លះបានដោយអំណាចនៃតទង្គប្បហាន និង វិក្ខម្ភនប្បហាន លុះបែកធ្លាយរាងកាយ ឃ្លាតចាកលោកនេះទៅ ក៏រមែងទៅ កើតក្នុងសុគតិ សួគ៌ទេវលោក , នេះចាត់ជាអានិសង្សនៃបញ្ញាជាលោកិយ កាល បើបានកំចាត់នូវកិលេសផ្សេងៗ ដាច់ស្រឡះដោយអំណាចនៃ សមុច្ឆេទប្បហាន ក៏ចាត់ជាអានិសង្ស ជាលោកុត្តរ នេះជាអានិសង្ស នៃបញ្ញាភាវនា ទី១ ។

កាលទទួលនូវរសនៃអរិយផលទាំង៤ មានសោតាបត្តិផល ជាដើម ដែល ជាគុណជាត បរិសុទ្ធ ផុតចាកឧបក្កិលេសទាំងពួង ជាអានិសង្សនៃ បញ្ញាភាវនាទី ២ ។

ការចូលកាន់និរោធសមាបត្តិ មិនមែនជាវិស័យ របស់បុថុជ្ជនទេ សូម្បីតែជាអរិយបុគ្គលជា សោតាបន្ន , សកទាគាមី , អនាគាមី , អរហន្ត ដែលជាសុក្ខវិបស្សក: ក៏ចូលកាន់និរោធសមាបត្តិ ពុំបានឡើយ លុះតែអរិយ បុគ្គល២ពួកគឺ អនាគាមី និងអរហន្ត ដែលប្រកបដោយបដិសម្ភិទា ធ្លាប់បាន សមាបត្តិ៨ប្រការ ទើបចូលនិរោធសមាបត្តិបាន ។

បុព្វកិច្ចរបស់លោកអ្នកចូលនិរោធសមាបត្តិនោះមាន៤យ៉ាងគឺ

ទី១- នានាពទ្ធអវិកោបនំ ធ្វើបរិក្ខារដែលជាប់នៅផ្សេងៗមិនឱ្យកំរើក គឺបាត្រ ចីវរ ឬគ្រែតាំង ឬក៏បរិក្ខារណាមួយដែលមិនជាប់ជាមួយនឹងខ្លួន ជារបស់ ដែលជាប់នៅក្នុងទីផ្សេងៗពីគ្នា . កាលបើ អរិយបុគ្គលពេញចិត្តនឹងចូលនិរោធ

សមាបត្តិនោះ ត្រូវអធិដ្ឋាន បរិក្ខារនោះថា

ឥទញ្ចិទញ្ច ឥមស្មឹ សត្តាហព្ភន្តរេ មា អគ្គិនា ឈាយតុ មា ឧទកេន វុយ្ហតុ មា វាតេន វិទ្ធំសតុ មា ចោរេហិ ហរិយតុ មា ឧន្ទុរាទីហិ ខជ្ជតុ

ប្រែថា "បរិក្ខារនេះខ្លះ នុ៎ះខ្លះសូមកុំឱ្យភ្លើងឆេះបាន , កុំឱ្យទឹកបន្សាត់ , កុំឱ្យខ្យល់បក់ពោក , កុំឱ្យចោរលួច , កុំឱ្យសត្វមានកណ្ដុរជាដើមគោរកាត់ ក្នុងចន្លោះ៧ថ្ងៃនេះឡើយ ! " កាលបើបានអធិដ្ឋានយ៉ាងនេះហើយអន្តរាយណា មួយ មិនមានដល់បរិក្ខាររបស់លោកអ្នកចូលនិរោធនោះអស់ ៧ ថ្ងៃឡើយ ។

ទី២- **សង្ឃប្បដិមាននំ** ការរង់ចាំរបស់សង្ឃ គឺវេលាដែលសង្ឃត្រូវធ្វើ សង្ឃកម្ម ជាទំនៀបរបស់ព្រះសង្ឃ . កាលបើភិក្ខុណាមួយមកមិនទាន់ដល់ ព្រះសង្ឃ មិនត្រូវប្រញាប់ធ្វើសង្ឃកម្មមុនទេ ព្រោះហេតុនោះ អ្នកពេញចិត្ត នឹងចូលនិរោធសមាបត្តិ គប្បី ពិចារណាចំពោះការរង់ចាំរបស់សង្ឃ យ៉ាងនេះថា " ប្រសិនបើអាត្មាអញចូលនិរោធសមាបត្តិ អង្គុយអស់៧ថ្ងៃ ចូនព្រះសង្ឃ ក៏ត្រូវ ការនឹងធ្វើសង្ឃកម្មណាមួយ មានញត្តិកម្មជាដើម អាត្មាអញនឹងចេញមិនបាច់ ឱ្យភិក្ខុណាមួយ មកហៅអាត្មាអញទាន់ឡើយ " . យោគីភិក្ខុ កាលបើបានធ្វើ យ៉ាងនេះហើយទើបចូលនិរោធសមាបត្តិ ក៏រមែងចេញអំពីសមាបត្តិនោះភ្លាម ក្នុងសម័យនោះដោយខ្លួនឯង ។

ទី៣- **សត្ថុ បក្កោលនំ** ការទទួលស្ដាប់ព្រះពុទ្ធដីការបស់ព្រះសាស្ដា គឺភិក្ខុគប្បីពិចារណាចំពោះព្រះពុទ្ធដីកាយ៉ាងនេះថា "បើអាត្មាអញចូលនិរោធ សមាបត្តិ អង្គុយអស់៧ថ្ងៃ ព្រះសាស្ដាទ្រង់បញ្ញត្តសិក្ខាបទ ឬ ទ្រង់សំដែងធម៌

ចំពោះហេតុដែលកើតឡើង អាត្មាអញនឹងចេញមិនបាច់ឱ្យភិក្ខុណាមួយ មកហៅអាត្មាអញទាន់ឡើយ " . យោគីភិក្ខុ កាលបើបានធ្វើយ៉ាងនេះហើយ ទើបចូលនិរោធសមាបត្តិ ក៏រមែងចេញអំពីនិរោធសមាបត្តិនេះបានភ្លាម ក្នុងសម័យនោះដោយខ្លួនឯង ។

ទី៤- **អទ្ធានបរិច្ឆេទោ** ការកំណត់កាលនៃជីវិត គឺយោគីភិក្ខុគប្បីពិចារណាមុនថា "អាយុសង្ខារ របស់អាត្មាអញ នឹងប្រព្រឹត្តទៅបាន៧ថ្ងៃ ឬមិនបានទេ " ដូច្នេះហើយសឹមចូលកាន់និរោធសមាបត្តិចុះ . បើភិក្ខុចូលទាំងមិនបានពិចារណាអាយុសង្ខារ ដែលគួររស់ទៅក្នុងរវាង៧ថ្ងៃទេ ឯនិរោធសមាបត្តិរបស់ភិក្ខុនោះ មិនអាចការពារនូវសេចក្តីស្លាប់បានទេ ព្រោះហេតុនោះ យោគីភិក្ខុ គប្បីពិចារណាដល់កាលបរិច្ឆេទនៃជីវិតមុនសិន សឹមចូលនិរោធសមាបត្តិ . ព្រោះថា បុព្វកិច្ចនេះឯង ត្រូវតែយោគីភិក្ខុ អធិដ្ឋាន ពិចារណានឹងខានពុំបាន ។

បុគ្គលស្លាប់ និងអរិយបុគ្គល ដែលកំពុងចូលកាន់និរោធសមាបត្តិ តើមានសេចក្តីប្លែកគ្នាដូចម្តេចខ្លះ ? ប្លែកគ្នាដូច្នេះ គឺបុគ្គលស្លាប់រលត់កាយសង្ខារ , វចីសង្ខារ , ចិត្តសង្ខារ ទាំងអាយុក៏អស់ , ចំហាយភ្លើងធាតុនិងឥន្ទ្រិយក៏ស្ងប់រម្ងាត់បែកធ្លាយ . ឯអរិយបុគ្គលដែលចូលកាន់និរោធសមាបត្តិ រលត់អស់តែកាយសង្ខារ ,វចីសង្ខារ , ចិត្តសង្ខា ប៉ុណ្ណោះ តែអាយុមិនទាន់អស់ . ទាំងចំហាយភ្លើងធាតុ និងឥន្ទ្រិយ ក៏មិនទាន់ស្ងប់រម្ងាប់ , មិនទាន់បែកធ្លាយ ។ ការចូលកាន់និរោធសមាបត្តិ របស់អរិយបុគ្គលដោយអារម្មណ៍ ដ៏ធូរផង់ បែរឈម ទៅរកព្រះនិព្វានតែម្យ៉ាង នេះជាអានិសង្សនៃ បញ្ហាភាវនាទី ៣ ។

បុគ្គលដែលបានឈ្មោះថា អាហុនេយ្យ . បាហុនេយ្យ . ទក្ខិណេយ្យ អញ្ជលិករណីយនោះ ចំពោះតែអរិយបុគ្គល៤ពួក ដែលប្រកបដោយបញ្ញាលោកុត្តរ មានសោតាបន្នបុគ្គលជាដើមប៉ុណ្ណោះ ឯបុថុជ្ជន( ក្នុងនិទ្ទេសនេះ ) លោកពោលថា " មិនបានទទួលភាពថាជាអាហុនេយ្យ ជាដើមដូច្នេះទេ " ។ សោតាបន្នបុគ្គល ដែលបានចំរើនចំពោះមគ្គញ្ញាណទី១ នោះមានពពួកដូចខាងក្រោមនេះ ។

## សោតាបន្នបុគ្គល៣ពួកគឺ

ទី១- **សត្តក្ខត្តុបរមៈ** ប្រែថា "មានជាតិ៧ជាយ៉ាងក្រៃលែង " សំដៅយកអរិយបុគ្គល ដែលមានឥន្ទ្រិយ៥យ៉ាង មានសទ្ធិន្ទ្រិយជាដើម ដ៏ទន់ថយ ទាំងវិបស្សនាបញ្ញា ក៏ទន់ខ្សោយ ត្រូវអន្ទោលទៅកាន់សុគតិភពអស់៧ជាតិទៀត ទើបបានអរហត្តផល ធ្វើនូវទីបំផុតទុក្ខបាន ។

ទី២- **កោលង្កោលៈ** ប្រែថា "ចេញចាកត្រកូល ទៅកាន់កូល " សំដៅយកអរិយបុគ្គល ដែលមានឥន្ទ្រិយ ជាកណ្តាល ទាំងវិបស្សនា ក៏យ៉ាងកណ្តាល ត្រូវព្រាច់រង្គាត់ចាប់កំណើតអស់ត្រកូលពីរឬបីទៀត ទើបធ្វើនូវទីបំផុតទុក្ខបាន ។

ទី៣- **ឯកពីជី** ប្រែថា "មានពូជតែម្តងទៀត " សំដៅយកអរិយបុគ្គលដែលមានឥន្ទ្រិយបរិបូណ៌ក្រៃលែង ទាំងវិបស្សនាក៏ចាស់ក្លា ត្រូវកើតក្នុងភពជារបស់មនុស្ស ត្រឹមមួយជាតិទៀត ទើបធ្វើនូវទីបំផុតទុក្ខបាន ។

សកទាគាមិ ប្រែថា " ត្រឡប់មកកាន់លោកនេះម្តងទៀត " បើជាឈ្មោះ បុគ្គល ហៅថា សកទាគាមី សំដៅយកអរិយបុគ្គលដែលបានចំរើន

មគ្គញ្ញាណទី២ ត្រូវមកកាន់មនុស្សលោកនេះម្តងទៀតជាកំណត់ ដូចឯកពីជីដែរ ទើបធ្វើនូវទីបំផុតទុក្ខបាន ។

អនាគាមិ ប្រែថា "មិនត្រឡប់មកវិញ" បើជាឈ្មោះបុគ្គលហៅថា អនាគាមី សំដៅយកអរិយបុគ្គល ដែលបានចំរើនមគ្គញ្ញាណទី៣ តែងទៅកើតក្នុងព្រហ្មលោកជាន់សុទ្ធាវាសទាំង៥ សុទ្ធាវាសណា(១)មួយ លោកមិនត្រឡប់មកកើត ក្នុងលោកនេះវិញទេ តែងបរិនិព្វានក្នុងជាន់សុទ្ធាវាសនោះតែម្តង ។

## អនាគាមិបុគ្គលនោះមាន៥ពួកគឺ

ទី១. អន្តរាបរិនិព្វាយី លោកទៅកើតក្នុងសុទ្ធាវាស ហោបួយតែមិនទាន់ដល់ពាក់កណ្តាលអាយុនៅឡើយ លោកក៏បរិនិព្វាន ក្នុងទីនោះតែម្តង ។

ទី២. ឧបហច្ចបរិនិព្វាយី លោកឋិតនៅក្នុងទីនោះកន្លងហួសពាក់កណ្តាលអាយុ ទើបបរិនិព្វាន ។

ទី៣. អសង្ខារបរិនិព្វាយី លោកញ៉ាំងអរហត្តមគ្គឱ្យកើតក្នុងសន្តានបានដោយងាយ មិនបាច់ព្យាយាមដោយលំបាក ។

ទី៤. សសង្ខារបរិនិព្វាយី លោកញ៉ាំងអរហត្តមគ្គឱ្យកើតក្នុងសន្តានប្រកបដោយសេចក្តីព្យាយាម ដ៏ក្លាខ្លាំង ។

ទី៥. ឧទ្ធំសោតអកនិដ្ឋគាមី លោកទៅកើតក្នុងជាន់សុទ្ធាវាសណាមួយ លុះច្យុតចាកទីនោះហើយ ក៏ទៅកើតក្នុងជាន់សុទ្ធាវាស ខាងលើ

*(១) សុទ្ធាវាស ៥ គឺ អវិហា១ អតប្បា១ សុទស្សា១ សុទស្សី អកនិដ្ឋា១ ពានជាឈ្មោះថា សុទ្ធាវាស ព្រោះជាស្ថានព្រហ្ម ជាន់ខ្ពស់បំផុត ជាទីនៅនៃបុគ្គលអ្នកបរិសុទ្ធគឺ អរិយបុគ្គលទី ៣ ។*

ដរាបដល់អរកនិដ្ឋភព ហើយទើបបរិនិព្វានក្នុងទីនោះ ។ អរហា ឬ អរហន្ត ប្រែថា "លោកអ្នកឆ្ងាយចាកកិលេសគ្រប់យ៉ាង" សំដៅយកលោកដែលបាន អរហត្តផល ។

ការបាននូវភាពជាអរិយបុគ្គល តាមលំដាប់ ទាបខ្ពស់នោះ លោកកំណត់ បារមីធម៌ ទន់ខ្ចី ចាស់ក្លា តាមលំដាប់ថ្នាក់ នេះជាអានិសង្សនៃបញ្ញា ភាវនាទី៤ ។

**វិសុទ្ធិ ទាំង៧ប្រការ** ដូចសេចក្តីអធិប្បាយមកនេះ បើសង្រ្គោះចូល ក្នុងធម្មក្ខន្ធ៣ គឺ សីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាក្ខន្ធនោះដូច្នេះគឺ សីលវិសុទ្ធិ សង្រ្គោះចូលក្នុងសីលក្ខន្ធ , ចិត្តវិសុទ្ធិ សង្រ្គោះចូលក្នុង សមាធិក្ខន្ធ , វិសុទ្ធិទាំង៥ ក្រៅពីនេះ សង្រ្គោះចូលក្នុងបញ្ញាក្ខន្ធ ។

ពណ៌នាម ក្នុងវិសុទ្ធិ៧ ប្រការព្រមទាំងអានិសង្ស នៃបញ្ញាភាវនា ចប់ដោយសង្ខេបតែប៉ុណ្ណេះឯង ។

**ពុទ្ធសាសនំ សកលលោកស្មឹ ផរតុ !**

សូមឱ្យព្រះពុទ្ធសាសនាផ្សាយទៅក្នុងសកលលោក !

ភ្នំពេញ ថ្ងៃ ២ ឆ្នាំម្សាញ់សប្តស័ក ព.ស ២៥០៨ - គ.ស ១៩៦៥

ព្រះមុនីកោសល **សួរ ហាយ**

អធិបតីរងនៃក្រុមជំនុំព្រះត្រៃបិដក

ចៅអធិការវត្តនិរោធរង្សី

# សេចក្តីឧទ្ទិស

យើងខ្ញុំព្រះករុណា មានសទ្ធាចំពោះព្រះពុទ្ធសាសនា បានបោះពុម្ពសៀវភៅ **វិសុទ្ធិកថា** នេះដើម្បីចែក ជូនជាធម្មទាន , ជាប្រទីបបំភ្លឺផ្លូវចំពោះពុទ្ធបរិស័ទ ទាំងឡាយណា ដែលលោកត្រូវការ ប្រាថ្នាចង់សិក្សាប្រតិបត្តិឱ្យបានជ្រៅជ្រះ ក្នុងព្រះពុទ្ធសាសនា ។ សូមតំកល់សៀវភៅ **វិសុទ្ធិកថា** នេះទុកជាធម្មសម្បត្តិ ក្នុងព្រះពុទ្ធ សាសនាតរៀងទៅ ។

យើងខ្ញុំព្រះករុណា សូមអរព្រះគុណ ចំពោះព្រះតេជគុណព្រះពុទ្ធឃោសាចារ្យ **ហេង លាងហោ** ចៅអធិការវត្ត ព្រះពុទ្ធមានបុណ្យ ដែលលោកផ្តល់ឱ្យ យើងខ្ញុំព្រះករុណា មានឱកាសបានធ្វើនូវធម្មទាននេះ ។

**សូមឧទ្ទិសកុសល** ផលបុណ្យ នៃសទ្ធា និងការបោះពុម្ពនេះ ជូនដល់ **លោកតា គ្រុយ ស្រ៊ន** ត្រូវជា ឪពុក , ជីតា ដែលលោកបានធ្វើកាលកិរិយាទៅកាន់ បរលោកហើយ ព្រមទាំង លោកយាយ តាំង ស្រីង ត្រូវជាម្តាយ , ជីដូន ដែលលោក នៅមានព្រះជន្មនៅឡើយ សូមឱ្យលោកសំរេចនូវ មគ្គ៤ ផល៤ និង ព្រះនិព្វាន ជាអវសានជាតិ ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា គ.ស ២០០១ ព.ស ២៥៤៦

កូននិងចៅ សពលោកតា គ្រុយ ស្រ៊ន